01391823

E1/505.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Feb-2017, 10:36
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៤៨៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ស្តាវរ៉ូឡា ប៉ាប៉ាដូប៉ូឡូស
*(Ms.Stavoroula PAPADOPOULOS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ធរិន្ត

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063 | ខ្មែរ |
| លោក ស៊ិន អ៊ឹង (2-TCW-1069) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖** 2-TCCP-1063

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី................................................................ ទំព័រ ៣
សួរដោយលោក គង់ សំអុន ផ្ដើមពី ...................................................................... ទំព័រ ២៩

**ការសួរសំណួរទៅសាក្សី៖ លោក ស៊ិន អ៊ីង** (2-TCW-1069)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ............................................................................ ទំព័រ ៤២
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី.......................................................................... ទំព័រ ៤៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063 និងចាប់ផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1069។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គល ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក ពេជ អង្គ សហមេធាវីនាំមុខជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានដោយមូលហេតុផ្ទាល់ខ្លួន ហើយលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1063 លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់មានរហស្សនាម 2-TCW-1069 សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ ហើយសាក្សីមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:០៤:២៦]

**ប្រធានអង្គជំនុំ៖**

អរគុណ លោកស្រី សែ កុលវុឌ្ឍី។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ បានបញ្ជាក់ថា ដោយគាត់មានបញ្ហា សុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរនិងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់ សវនាការនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាព ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាព ជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៦។ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះ និងវិលមុខមិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទេកាជូនទៅមេធាវីការពារក្តី ដែលដំបូងនេះផ្តល់វេទិការជូនទៅមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

បាទ សូមអញ្ជើញ!

[០៩:០៦:១២]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ជម្រាបសួរលោកប្រធាន។ យើងខ្ញុំមិនមានសំណួរអ្វីទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តទៅនេះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោកលោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ជាមួយនឹងលោកមេធាវី គង់ សំអុន ខ្ញុំមានសំណួរសួរបន្ថែមមួយចំនួនទៅលើសក្ខីកម្មរបស់លោក។ ខ្ញុំចាំអារម្មណ៍លើរយៈកាលមុនឆ្នាំ១៩៧៥ <ហើយខ្ញុំចង់សួរឡើងវិញអំពី> ចំណុចពីរ។ កាលពីម្សិលមិញនៅម៉ោង ១៥:៣៩នាទី លោកថាលោកជាទាហាន លន់ នល់ អស់រយៈពេល៣ខែ ក៏ប៉ុន្តែខ្ញុំអត់បានឮថាលោកប្រាប់ជូនតុលាការថា ពេលណាលោកបានក្លាយជាទាហានលន់ នល់ នោះទេ តើលោកអាចបញ្ជាក់ជូនតុលាការបានទេនៅពេលនេះ?

[០៩:០៧:២៤]

2-TCCP-1063៖

**ឆ៖** បាទ សូមគោរពលោកប្រធាន។ បាទ ខ្ញុំចូលទាហានលន់ នល់ កាលឆ្នាំ៧១ បាទ។

**ស៖** ហើយខ្ញុំក៏ដូចជាយល់ដែរ កាលពីម្សិលមិញនេះថា លោកបានឈប់ធ្វើជាទាហានទៅហើយលោកត្រឡប់ចូលធ្វើជាប្រជាជនវិញ ក្រោយពីពេលបានរងរបួស។ តើលោកពិតជាបាននិយាយអ៊ីចឹងមែនទេកាលពីម្សិលមិញ?

**ឆ៖** បាទ ខ្ញុំសូមនិយាយ គឺថាម្សិលមិញខ្ញុំបាននិយាយអ៊ីចឹងមែនបាទ។

**ស៖** នៅពេលដែលលោកនិយាយថាលោកធ្វើជាប្រជាជនវិញហ្នឹង គឺលោកចង់សំដៅថាលោកធ្វើជាកសិករវិញ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ ពេលនោះខ្ញុំឈប់ពីទាហានខ្ញុំនៅជាកសិករ។

**ស៖** លោកបាននិយាយអំពីឪពុកលោកផងដែរ <បើសិនខ្ញុំមិនច្រឡំទេ គាត់>ជាឈ្លបនៅក្នុងកងឈ្លបកាលហ្នឹង កងស្វ័យត្រាណ អ៊ីចឹងមែនទេកងស្វ័យត្រាណ ហើយខ្ញុំក៏ដូចជាឮលោកនិយាយផង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែរម្សិលមិញថា នៅក្នុងកងស្វ័យត្រាណហ្នឹងគាត់ទទួលបន្ទុកក្នុងការការពារមិនឲ្យកងទ័ពបដិវត្តខ្មែរក្រហមហ្នឹងចូលទៅក្នុងទឹកដីរបស់គាត់។ តើលោកពិតជាបាននិយាយអ៊ីចឹងមែនទេកាលពីម្សិលមិញ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ម្សិលមិញខ្ញុំបាននិយាយអ៊ីចឹងមែន ពីព្រោះគេយកប្រជាពលរដ្ឋហ្នឹងឲ្យចូលកងស្វ័យត្រាណ ដើម្បីជំនួយកម្លាំងជាមួយកងទ័ពទាហាន លន់ នល់ បាទយើងសម្រាប់នៅសមរភូមិក្រោយ។

**ស៖** ពេលលោកនិយាយគាត់នៅក្នុងបញ្ជីនេះ <តើលោកចង់សំដៅទៅលើ>បញ្ជីឈ្មោះទាហាន លន់ នល់ ឬក៏បញ្ជីឈ្មោះអីដែរលោក?

**ឆ៖** បាទ ខ្ញុំស្តាប់អត់ទាន់ត្រង់ហ្នឹង។ បាទ សូមមានប្រសាសន៍ម្តងទៀត។

[០៩:១០:០២]

**ឆ៖** បាទ ខ្ញុំស្តាប់អត់ទាន់ត្រង់ហ្នឹង បាទ សូមមានប្រសាសន៍ម្តងទៀត។

**ស៖** លោកបាននិយាយថា គេដាក់គាត់ចូលទៅក្នុងបញ្ជី ដើម្បីធ្វើការជាមួយទាហាន លន់ នល់ អ៊ីចឹងខ្ញុំចង់ដឹងថា អ្នកណាអ្នកដាក់ឈ្មោះឈ្លបនុំងចូលបញ្ជី? តើវាជាអាជ្ញាធរយោធា ជាអ្នកដាក់ឈ្មោះនុំងចូលបញ្ជី ឬក៏អ្នកណាដែរ?

**ឆ៖** បាទ ដាក់ឈ្មោះចូលបញ្ជីនេះ គឺថាត្រឹមអាជ្ញាធរឃុំ បានមិនមែនអាជ្ញាធរយោធាទេ ត្រឹមមេឃុំ បាទ មេឃុំ មេភូមិហ្នឹង គេបញ្ចូលជាកងសេនាជននៅក្រោម គេហៅកងស្វ័យត្រាណ កាលសម័យនោះ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំលើចំណុចនេះ តើលោកដឹងដែរឬទេ ថាតើមានការប្រឈមមុខគ្នារវាងកងស្វ័យត្រាណនេះ ហើយនិងសមាជិកនៃកងកម្លាំងរបស់កងចលនាបដិវត្តន៍ដែរឬទេ?

**ឆ៖** បាទ កាលនោះ គឺថាមានដែរ មានការប្រឆាំងគ្នា ពីព្រោះហ្នឹង យើងជួយការពារទាំងអស់គ្នា អត់មានប្រឆាំងនឹងបដិវត្តន៍មែន។

[០៩:១១:៣៩]

**ស៖** ខ្ញុំសូមឲ្យលោកជួយបំភ្លឺចំណុចមួយទៀត ខ្ញុំដូចជាមិនយល់ច្បាស់អំពីពេលវេលាដែលខ្មែរក្រហមមកដល់កន្លែងដែលលោករស់នៅ។ តើនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ឬក៏កងកម្លាំងបដិវត្តន៍នេះចូលមកដល់កន្លែងដែលលោករស់នៅហ្នឹង មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥នេះទៀត?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ពីព្រោះក្នុងខេត្តស្វាយរៀង គឺថាចូលថ្ងៃ១៤ បាទ មុន

ចូលឆ្នាំ បាទ មុនចូលឆ្នាំ គឺថាកងទ័ពបដិវត្តន៍ហ្នឹង ចូលដល់ទីក្រុងស្វាយរៀង។ ជម្លៀសប្រជាជន ដេញប្រជាជនចេញពីខេត្តស្វាយរៀង បាទ ហ្នឹង មុនៗថ្ងៃ១៧។

**ស៖** ពេលលោកនិយាយថា ថ្ងៃទី១៤ហ្នឹង លោកសំដៅទៅលើថ្ងៃ១៤ មេសា ឆ្នាំ១៩៧៥ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ បានខ្ញុំសំដៅថ្ងៃ១៤ ព្រោះថ្ងៃនោះ ត្រូវចំថ្ងៃចូលឆ្នាំ បាទ ត្រូវចំថ្ងៃចូលឆ្នាំ ពីព្រោះកងទ័ពបដិវត្តន៍ហ្នឹង ចូលដល់ក្រុងស្វាយរៀង។

**ប្រធានអង្គជំនុំ៖**

សំណួរមិនសួរអីចឹងទេ ចង់សួរ ឲ្យសួរបញ្ជាក់ថា តើថ្ងៃ១៤ហ្នឹង ចង់បញ្ជាក់ថា ថ្ងៃ១៤ ក្នុងខែមេសា ឆ្នាំ១៩៧៥ ពិតមែនដែរឬទេ? ព្រោះលោកនិយាយ១៤ហ្នឹង វាមានច្រើនខែ ច្រើនឆ្នាំ មិនដឹងឆ្នាំណាទេ។ ចង់ឲ្យបង្ហាញជាក់លាក់ថា ថ្ងៃ១៤នេះ ១៤ខែមេសា ឆ្នាំ១៩៧៥ ពិតមែនដែរឬទេ?

[០៩:១៣:៣២]

**2-TCCP-1063៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ថ្ងៃ១៤ គឺថាថ្ងៃ១៤ ខែមេសា ៧៥ បាទ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នេះជាចំណុចចុងក្រោយរបស់ខ្ញុំ ទាក់ទងនឹងរយៈពេលនេះ។ យើងទាំងអស់គ្នាស្របគ្នាហើយថា រហូតដល់ថ្ងៃ<១៤> មេសា ឆ្នាំ១៩៧៥ កន្លែងដែលលោករស់នៅហ្នឹង គឺស្ថិតនៅក្រោមរដ្ឋបាល ឬក៏ឥទ្ធិពលនៃកងទ័ព កងទាហាន លន់ នល់។ តើអីចឹងមែនទេ?

**ឆ៖** បាទ។ ពេលនោះហើយ ដែលពេលដែលខ្ញុំត្រូវថ្ងៃ១៧ហ្នឹង ត្រូវខ្ញុំទទួលគ្រោះពីកងទ័ពបដិវត្តន៍ ព្រោះពេលនោះហើយ ដែលកងទ័ពបដិវត្តន៍បានដេញចេញ ខ្ញុំចេញពីទីក្រុងស្វាយរៀង។ ពេលនុំហើយ ដែលខ្ញុំត្រូវការមានការភិតភ័យជាខ្លាំង ពីព្រោះមានកងទ័ពវៀតណាមបាញ់រះ ដើម្បីឲ្យប្រជាជនចេញ។ បើអ្នកណាមិនចេញ គេត្រូវតែបាញ់អីចឹងតែម្តង បាទ។ ក្នុងពេលនោះហើយ ដែលខ្ញុំមានការតក់ស្លុតៗ ដោយសារភ័យពេក បានជាមូលហេតុយកអីមិនបាន។ មួយទៀត គេស្រែកថាឲ្យចេញតែពីរបីថ្ងៃទេ ឲ្យបងប្អូនចូលរស់នៅក្នុងផ្ទះសម្បែងវិញហើយ តែក្រោយមក មិនដែលឃើញ មិនទាន់មានឲ្យកងប្រជាជនណាមួយចូលទៅរស់នៅរហូតហ្នឹង។ ពេលក្រោយមក គឺថាជម្លៀសបន្តៗទៀត និងកន្លងមកហ្នឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:១៥:១៧]

**ស៖** សំណួរខ្ញុំខុសពីនេះបន្តិច។ ខ្ញុំចង់បញ្ជាក់ជាមួយលោកថា រហូតដល់ពេលគេជម្លៀសនេះ ហើយនិងមុនពេលដែលកងទ័ពបដិវត្តន៍ចូលមកដល់នោះ កន្លែងដែលរស់នៅ ឃុំរបស់លោករស់នៅហ្នឹង ស្ថិតនៅក្រោមការគ្រប់គ្រង ឬក៏ក្រោមឥទ្ធិពលនៃទាហាន ឬក៏កងទ័ពលន់នល់។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ កាលនោះ មុននឹងពេលនោះ ខ្ញុំរស់នៅក្រោមការគ្រប់គ្រង់របស់លោក លន់ នល់។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីចម្លើយមួយចំនួនដែលលោកបានបំពេញក្នុងឋានៈលោកជាអ្នកចូលរួមក្នុងតុលាការនេះ។ ខ្ញុំសូមធ្វើលំដាប់លំដោយពេលវេលាដូចតទៅនេះ។ យើងនៅក្នុងសំណុំរឿងមានទម្រង់បែបបទបីខុសគ្នា ដែលលោកបានបំពេញទម្រង់បែបបទទី១ គឺឯកសារ E3/10670 ដែលចុះថ្ងៃទី០២ <ខែសីហា> ឆ្នាំ២០០៨ ដែលជាទម្រង់បែបបទទី១ នៃការសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក។ មានទម្រង់បែបបទទី២ គឺឯកសារE3/5932a ប្រហែលជាខ្ញុំឯកសារទី១ អម្បាញ់មិញហ្នឹង គឺឯកសារ E3/10670a ដូចគ្នាដែរ។ ហើយទម្រង់បែបបទទី២ គឺព័ត៌មានបន្ថែមរបស់លោកចុះថ្ងៃទី២ មេសា ២០១០ គឺឯកសារE3/5932a ហើយឯកសារមួយទៀតគឺទម្រង់ព័ត៌មានបន្ថែមដែរ ដែលមាននៅក្នុងសំណុំរឿង ០០៤មិនមែននៅក្នុងសំណុំរឿង ០០២ យើងនេះទេ គឺឯកសារ E3/10670 ដែលមេធាវីរបស់លោកបានបញ្ជូលមកនៅថ្ងៃទី០៥ មករា ២០១៥។ តើលោកចាំដែរឬទេ លោកមានចាំអំពីទម្រង់បែបបទដែលលោកបានបំពេញទាំងអស់នេះទេ? គឺថាលោកបានធ្វើទី១ នៅឆ្នាំ២០០៨ ពីព័ត៌មានបន្ថែមនោះ លោកបានបំពេញនៅឆ្នាំ២០១០ ហើយនិងឯកសារចុងក្រោយគេគឺចុងឆ្នាំ២០១៤ ឬក៏ដើមឆ្នាំ២០១៥ លោកបានបំពេញទម្រង់បែបបទនេះ។ លោកនឹកឃើញទេ ថាលោកបានបំពេញសំណុំទម្រង់បែបបទទាំងបីនេះ?

**ឆ៖** បាទ ខ្ញុំបាននឹកឃើញខ្លះដែរ។

[០៩:១៨:៤០]

**ស៖** ឥឡូវខ្ញុំសូមនិយាយអំពីទម្រង់បែបបទទី១ ដែលលោកបានបំពេញនៅឆ្នាំ២០០៨ ដែលលោក<សុំតាំងខ្លួន>ធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងយើងនេះ។ នៅពេលដែលលោកបំពេញទម្រង់បែបបទនេះ តើនៅពេលនោះ លោកមានមេធាវីហើយឬនៅ ហើយបើមិនអ៊ីចឹងទេ តើអ្នកណាជួយបំពេញទម្រង់បែបបទពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីឲ្យលោក?

**ឆ៖** បាទ កាលនោះខ្ញុំដូចភ្លេចដែរ ខ្ញុំអត់ទាន់បានចាំ មិនបានចាប់អារម្មណ៍ទេ ថាដល់កម្រិត

ហ្នឹងផង។

**ស៖** តើលោកមានចាំថា កាលនោះ ពេលដែលលោកបំពេញទម្រង់បែបបទហ្នឹង លោកបំពេញតែម្នាក់ឯងទេ ឬក៏មានអ្នកជួយបំពេញលោកដែរ?

**ឆ៖** បាទ កាលនោះ គឺថាមានអ្នកចូលរួមជួយបំពេញដែរ។ តែខ្ញុំមិនបានចាំ។

**ស៖** អ៊ីចឹង បើថាអត់ លោកអត់ចាំឈ្មោះអ្នកជួយនោះ ក៏អត់ទៅចុះ ក៏ប៉ុន្តែតើលោកមានចាំថាអ្នកជួយហ្នឹង គឺជាមេធាវី ឬក៏ជាអ្នកធ្វើការឲ្យអង្គការណាមួយដែរឬទេ?

**ឆ៖** បាទ ពេលនោះអ្នកធ្វើការខាងអង្គការ តែខ្ញុំអត់បានចាំឈ្មោះអង្គការ។

**ស៖** សូមអរគុណ។ នៅក្នុងទម្រង់បែបបទនេះ លោកបាននិយាយអំពីការដែលលោកបានចូលទៅផ្សារមួយ ក៏ប៉ុន្តែលោកមិនបាននិយាយអំពី ខៀវ សំផន ទេ។ អ៊ីចឹងខ្ញុំយោងទៅលើឯកសារ E3/10670a, ERN ជាអង់គ្លេសគឺ <00422204>, ERNជាភាសាខ្មែរគឺ 00397758។ លោកនិយាយអំពីផ្នែក ពេលដែលចូលទៅក្នុងផ្សារហ្នឹងដូចតទៅនេះ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ “<យើងត្រូវបានគេស្នើឲ្យចាកចេញ> ហើយព្រឹកឡើងយើងបានមកដល់ផ្សារថ្មី ហើយស្នាក់នៅទីនោះអស់រយៈពេលបីយប់។ ពួកយើងម្នាក់ៗហ្នឹង គឺថាទទួលបានបាយមួយកញ្ចប់ ទទួលបានក្រមាពណ៌<បៃតង>មួយ និងខោអាវមួយកំប្លេ។ ក្រោយមកគេបានឲ្យយើងឡើងជិះឡានធំៗ<របស់ខ្មែរក្រហម> ដើម្បីទៅកាន់ស្ថានីយរថភ្លើង<នៅម៉ោងមួយរសៀល។> ខ្ញុំធ្វើដំណើរតាម<រថភ្លើង>រយៈពេល<មួយថ្ងៃ>មួយយប់ ទើបដល់ព្រៃស្វាយនៅម៉ោងដប់ពីរ<ថ្ងៃត្រង់>។” ចប់ការដកស្រង់។

[០៩:២២:២៩]

អ៊ីចឹងសំណួរទី១ របស់ខ្ញុំទាក់ទងនឹង<ពេល>ដែល<លោក>នៅផ្សារថ្មីនេះ។ <កាលពីម្សិលមិញ> ខ្ញុំ<ជឿជាក់ថា ខ្ញុំបានយល់ពី>ការពន្យល់<ដែល>លោក<បានផ្តល់ទៅឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា លោកបានទៅផ្សារថ្មី ពីព្រោះលោកមិនបានមិនស្គាល់ភ្នំពេញទេ> អ៊ីចឹងប្រហែលជាលោកច្រឡំ ក៏ប៉ុន្តែនៅទម្រង់បែបបទទី២ ដែលខ្ញុំនឹងនិយាយបន្តិចទៀតនេះ។ នៅពេលដែលមេធាវីរបស់លោកសួរទៅលោកថា តើហេតុអីបានលោកដឹងថាផ្សារនុ៎ងជាផ្សារច្បារអំពៅ? លោកនិយាយថា ពីព្រោះអ្នកដែលមកជាមួយលោកហ្នឹង ប្រាប់ថាអាហ្នឹងជាផ្សារច្បារអំពៅ។ អ៊ីចឹង បើសិនជាលោកដឹងថាជាផ្សារច្បារអំពៅ ដោយសារគេប្រាប់លោកនោះ ហេតុអីក៏លោកមិននិយាយតាំងពីដើមទីមកក្នុងទម្រង់បែបបទរបស់លោកហ្នឹងថា លោកដឹងថាអាហ្នឹងជាផ្សារច្បារអំពៅហ្នឹង ដោយសារគេប្រាប់

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

លោក?

**ឆ៖** បាទ កាលនោះ ខ្ញុំអត់ស្គាល់មែន ដល់ពេលគេប្រាប់ក្រោយមក បានគេថាផ្សារហ្នឹងផ្សារច្បារអំពៅ រហូតទល់នឹងសព្វក៏ខ្ញុំមិនសូវបានស្គាល់ច្បាស់លាស់ដែរ។ ហ្នឹងខ្ញុំសូមជម្រាបលោកប្រធាន។

**ស៖** ពេលដែលលោកនិយាយថា ក្រោយមកហើយហ្នឹងបានលោកដឹងហ្នឹង តើក្រោយមកហើយហ្នឹង លោកសំដៅលើពេលណាដែរ?

**ឆ៖** បាទ ក្រោយមកនេះ ក្រោយពេលដែលកងទ័ពរបស់សម្តេច ហ៊ុន សែន គាត់រំដោះបានហើយហ្នឹង បានខ្ញុំស្គាល់។

**ស៖** អ៊ីចឹងលោកដឹងថា វាមិនមែនជាផ្សារថ្មីនោះ គឺ<នៅក្រោយពេលដែល>កងទ័ពរបស់សម្តេច ហ៊ុន សែន បានរំដោះបានហើយ<>។ អ៊ីចឹង បានន័យថា <នៅពេលដែលលោកបំពេញព័ត៍មាន>នៅក្នុងទម្រង់បែបបទទី១របស់លោកនេះ <នៅឆ្នាំ២០០៨>ហ្នឹង គឺ<លោកបានដឹងហើយថាលោក>មិនមែន<ទៅ>ផ្សារថ្មីទេ <ប៉ុន្តែលោកទៅ>ផ្សារច្បារអំពៅ។ លោកចង់និយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំចង់និយាយថា ផ្សារច្បារអំពៅ។

[០៩:២៥:៤២]

**ស៖** អ៊ីចឹងដូចដែលដឹងថា កាលនោះទាហានសម្តេច ហ៊ុន សែន អ្នកប្រាប់នោះ។ អ៊ីចឹងម៉េចក៏នៅពេលដែលលោកបំពេញទម្រង់បែបបទទី១ហ្នឹង ម៉េចលោកនៅប្រើពាក្យថា “ផ្សារថ្មី” ទៀត?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ទី ស្រ៊ីនណា៖**

ខ្ញុំសូមធ្វើការជំទាស់ទៅនឹងសំណួរនេះ ពីព្រោះដើមបណ្តឹងរដ្ឋប្បវេណីពុំបាននិយាយថា កងទ័ពសម្តេច ហ៊ុន សែន ជាអ្នកប្រាប់គាត់ថាផ្សារច្បារអំពៅនោះទេ។ ដូច្នេះហើយ ខ្ញុំគិតថា បើសិនជាបន្តនូវការតាំងសំណួរបែបនេះ វាហាក់បីដូចជាទាញនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការឆ្លើយប្រាសចាកទៅនឹងអ្វីដែលគាត់បានឆ្លើយកន្លងមក។ សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គិសសេ៖**

ខ្ញុំគិតថា ប្រហែលជាមានបញ្ហាបកប្រែហើយ ព្រោះតាមការបកប្រែតាមភាសាជាបារាំង ខ្ញុំឮ

អ៊ីចឹងឯង។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសួរលោកថា តើអ្នកណាជាអ្នកប្រាប់លោកថា ផ្សារនុំងជាផ្សារច្បារអំពៅទេ គឺមិនមែនផ្សារថ្មីទេ? ហើយអ្នកប្រាប់លោកហ្នឹង ប្រាប់លោកនៅពេលណាដែរ? អ្នកណាជាអ្នកប្រាប់ ហើយប្រាប់នៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ លោកសួរអំមិញហ្នឹង ខ្ញុំដូចជាស្ដាប់អត់ទាន់ដែរ។ ហើយខ្ញុំឆ្លើយអំមិញ ខ្ញុំមិនមែនឆ្លើយថា កងទ័ពសម្ដេច ហ៊ុន សែន អ្នកប្រាប់ទេ។ ខ្ញុំថា គេប្រាប់ហ្នឹងប្រាប់ពេលក្រោយពេលដែលកងទ័ពសម្ដេច ហ៊ុន សែន គាត់រំដោះបាន។ ហ្នឹងប្រជាជន ប្រាប់ អ្នកប្រាប់ មិនមែនកងទ័ពអ្នកប្រាប់ទេ។ តែដល់គាត់និយាយអំមិញ គាត់ថាកងទ័ពសម្ដេច ហ៊ុន សែន អ្នកប្រាប់។ ខ្ញុំថាត្រង់ហ្នឹង ត្រូវខុសយោបល់គ្នា។

[០៩:២៧:៥០]

តាមពិត ប្រជាជនដែលគាត់មកពីក្រោយរំដោះ៧៩ហើយនេះ ដែលខ្ញុំជួបគាត់ ខ្ញុំសួរគាត់ច្បាស់លាស់ទៅ អង្កាល់ដែលយើងមកសម្រាក គេជម្លៀសយើងពីស្វាយរៀង មកសម្រាកនៅហ្នឹង តើសម្រាកនៅផ្សារថ្មី ឬក៏សម្រាកនៅផ្សារច្បារអំពៅ។ ហើយគាត់ដែលគេជម្លៀសមកជាមួយខ្ញុំនេះ គេថា មិនមែនផ្សារថ្មីទេ ផ្សារថ្មីហ្នឹងមានដែរ ប៉ុន្តែប្រជាជននៅខេត្តគេ បាទ នៅខេត្តគេ។ តែត្រង់ខេត្តស្វាយរៀងនេះ គឺសម្រាកនៅផ្សារច្បារអំពៅ។ ពីព្រោះពេលនោះជម្លៀសប្រជាជនបីខេត្ត មានខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តព្រៃវែង។ មិនមែនសំដៅថា មកសម្រាកនេះ មានតែផ្សារថ្មីទេ គឺថាផ្សារថ្មីដាក់ប្រជាជនមិនអស់ទេ បាទ ដល់ហើយត្រូវហៀរមកដល់ផ្សារច្បារអំពៅ។ ហ្នឹងក្នុងបញ្ហា ខ្ញុំជម្រាបលោកប្រធានឲ្យជ្រាប។

**ស៖** អ៊ីចឹងសំណួរខ្ញុំនៅតែដដែលទេ លោក។ ដោយហេតុថា ក្រោយពីកងទ័ពសម្ដេច ហ៊ុន សែន រំដោះបានហើយហ្នឹង លោកដឹងថាផ្សារហ្នឹង ផ្សារច្បារអំពៅទេ។ អ៊ីចឹង ហេតុអីបានដល់ឆ្នាំ២០០៨ហើយនេះ លោកបំពេញសំណុំបែបបទលោកហ្នឹង លោកនៅតែដាក់ថា នៅផ្សារថ្មីទៀត?

**ឆ៖** បាទ សុំទោស ព្រោះខ្ញុំកាលនោះ ខ្ញុំមិនសូវបានចាប់អារម្មណ៍ដែរ ដល់ឆ្លើយទៅ យើងមិនបាននៅក្រឹត្យក្រមទេ គឺថាមានការភាន់ច្រឡំ។

**ស៖** នៅក្នុងផ្នែកដែលខ្ញុំដកស្រង់អម្បាញ់មិញហ្នឹង លោកបាននិយាយអំពីពេលដែលទៅដល់ផ្សារហ្នឹង ហើយពេលសម្រាក។ ក៏ប៉ុន្តែលោកអត់បាននិយាយអំពីវត្តមានលោក ខៀវ សំផន នៅទីនោះ

ទេ។ តើលោកអាចពន្យល់ទេ ហេតុអីបានលោកមិនបានលើកឡើងអំពីចំណុចនេះ?

[០៩:៣០:០៨]

**ឆ៖** បាទ ខ្ញុំជម្រាបលោកប្រធាន ពីព្រោះក្នុងការនិយាយ យើងនិយាយមិនបានអស់ពាក្យគ្រប់ជ្រុងជ្រោយទេ ប៉ុន្តែពេលណាសួរត្រង់ណាខ្ញុំឆ្លើយត្រង់ហ្នឹង បើសិនឲ្យខ្ញុំឆ្លើយ ខ្ញុំអាចឆ្លើយបាន។

**ស៖** ដូចលោកនិយាយពីការចែកចាយចំណីអាហារ កន្សែង សម្លៀកបំពាក់ ហើយលោកបានលើកឡើង<ថា> លោក<ត្រូវបានគេ>ដឹក<តាមឡាន>ទៅដល់ស្ថានីយរថភ្លើង<>។ លោក<បានលើក>ឡើង<យ៉ាងលម្អិតអំពីអ្វីដែលគេឲ្យលោកនៅថ្ងៃនោះ> ប៉ុន្តែនៅក្នុងសវនាការនេះ លោកហាក់ដូចជាផ្សារភ្ជាប់ការបែងចែកស្បៀង ចែកចាយស្បៀង ហើយនិងសម្លៀកបំពាក់ហ្នឹង ហើយនិងការដែលលោក ខៀវ សំផន មកដល់។ អ៊ីចឹងខ្ញុំឆ្ងល់ថាហេតុអីក៏លោកមិនបានលើកឡើងពីចំណុចទាំងអស់នេះ <បើទោះជាលោកមិនត្រូវបានគេសួរនូវសំណួរជាក់លាក់ក៏ដោយ>?

**ឆ៖** បាទ ខ្ញុំស្តាប់ដូចអត់ទាន់សំណួរទាំងនេះ។ បាទ សូមសួរម្តងទៀត។

[០៩:៣១:២៩]

**ស៖** នៅក្នុងសវនាការនេះនៅពេលដែលលោកនិយាយអំពីការមកដល់នៃស្បៀង ហើយនិងសម្លៀកបំពាក់ទាំងអស់ហ្នឹងលោកបាននិយាយថា គេដឹកឡានធំ ឡានពីរដែលគេដឹកមកហ្នឹង។ ហើយនៅក្នុងឡានមាន ខៀវ សំផន ដែរ ហើយក្រោយមកគាត់ធ្វើសុន្ទរកថា ហើយក្រោយដែលគាត់មកដល់ហ្នឹងគឺ គេចែកចាយអីវ៉ែអីវ៉ាន់របស់របរទាំងអស់ហ្នឹងឲ្យលោក។ អ៊ីចឹងវាមាន<ការផ្សារភ្ជាប់គ្នា>រវាង<វត្តមានរបស់>លោក ខៀវ សំផន ហើយនិងការចែកចាយអីវ៉ែអីវ៉ាន់ទាំងអស់ហ្នឹង។ អ៊ីចឹងខ្ញុំសួរលោកថា ហេតុអីបាននៅក្នុងទម្រង់បែបបទ<ព័ត៌មានលើកទី១>របស់លោកនោះ <បើទោះបីជាលោកមិនត្រូវបានសួរនូវសំណួរជាក់លាក់អំពីរឿងទាំងអស់នេះ? ពីព្រោះវាស្របទៅនឹងអ្វីដែលលោកបានរៀបរាប់រួចមកហើយនៅក្នុងឯកសារនេះ ដូចជាទទួលស្បៀង និង>អីវ៉ែអីវ៉ាន់អីហ្នឹង<>ជាដើមនោះណា ម៉េចក៏នៅក្នុងសាលសវនាការនេះលោកផ្សារភ្ជាប់ចំណុចនេះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមធ្វើការកត់សម្គាល់ខ្លីមួយលោកប្រធាន។ <នៅក្នុងសវនាការសំណុំរឿងនេះ> ខ្ញុំ<បាន>ធ្វើការកត់សម្គាល់ច្រើនដងទៅហើយ ព្រោះថាយើងត្រូវយល់អំពីការធ្វើទម្រង់បែបបទ<ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ គឺ>ពីដំបូងមកគឺអង្គការ<ក្រៅរដ្ឋាភិបាល បានកត់ត្រានូវរាល់ព័ត៌មាន

ទាំងឡាយ។ ខ្ញុំសូមកត់សម្គាល់ម្តងទៀតថា វាមិនចាំបាច់នោះទេ ដែលថាសាក្សីមិនបានលើកឡើងអំពីរឿងនេះ ប៉ុន្តែ>ប្រហែល <បុគ្គលិក>របស់អង្គការក្រៅរដ្ឋាភិបាល – <CHRAC> – ប្រហែលជាគាត់មិនបានសរសេរបញ្ចូលក៏មិនដឹង <ពីព្រោះពួកគាត់គឺជាអ្នកកត់ត្រាពាក្យសម្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនមែនគាត់ជាអ្នកសរសេរនោះទេ>។ អ៊ីចឹងមេធាវីការពារក្តី<មានសិទ្ធិក្នុងការសាកសួរពីកំណត់ហេតុរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃនេះ> ក៏ប៉ុន្តែយើង<ទាំងអស់គ្នាបាន>យល់<ច្បាស់ហើយ>ពីស្ថានភាព<ចាំបាច់នៅពេលនោះ ពោលគឺថាឯកសារទាំងអស់នោះត្រូវបានបំពេញដោយអង្គការក្រៅរដ្ឋាភិបាល នៅចំពោះមុខ>មេធាវី <ដែលគេចាត់តាំង។>

[០៩:៣៣:២៨]

**កញ្ញា អង់តា ហ្គីសសេ៖**

<ខ្ញុំពិតជាយល់អំពីអំណះអំណាងរបស់លោកស្រី ប៉ុន្តែអំណះអំណាងហ្នឹងមានតែប៉ុណ្ណោះ។ ចំពោះករណីនេះ> ខ្ញុំគ្រាន់តែសួរ<សំណួរមួយទៅ>ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ <ហើយគាត់មានសេរីភាពក្នុងការពន្យល់ ប៉ុន្តែខ្ញុំ>ចង់ឲ្យគាត់ហ្នឹងពន្យល់ចេញពីមាត់គាត់តែម្តង ឲ្យយើងបានយល់ទាំងអស់គ្នា។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមបន្តសួរតទៅទៀត។ ដោយសារ -- គឺថាលោកឆ្លើយនៅទីនេះហ្នឹងគឺលោកផ្សារភ្ជាប់ទំនាក់ទំនងរវាង ខៀវ សំផន ហើយនិងការចែកចាយស្បៀង។ អ៊ីចឹងសំណួរខ្ញុំនៅតែដដែលទេលោក ខ្ញុំចង់សួរលោកថា ហេតុអីបាននៅក្នុងទម្រង់បែបបទសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី<លើកដំបូងហ្នឹង> លោកមិនបានលើកអំពីចំណុចនេះ?

**2-TCCP-1063៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាប ពីព្រោះពេលនោះគឺថា ពេលសរសេរគឺថាខ្ញុំមិនបានសរសេរខ្លួនឯងទេ ចំណែកខាងអង្គការគាត់អ្នកសរសេរ។ ប៉ុន្តែពេលនោះសួរខ្ញុំ ខ្ញុំចេះតែឆ្លើយដែរ ប៉ុន្តែដល់ពេលក្រោយមកមិនដឹងដែរខ្ញុំ ធ្លប់បញ្ហាហ្នឹងដែរ ប៉ុន្តែជាក់ស្តែងដែលខ្ញុំត្រូវជួបបញ្ហានេះ គឺថាជួបពិតប្រាកដៗមែន។ សូមជម្រាបលោកប្រធានអ៊ីចឹង។

**ស៖** លោកបានចុះហត្ថលេខាលើទម្រង់បែបបទនេះ ហើយអង្កាល់នុំងគេអានឲ្យលោកស្តាប់ហើយមុននឹងសូមឲ្យលោកចុះហត្ថលេខាមែនទេ?

01391838



**ឆ៖** បាទ កាលនោះខ្ញុំដូចអត់បានចាំដែរ ដូចជាបានអាន ឬមិនបានអាន ខ្ញុំអត់បានចាំកាលនោះ។

**ស៖** នៅទំព័រដែលខ្ញុំដកស្រង់ដដែលហ្នឹង លោកបាននិយាយអំពីការបំពេញទម្រង់បែបបទហ្នឹង គឺលោកមាននិយាយលើកឡើងពីប្រធានសហករណ៍ព្រែកជីក នៅ<>ស្វាយ<ស្ដ័រ>។ ខ្ញុំឃើញថា <លោកបាន>លើកឡើងនូវឈ្មោះប្រធានសហករណ៍មួយដែលលោកលើកឡើងនៅថ្ងៃនុ៎ង។ អ៊ីចឹង<ខ្ញុំចង់សួរថា> ពេលដែលលោកឃើញ ខៀវ សំផន <ឬ>លោកនិយាយថាលោកបានឃើញ ខៀវ សំផន នៅផ្សារហ្នឹង តើនៅពេលហ្នឹងលោកស្គាល់ពីតួនាទីគាត់ទេ? ដឹងពីតួនាទីគាត់ទេ?

[០៩:៣៦:១៩]

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំបាននិយាយពីម្សិលមិញម្ដងហើយ ព្រោះខ្ញុំមិនបាននៅចាំតួនាទីគាត់ ព្រោះខ្ញុំភ្លេចកាលនោះ។ បាទ ខ្ញុំអត់បានចាំមែនបាទ។

**ស៖** លោកមិនដឹងពីតួនាទីរបស់គាត់ក៏ដោយចុះ តើលោកគិតថាគាត់ជាមនុស្សធំដុំដែរឬទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏កាលនោះលោកគិតថាគាត់គ្រាន់តែមានតួនាទីឬក៏មុខតំណែងស្មើនឹងប្រធានសហករណ៍ទេនៅពេលនោះ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន កាលនោះគាត់ហ្នឹងមានតួនាទីខ្ពស់ណាស់ បាទជាថ្នាក់ដឹកនាំជាន់ខ្ពស់បាទអង្កាល់នោះ គ្រាន់តែខ្ញុំមិនបានចាំឋានន្តរសក្តិ ឬតួនាទីរបស់គាត់ច្បាស់លាស់។ ព្រោះទាស់ខ្ញុំមិនបានចាំមែន ហើយគ្រាន់ដឹងថាគាត់ហ្នឹងមានតួនាទីខ្ពស់ជាងគេ ជាថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងសម័យនោះ។

**ស៖** ហើយនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង តើលោកធ្លាប់ជួបអ្នកដែលលោកគិតថាមានតួនាទីខ្ពស់អ៊ីចឹងទេ មានតំណែងធំអ៊ីចឹងទេ?

**ឆ៖** បាទ កាលនោះខ្ញុំអត់ដែលបានជួបផង ពីព្រោះយើងជាប្រជាជននៅតែតាមជនបទ។ ខ្ញុំទើបនឹងគេជម្លៀសខ្ញុំមកនេះ បានខ្ញុំជួបគាត់នៅទីក្រុងតែម្ដង ទើបជួបម្ដងហ្នឹងគត់បាទ។

[០៩:៣៨:៣៤]

**ស៖** អ៊ីចឹងតើយើងយល់ស្របហ្នឹងគ្នាដែរឬទេ ក្នុងការនិយាយថា លោកជួបមនុស្សម្នាក់ដែលលោកគិតថាជាអ្នកដឹកនាំជាន់ខ្ពស់ហ្នឹង ការជួបរបៀបហ្នឹងគឺកម្រមានណាស់។ លោកយល់ស្របហ្នឹងខ្ញុំទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំសូមយល់ស្រប។ បញ្ហានេះគឺថា ប្រជាជនទាំងអស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កម្រនឹងជួបអ្នកធំជំនាន់ហ្នឹងណាស់បាទ។

**ស៖** សូមអរគុណ។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ ហើយវាជាចំណុចចុងក្រោយទាក់ទងនឹងទម្រង់បែបបទហ្នឹងផង ហើយលោកនិយាយថានេះជាឱកាសមួយដ៏កម្រ ដែលជួបអ្នកធំ។ <បើតាមលោកចាំបាន> តើអង្គាល់នោះលោកបាន<រៀបរាប់ពីព្រឹត្តការណ៍នេះ>ប្រាប់អ្នកជួយបំពេញសំណុំបែបបទឲ្យលោកដែរ<ឬទេ? ឬប្រហែលជា>គេ<ភ្លេច មិនបាន>បញ្ចូល<ឈ្មោះ ខៀវ សំផន?>

[០៩:៤០:០៣]

**លោក នីកូឡាស គូមជែន៖**

<លោកប្រធាន ខ្ញុំជឿជាក់ថា យុត្តិធម៌អាចផ្តល់ឲ្យសាក្សីបានលុះត្រាតែលោកស្រីមេធាវីបញ្ជាក់ពីផ្នែកនៃឯកសារនិងទីកន្លែងដែលបានសរសេរ ពីព្រោះផ្នែកនៃឯកសារនេះមានចំណងជើងជាភាសាអង់គ្លេសថា "ការពិពណ៌នាពីឧក្រិដ្ឋកម្ម ឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើង ហើយឧក្រិដ្ឋកម្មកើតឡើងយ៉ាងដូចម្តេច"។ ដូច្នេះនេះជាសំណួរទូទៅដែលត្រូវបានឆ្លើយដោយសាក្សី>អំពីអ្វីដែលកើតឡើងចំពោះគាត់ ហើយនិងគ្រួសារគាត់។ កាលនោះ គេអត់មានបាននិយាយ<ថាតើគោលនយោបាយឧក្រិដ្ឋកម្មត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច ហើយថ្នាក់ដឹកនាំជាន់ខ្ពស់បានបង្កើតគោលនយោបាយយ៉ាងដូចម្តេចនោះទេ។ បើក្រឡេកមើលទៅដើមដំបូងនៃផ្នែកនេះ ឯកសារនេះបានសរសេរថា "ការពិពណ៌នាពីឧក្រិដ្ឋកម្ម ឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើង ហើយឧក្រិដ្ឋកម្មកើតឡើងយ៉ាងដូចម្តេច"។>

**កញ្ញា អង់តា ហ្គីសសេ៖**

<សូមអរគុណម្តងទៀតលោកប្រធាន> នេះគឺ<អាច>ជាគោលជំហររបស់សហព្រះរាជអាជ្ញា។ អ៊ីចឹង<នៅចុងក្រោយ គឺនៅពេលដែលយើងនឹងជជែកដេញដោល ហេតុអ្វីឈ្មោះ ខៀវ សំផន អត់មាននៅក្នុងទម្រង់ព័ត៌មាននេះ។> ក៏ប៉ុន្តែ<សំណួររបស់ខ្ញុំគឺស្របច្បាប់ ហើយ>យើង<ថែមទាំង>ឃើញថាមានតែឈ្មោះអ្នកដែលប្រធានសហករណ៍ <>ដែលមានសរសេរនៅក្នុងទម្រង់បែបបទហ្នឹង។ អ៊ីចឹង<សំណួររបស់>ខ្ញុំ<នៅដដែល។ តើលោកនៅចាំបានទេ?>

[០៩:៤១:២០]

**លោក នីកូឡាស គូមជែន៖**

តើឈ្មោះប្រធានសហករណ៍ នៅកន្លែងណាដែរ លោកស្រីមេធាវី?

**កញ្ញា អង់តា ហ្គីសសេ៖**

គឺឯកសារ <E3/10760>*(ស៊ីក)*, ERN ជាភាសាអង់គ្លេស គឺ <00422204>, ជាភាសាខ្មែរ 00397758។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកស្រីនិយាយលឿនបន្តិចហើយ។ ឥឡូវសូមឲ្យលោក<ស្រីអានលេខ E> ឡើងវិញបន្តិចទៀតមើល៍។

**កញ្ញា អង់តា ហ្គីសសេ៖**

E3/10670a។ វាជាទម្រង់បែបបទទី១ ចុះថ្ងៃទី០២ សីហា ឆ្នាំ២០០៨។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំនៅតែសួរសំណួរដដែលទេលោកដើមបណ្ដឹងរដ្ឋប្បវេណី។ តើបើតាមលោកចងចាំ លោកមានបាននិយាយពីឈ្មោះ ខៀវ សំផន ពេលដែលគេសម្ភាសលោក<លើកទី១ទេ>? ហើយឈ្មោះនោះអត់<មាននៅក្នុងឯកសារ បើទោះជាលោករៀបរាប់ក៏ដោយ> គេនៅតែមិនសរសេរ ដោយសារគេភ្លេចសរសេរ កត់ត្រាឈ្មោះលោក ខៀវ សំផន ហ្នឹងចូល ឬក៏យ៉ាងម៉េច? <តើលោកនៅចាំបានថា លោកបានរៀបរាប់ពីព្រឹត្តការណ៍នេះទេ?>

[០៩:៤៣:០២]

**2-TCCP-1063៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន កាលគេសម្ភាសនោះ បើតាមខ្ញុំនឹកឃើញ គេអត់បានទាន់សួរត្រង់ហ្នឹងផង។ គេអត់មានសួរពីរឿងជួបលោក ខៀវ សំផន នុ៎ង អត់មានបានសួរទេ តែក្រោយមក បានទើបនឹងគេសួរក្រោយហ្នឹងបានខ្ញុំប្រាប់គេ។ តែដល់ហើយក្នុងឯកសារនេះ មិនដឹងគេបំពេញ ឬមិនបំពេញ ខ្ញុំអត់ដឹង។

**ស៖** អ៊ីចឹងអ្វីដែលលោកចង់និយាយ ខ្ញុំចង់យល់លោកឲ្យច្បាស់។ ដោយសារគេមិនបានចោទសំណួរ<លោកពី> ខៀវ សំផន ហើយនៅពេលដែលលោកបាននិយាយអំពី<អ្វីដែលបានកើតឡើងនៅ>ផ្សារនោះ។ ទោះជាផ្សារច្បារអំពៅក៏ដោយ ផ្សារថ្មីក៏ដោយហ្នឹង គឺលោកមិនបាននិយាយអំពី ខៀវ សំផន ទេ ក៏ប៉ុន្តែលោកបាននិយាយថា បានទទួល ស្រូវ អង្ករ ស្បៀង ខោអាវ ក្រមា អីជាដើម ហើយលោកបាននិយាយអំពីការដែលគេបញ្ជូនលោកទៅស្ថានីយរថភ្លើង។ ហើយពេលដែលលោករៀបរាប់

នេះ គឺលោកមិនបាននិយាយអំពី ខៀវ សំផន ទេ ដោយសារកាលនោះ គេមិនបានសួរលោកអំពីលោក ខៀវ សំផន ទេ។ តើអ៊ីចឹងមែនទេ លោកពិតជាចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ពេលនោះគេមិនបានសួរអ៊ីចឹងមែន។

[០៩:៤៤:៥២]

**ស៖** ដើម្បីឱ្យច្បាស់ទាំងអស់គ្នា ដោយសារគេមិនសួរលោកពាក់ព័ន្ធនឹងគាត់ អ៊ីចឹងហើយបានលោកមិនបាននិយាយអំពីគាត់ហ្នឹង។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលនោះ គេអត់បានសួរអ៊ីចឹងមែន បាទ ខ្ញុំសូមជម្រាបឱ្យត្រង់អ៊ីចឹង គឺថាពេលនោះ គេអ្នកសម្ភាសអត់បានសួរបញ្ហាថា ជួបលោក ខៀវ សំផន ឬមិនជួប ខ្ញុំអត់បានប្រាប់ ព្រោះដល់គេមិនសួរ ខ្ញុំអត់ប្រាប់បាទ។

**ស៖** ឥឡូវមានចំណុចមួយទៀត ទាក់ទងទៅនឹងទម្រង់បែបបទនេះ ខ្ញុំនឹងនិយាយពីលោក ខៀវ សំផន នៅក្នុងទម្រង់បែបបទទី២។ ទម្រង់បែបបទទី១ ERN ជាភាសាអង់គ្លេសគឺ 00422202, ជាភាសាខ្មែរគឺ 00397758។ នៅក្នុងទម្រង់បែបបទទី១ ហ្នឹង ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ “នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកក្នុងឃុំរបស់ខ្ញុំ ហើយជម្លៀសប្រជាជនចេញពីទីរួមខេត្តស្វាយរៀងឱ្យមកនៅម្តុំភូមិឃុំ ដែលជាស្រុកកំណើតរបស់ខ្ញុំ។” បញ្ចប់ការដកស្រង់។ តើលោកនៅរក្សាចម្លើយរបស់លោកនេះទេ គឺថា មានជម្លៀសថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ហើយបន្ទាប់មក លោកត្រឡប់មកភូមិកំណើតរបស់លោកវិញនៅខែឧសភា ឆ្នាំ១៩៧៥។ តើលោករក្សាចម្លើយហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំរក្សាចម្លើយរបស់ខ្ញុំ។

**ស៖** នៅក្នុងទម្រង់បែបបទហ្នឹងដដែលលោកនិយាយថា គេយកទៅអប់រំ ទៅកសាងនៅវត្តតាចាយ។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ “ក្រោយពេល ចំណាយពេល៤ខែនៅទីនោះ អង្គការបានឱ្យខ្ញុំត្រឡប់ទៅផ្ទះវិញ ហើយធ្វើការឱ្យបានខ្លាំងក្លានៅក្នុង<សហករណ៍ភូមិ>តាជ័យ។” បញ្ចប់ការដកស្រង់។ បើតាមចម្លើយរបស់លោកនេះ គឺថា គេឃុំលោក៩ខែ ហើយក្នុងនេះ ឃើញសរសេរតែ៤ខែទេ។ អ៊ីចឹងខ្ញុំសូម ឱ្យលោកបញ្ជាក់ជូនតុលាការ ថាតើរយៈពេលមួយណា ៤ខែ ឬ៩ខែ មុនពេលដែលលោកត្រឡប់ចូលទៅនៅសហករណ៍វិញនេះ?

**ឆ៖** បាទ អរគុណ។ បាទ ខ្ញុំសូមជម្រាបលោកប្រធាន ក្នុងពេលខ្ញុំជាប់គុកនោះ គឺថា មិនមែនរយៈកាល៤ខែទេ តែដល់គាត់អ្នកសរសេរ គាត់ស្តាប់មិនទាន់ដឹង គាត់ថា៤ខែ ខ្ញុំជាប់នោះ គឺថារយៈ

កាល៩ខែៗ ហ្នឹងបានខ្ញុំ គេដោះលែងៗខ្ញុំចេញពីកន្លែងឃុំឃាំងនោះ។ រយៈកាល៩ខែ មិនមែន៤ខែទេ។

[០៩:៤៨:៤៥]

**សៈ** ឥឡូវខ្ញុំសូមចូលនិយាយអំពីទម្រង់បែបបទទី២របស់លោក ចុះនៅថ្ងៃទី០២ មេសា ឆ្នាំ ២០១០ ហើយនៅក្នុងឯកសារហ្នឹង ជាឯកសារទី១ ហើយដែលលោកនិយាយពីឈ្មោះ ខៀវ សំផន គឺ ឯកសារ E3/5932a។ ចំណុចដែលខ្ញុំចាប់អារម្មណ៍ ERN ជាភាសាអង់គ្លេសគឺ 01332268, ជាភាសា ខ្មែរគឺ 00578456។ មុននឹងចោទសំណួរទៅលោកលើចំណុចនេះ ខ្ញុំសូមការបំភ្លឺមួយសិននៅក្នុងសំណុំ រឿងនោះ គឺមានឯកសារមួយទៀត គឺឯកសារ D22/19414 ដែលជាការផ្ទេរសិទ្ធិអំណាចទៅមេធាវី របស់លោកដើម្បីឱ្យគាត់តំណាងលោក។ មានតែជាភាសាអង់គ្លេសទេគឺ 00407825, ជាឯកសារដែល ចុះនៅថ្ងៃទី២៥ តុលា ឆ្នាំ២០០៩។ មេធាវីដែលតំណាងឱ្យលោកហ្នឹង គឺជាមេធាវី ជេត វណ្ណលី។ សំណួរទី១ របស់ខ្ញុំថា តើលោកនៅចាំទេថា នៅខែតុលា ឆ្នាំ២០០៩ លោកបានទទួលមេធាវីមួយដែល ចាប់ផ្តើមតំណាងឱ្យលោកនៅក្នុងសំណុំរឿងយើងនេះ។ លោកនៅចាំទេ?

**ឆៈ** បាទ កាលនោះ ខ្ញុំបានទទួលមេធាវីមួយមែន អង្កាល់នោះ។

**សៈ** ដូចដែលខ្ញុំបានលើកឡើងអ៊ីចឹង គឺថានៅក្នុងសំណុំរឿងយើងនេះ គឺថាមានទម្រង់បែបបទ ទី២ ដែលជាព័ត៌មានបន្ថែមចុះថ្ងៃទី០២ មេសា ឆ្នាំ២០១០ ក្រោយពីពេលលោកទទួលបានមេធាវីហើយ នេះ។ អ៊ីចឹងខ្ញុំសួរលោកថា តើនៅពេលដែលលោកបំពេញទម្រង់បែបបទព័ត៌មានបន្ថែមហ្នឹង លោកបំពេញ ហ្នឹង មេធាវីលោក ដែលលោកទើបទទួលបានហ្នឹង មានជួយបំពេញលោកទេ?

**ឆៈ** បាទ ពេលនោះ មាន គាត់មានជួយបំពេញ។

[០៩:៥១:៥២]

**សៈ** ឥឡូវខ្ញុំបង្ហាញលេខ ERN ដែលខ្ញុំបានជម្រាបជូនអម្បាញ់មិញហ្នឹង។ អ៊ីចឹងនៅពេល លោកនៅផ្សារហ្នឹង លោកលើកឡើងដូចតទៅនេះ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ពីព្រោះអត់មានជា ភាសាបារាំងទេ "នៅភ្នំពេញ នៅជាយផ្សារច្បារ នៅមុំផ្សារច្បារអំពៅ គឺថាគេបានឃើញ ខៀវ សំផន គឺ បានចែកចាយក្រមាពណ៌ខៀវឱ្យពួកយើង នៅពេលយប់ នៅម៉ោងពីរយប់ ពួកគេបានយកយើងឱ្យទៅ កាន់ស្ថានីយរទេះភ្លើង ហើយឡើងជិះ<រថភ្លើង ទៅព្រៃវែង>។ល។" ថ្ងៃទី០២ មេសា ឆ្នាំ២០១០ មាន មេធាវីជួយលោក អង្កាល់នោះលោកនិយាយអំពី ខៀវ សំផន ហើយគេចោទសំណួរទៅលោកពីលោក ខៀវ សំផន ហើយបើខ្ញុំនិយាយខុស លោកកែខ្ញុំ។ អ៊ីចឹងថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ លោកបាននិយាយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អំពី ខៀវ សំផន ថាគាត់ជាអ្នកចែកក្រមា។ តើលោកមាននៅចាំអំពីទម្រង់បែបបទមួយហ្នឹង ហើយដែលថានៅក្នុងទម្រង់បែបបទហ្នឹង លោកបាននិយាយថាលោក ខៀវ សំផន អ្នកចែកក្រមា លោកនៅចាំទេ នៅក្នុងទម្រង់បែបបទព័ត៌មានបន្ថែមរបស់លោកហ្នឹង លោកនិយាយអ៊ីចឹង?

**ឆ៖** បាទ កាលនុ៎ង គាត់អ្នកមកចែកមែន អង្គាល់នុ៎ងបាទ។ ចែកបាយ ចែកខោអាវ ចែក្រមា ចែកថ្នាំពេទ្យ មុននឹងចេញដំណើរឡើងរថយន្តទៅកន្លែងវ៉ារទេះភ្លើង។

[០៩:៥៣:៥៨]

**ស៖** នៅក្នុងទម្រង់បែបបទចុះខែមេសា ឆ្នាំ២០១០ហ្នឹង ជាលើកទី១ ហើយដែលលោកនិយាយអំពីលោក ខៀវ សំផន ហើយលោកមិនដែលនិយាយអំពីសុន្ទរកថាគាត់ទេ នៅពេលដែលគាត់ចែកក្រមា ហើយនិងចែកស្បៀងនេះ។ អ៊ីចឹងលោកអាចពន្យល់ជូនតុលាការបានដែរឬទេ ថាហេតុអ្វីបានជាលោកមិននិយាយអំពីសុន្ទរកថានេះ ដែលលោកបានលើកឡើងនៅចំពោះមុខតុលាការនេះតែម្តងនោះ<? បើទោះជាវាមិនមានអ្វីជាចម្ងល់ទេនៅពេលដែល>លោកនិយាយពីរឿង ខៀវ សំផន ដែរ<នោះ។>

**ឆ៖** បាទ អរគុណ។ បាទ ក្នុងពេលនោះ ខ្ញុំសូមជម្រាបលោកប្រធាន គឺថា មេធាវីគាត់អត់បានសួរខ្ញុំពីរឿងលោក ខៀវ សំផន គាត់មានសុន្ទរកថាអ្វីខ្លះទេ កាលនោះ។ បាទគ្រាន់តែសួរថា លោក ខៀវ សំផន បានមកចែកស្អីខ្លះ។ តែគាត់អត់បានសួរពីបញ្ហាលើសុន្ទរកថាទេ។ បាទ ដល់ហើយ ខ្ញុំក៏អត់បានឆ្លើយដែរ។ មូលហេតុនេះហើយ បាននៅក្នុងឯកសារអត់មាន។ បាទ ខ្ញុំជម្រាបលោកប្រធាន។

**ស៖** អ៊ីចឹង អ្វីដែលលោកពន្យល់ជូនទៅតុលាការនោះ គឺថានៅពេលដែលលោក<និយាយ>អំពី ខៀវ សំផន នៅផ្សារហ្នឹង គឺលោកមិនបាននិយាយរឿងវ៉ារឲ្យអស់គ្រប់ជ្រុងជ្រោយនៅផ្សារនោះទេ ពីព្រោះថាគេមិនបានសំណួរ មិនបានសួរសំណួរជាក់លាក់ទៅលោក អង្គាល់នោះ។ លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

[០៩:៥៦:០១]

**ឆ៖** បាទ ខ្ញុំចង់និយាយត្រឹមហ្នឹង។ ពីព្រោះកាលនោះ អត់មានបានសួរមែន ដល់អ៊ីចឹងខ្ញុំក៏អត់បានឆ្លើយដែរ។ ម្យ៉ាងទៀត ពេលនោះ ខ្ញុំមិនបានចាប់អារម្មណ៍ដូចថា ដល់ដំណាក់កាលហ្នឹងទេ។ គឺថាគេសួរត្រង់ណា ខ្ញុំត្រង់ហ្នឹង។ បានដល់ហើយខ្ញុំអត់ប៉ាននិយាយច្រើន។ បាទ អរគុណ។

**ស៖** អ៊ីចឹង អ្វីដែលខ្ញុំចង់ដឹងហ្នឹង គឺថា ដោយហេតុថាលោកមិនបាននិយាយអំពីឈ្មោះ ខៀវ សំផន ទាល់តែសោះ នៅពេលដែលលោកបំពេញទម្រង់បែបបទទី១របស់លោកនោះ។ អ៊ីចឹងថាហេតុអី

បាននៅក្នុងទម្រង់បែបបទទី២ហ្នឹង លោកនិយាយពី ខៀវ សំផន<?> ដោយសារគេសួរលោកពីឈ្មោះ ខៀវ សំផន ហ្នឹង បានលោកបញ្ចូលឈ្មោះហ្នឹងចូលទៅក្នុងទម្រង់បែបបទហ្នឹង <ឬមួយលោកជាអ្នកនិយាយពីគាត់ខ្លួនឯង? អ្វីដែលខ្ញុំចង់ដឹងនោះ គឺថា> តើលោកជាអ្នកនឹកឃើញនិយាយពីឈ្មោះ ខៀវ សំផន ដោយផ្ទាល់ ដោយខ្លួនឯង ឬក៏ទាល់តែមានគេសួរលោក ខៀវ សំផន ហ្នឹង បានលោកនិយាយពីឈ្មោះគាត់នោះ? អ៊ីចឹង<ខ្ញុំចង់បញ្ជាក់ថា> ទម្រង់បែបបទទី២ហ្នឹង ជាទម្រង់បែបបទពីព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងបទពិសោធន៍ ឬក៏ការរស់នៅរបស់លោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ីចឹង ខ្ញុំសួរលោកថាដាក់ឈ្មោះលោក ខៀវ សំផន ហ្នឹង ដោយចិត្តឯង ឬក៏ដោយសារមេធាវីសួរ?

[០៩:៥៧:៤៦]

**ផ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ ចំណែកលោក ខៀវ សំផននេះ ដល់ពេលគេសម្ភាសខ្ញុំក្រោយ បានគេសួរ។ បាទ បានគេសួរ សួរហើយ បានគេសួរបញ្ជាក់ទៀត តើគាត់មកចែកហ្នឹង តើគាត់មានបាននិយាយអ្វីខ្លះក្នុងពេលទៅចែកអំណោយឲ្យប្រជាជន។ ហ្នឹងក្នុងពេលនេះហើយ បានខ្ញុំទើបនឹងឆ្លើយពេលក្រោយ។ បាទ អាហ្នឹង ខ្ញុំទើបឆ្លើយពេលក្រោយ។ ព្រោះពេលមុន ខាងមេធាវី ឬខាងអង្គការគាត់អត់បានសួរចំណែកខាងហ្នឹងទេ បានដែលអត់ក្នុងសំណុំរឿងអត់មាន។ បាទ ខ្ញុំសូមជម្រាបលោកប្រធានប៉ុណ្ណឹង។

**សៈ** ប៉ុន្តែឥឡូវនៅក្នុងទម្រង់បែបបទទី២នេះ ដោយសារមានការលើកឡើងអំពីគាត់នោះ។ អ៊ីចឹងលោកម៉េចក៏ ខ្ញុំចង់និយាយថា ម៉េចក៏លោកមិន អង្កាល់នោះ <តើ>លោកមិនយល់ឃើញថា គួរតែនិយាយ<រៀបរាប់លម្អិត>ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកនៅផ្សារច្បារអំពៅហ្នឹង<ដែរឬទេ>?

**ផ៖** បាទ កាលនោះ បានខ្ញុំមិននេះ ខ្ញុំមិនបាននឹកឃើញដែរ ដូចថាភ្លេចដែរ។ ដល់ក្រោយមកបានគេសួរទៅ បានខ្ញុំទើបស្រាវជ្រាវ នឹកឃើញ។ ដល់នឹកឃើញក្នុងការវេទនា ក្នុងការពិបាកពេលនោះ តើយើងខ្ញុំជួបបញ្ហាអីខ្លះ បានខ្ញុំទើបលើកឡើងក្រោយ។ បាទ ពេលមុន ខ្ញុំអត់បានចាប់អារម្មណ៍ពីបញ្ហាហ្នឹងទេ។ ម្យ៉ាងដល់ខាងអង្គការក៏មិនសួរ មេធាវីក៏មិនសួរ ខ្ញុំក៏មិនបានឆ្លើយក្នុងបញ្ហានេះដែរ។ បាទ សូមជម្រាបលោកប្រធានប៉ុណ្ណឹង។

[១០:០០:០២]

**សៈ** ឥឡូវខ្ញុំលើកពីសំណួរពីមុនមក ទាក់ទងទៅនឹងទម្រង់បែបបទទី១។ លោកបាននិយាយដោយខ្លួនឯងផ្ទាល់ថាការជួបថ្នាក់ដឹកនាំជាន់ខ្ពស់ហ្នឹងជា<ឱកាសដ៏>កម្រមានណាស់។ ប៉ុន្តែឥឡូវនេះ

ពេលដែលគេនិយាយអំពី ខៀវ សំផន គេចោទសំណួរសួរ ខៀវ សំផន ពេលដែលលោកបំពេញព័ត៌មានបន្ថែមនេះ លោកនៅតែយល់ឃើញថាវាមិនសំខាន់អីទេ មិនចាំបាច់និយាយអំពីព័ត៌មានលម្អិតទាក់ទងនឹង ខៀវ សំផន នេះទេឬក៏យ៉ាងម៉េច<? នេះជាអ្វីដែលខ្ញុំបានយល់ ពីចម្លើយរបស់លោកកន្លងមក។>

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់មួយ។ មេធាវីការពារក្ដីគាត់លើកឡើងអម្បាញ់មិញថា ខ្ញុំកំពុងតែធ្វើការសន្និដ្ឋាន ក៏ប៉ុន្តែ<ខ្ញុំគិតថា>គាត់កំពុងធ្វើការសន្និដ្ឋានដែរ <នៅពេលដែល>គាត់កំពុងតែ<ចោទសួរ និង>សង្កត់ធ្ងន់ទៅលើអ្វីដែលដើមបណ្ដឹងរដ្ឋប្បវេណី<បាន>ធ្វើ <ឬក៏>មិន<បាន>ធ្វើគិត <ឬក៏មិនបានគិត នៅពេលដែលគាត់បាន>ជួបមេធាវី <ឬបាន>ជួបអង្គការ<>ជាដើម។ ខ្ញុំសុំថាសូមឱ្យ<>លោកស្រីមេធាវីហ្នឹងសួរសំណួរកណ្ដាលអព្យាក្រឹត្យ<ជាជាងការព្យាយាមរកពាក្យឱ្យដើមបណ្ដឹងរដ្ឋប្បវេណីនិយាយ ហើយធ្វើឱ្យគាត់>គិតថានេះជារឿងសំខាន់ <ឬ>មិនសំខាន់។

[១០:០១:៣៣]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លើសពីនេះទៅទៀត> ចំណុចដែលសំខាន់<ខ្លាំង>សម្រាប់មេធាវីការពារក្ដី ដូចជាសុន្ទរកថានេះ <ប្រហែលជាមិនសូវសំខាន់សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សីដែលមិនបានទទួលការបណ្ដុះបណ្ដាលផ្នែកច្បាប់នោះទេ។ នេះគ្រាន់តែជាការកត់សម្គាល់ទូទៅរបស់ខ្ញុំ។>

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំមិនដឹងថា ការសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនោះ វាចេញជាលទ្ធផលអ្វីនោះទេ ក៏ប៉ុន្តែខ្ញុំមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីសួរសំណួរបែបនេះ <ក្នុងតួនាទីជាមេធាវីការពារក្ដីរបស់ ខៀវ សំផន> ដើម្បីឱ្យដឹងថាតើហេតុអី<បានជានៅក្នុង>ឆ្នាំ២០១៥<ដែល>ដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់<សក្ខីកម្ម>ដាក់បន្ទុក<មកលើកូនក្ដីរបស់ខ្ញុំ> ព្រោះថាគាត់<ត្រូវ>បាន<គេសម្ភាសជាច្រើនលើកច្រើនសាចាប់>តាំងឆ្នាំ២០០៨មកម្ល៉េះ។ <សម្រាប់ខ្ញុំ ការសួរសំណួរទាំងអស់នេះជារឿងធម្មតាទេ។> ហើយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីថាខ្ញុំហ្នឹងជាអ្នកញាត់ពាក្យសម្ដីទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំថា តាមពិតគាត់ទេជាអ្នកនិយាយ <និង>ជាអ្នកផ្ដល់សក្ខីកម្ម <ហើយគាត់គិតថាវាមិនសំខាន់នៅក្នុងការផ្ដល់ព័ត៌មានទាំងនេះ>។ អ៊ីចឹង<វាជារឿងធម្មតាទេដែល>ខ្ញុំត្រូវតែចោទសំណួរដើម្បី<ទទួលបានព័ត៌មានមុននឹងខ្ញុំធ្វើការបកស្រាយដោយផ្ទាល់។ ខ្ញុំចោទសួរគាត់ដើម្បី>ឱ្យដឹងថា តើនៅពេលដែលគាត់បំពេញ

ទម្រង់បែបបទនោះ ពេលដែលគាត់ឆ្លើយពីមុនៗមកនោះ គាត់មានស្មារតី ឬក៏ការពិចារណាយល់ឃើញយ៉ាងណា បាន<ជាគាត់>មិនបាន<និយាយដល់>ចំណុចនេះ អ៊ីចឹងហើយបានខ្ញុំចង់សួរឲ្យលេចចំណុចនេះឡើង។ <ដូច្នេះខ្ញុំគិតថា នេះគ្រាន់តែជាការកត់សម្គាល់ មិនមែនជាការជំទាស់ទេ។> ឥឡូវខ្ញុំសូមសួរបន្ត។ នៅពេលដែលលោកនិយាយពី ខៀវ សំផន ពេលដែលលោកបំពេញសំណុំទម្រង់បែបបទព័ត៌មានបន្ថែមនោះ ទោះបីជាគេមិនសួរ<>សំណួរលោកពាក់ព័ន្ធ<នឹង>លោក ខៀវ សំផន ឲ្យនិយាយព័ត៌មានលម្អិតពី<អ្វីដែល> ខៀវ សំផន <បាននិយាយនោះ តើ>លោកមិនយល់ឃើញថា ជាការសំខាន់ទេឬ<> ក្នុងការនិយាយអំពី<គ្រប់ហេតុការណ៍នៅផ្សារនោះ អំពីអ្វីដែលលោកបានឃើញ ព្រមទាំង>អ្វីដែលលោក<បានឮពីលោក> ខៀវ សំផន <នៅ>ពេលដែលគាត់ចែកចាយអីវ៉ែអីវ៉ាន់ ចែកចាយក្រមា ចែកចាយអីហ្នឹង ឬក៏អ្វីដែលគាត់បាននិយាយនៅពេលនោះ លោកគិតថាមិនសំខាន់ទេឬ?

[១០:០៣:៥៤]

2-TCCP-1063៖

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ពេលនោះខ្ញុំនិយាយឲ្យត្រង់ទៅ ខ្ញុំមិនសូវបានចាប់អារម្មណ៍មែនបាទ មិនសូវបានចាប់អារម្មណ៍ទេ។ ទើបនឹងក្រោយមក ដល់ខាងតុលាការ ហៅខ្ញុំមកបាន ខ្ញុំទើបនឹកឃើញបាទ។ ពីព្រោះកាលមុនខ្ញុំអត់បានចាប់អារម្មណ៍ទេបាទ ព្រោះយើងជាប្រជាជនមិនសូវគិតចាប់អារម្មណ៍ពីបញ្ហាហ្នឹងប៉ុន្មានទេ។ ពីព្រោះកសិករសម្រាប់តែខំបង្កបង្កើនផល ម៉្លោះហើយការងារក្នុងហ្នឹងយើងមិនសូវបានចាប់អារម្មណ៍ មូលហេតុនេះហើយបានខ្ញុំមិនបានឆ្លើយ ទទួលនឹងខាងអង្គការក៏មិនបានសួរ វារួមចំណែកគ្នាក្នុងពេលហ្នឹងខ្ញុំក៏មិនបានប្រាប់ដែរ។ បាទខ្ញុំសូមជម្រាបលោកប្រធានអ៊ីចឹងបាទ។

**ស៖** ឥឡូវខ្ញុំសូមចូលទៅនិយាយពីទម្រង់បែបបទទី៣របស់លោក ដែល<លោកបានដាក់ជូនជាផ្នែកនៃការស៊ើបអង្កេតនៅក្នុង>សំណុំរឿង០០៤ គឺឯកសារE3/10670 ដែលបញ្ជូនមកនៅថ្ងៃទី<០៥> មករា ឆ្នាំ២០១៥ <ដោយ>មេធាវីរបស់លោក។ <ចំពោះឯកសារនេះ ដូចដែលខ្ញុំបានយល់ច្បាស់អំពី> ការពន្យល់ពីមុនៗរបស់លោក ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃកិច្ចសម្ភាសន៍ ដើម្បីទទួលបានព័ត៌មានបន្ថែមហ្នឹង ទោះបីឆ្នាំ២០១៤ក៏ដោយ ២០១៥នោះក៏ដោយ មេធាវីរបស់លោកបានចោទសំណួរជាក់លាក់អំពី ខៀវ សំផន។ អាស្រ័យហេតុដូច្នេះហើយ បានលោកនិយាយអំពីព័ត៌មានលម្អិត និយាយពាក់ព័ន្ធអំពីលោក ខៀវ សំផន បានលម្អិតជាងមុន។ តើ<ជាការត្រឹមត្រូវទេដែលខ្ញុំបានធ្វើការពន្យល់ពីអ្វី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែលបានកើតឡើងនៅពេលនោះ>?

[១០:០៦:១២]

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន មេធាវីមិនបានជម្រិតខ្ញុំទេ គ្រាន់តែខ្ញុំដល់ពេលហើយ បានខ្ញុំទើបនឹងនឹកឃើញ បានខ្ញុំទើបនឹងជម្រាបជូនមេធាវីក្រោយ បានតែរឿងហ្នឹង ក្នុងឯកសារទើបនឹងមានក្រោយ បាទ ពីព្រោះពេលនោះ ដូចថាវាយូរឆ្នាំពេក ខ្ញុំភ្លេចដែរ។ ក្រោយមក បានខ្ញុំទើបនឹងនឹកឃើញ បានខ្ញុំរំឭកឡើងវិញ ពីបញ្ហាហ្នឹងខ្ញុំរាយការណ៍ជូនមេធាវី បាទ។ ដល់ហើយ បានមេធាវីបញ្ចូលក្នុងឯកសារហ្នឹង បាទ។

**ស៖** អ៊ីចឹងបើខ្ញុំមិនច្រឡំទេ គឺថាលោកបានភ្លេចអំពីផ្នែកពាក់ព័ន្ធ អង្គហេតុពាក់ព័ន្ធនឹង ខៀវ សំផនហ្នឹង ហើយដល់ពេលលោកនឹកឃើញហើយ បានលោកនិយាយប្រាប់មេធាវីរបស់លោក។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ តើលោកនៅតែជឿជាក់ថា ការចងចាំរបស់លោកហ្នឹងច្បាស់លាស់ទេ<?> ព្រោះថារឿងរ៉ាវនេះវាកើតឡើងកន្លងយូរមកហើយ ទោះបីនៅក្នុងទម្រង់<ឯកសារ> E3/10670 ហើយនិងនៅក្នុងសវនាការនេះក៏ដោយ គឺលោកបាននិយាយ<>លម្អិត <នូវពាក្យសម្ដី> ប្រធានបទ <និងបញ្ហានានា>ដែលលោក ខៀវ សំផន <បានលើកឡើងនៅពេល>នុ៎ង។ ERN ជាភាសាអង់គ្លេស គឺ 01190623, ERN ជាភាសាខ្មែរគឺ <01118429 ហើយនៅទំព័របន្ទាប់>។ លោកលើកឡើងដូចតទៅនេះ នៅក្នុងផ្នែកនេះ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ "នៅពេលដែលយើងឈប់សម្រាក អង្គការបានផ្ដល់បាយ <និងត្រីកាម៉ុងចំហុយ>ឲ្យយើងហូប។ នៅព្រឹកថ្ងៃទី០៣ មុនពេលយើងបន្តដំណើររបស់យើងទៅទៀត មេដឹកនាំខ្មែរក្រហម គឺ ខៀវ សំផន និងក្រុមរបស់គាត់ (ភាគច្រើន ខ្ញុំអត់ស្គាល់ពួកគាត់ទេ) បានជិះឡានមកចែកបាយចំណីឲ្យយើង មានក្រមា សម្លៀកបំពាក់ ហើយនិង<ប្រេងកូឡា> ចែកថ្នាំសង្កូវឲ្យយើងផងដែរ។ ក្រោយពីចែករបស់របរទាំងអស់នេះហើយ ខៀវ សំផន និងថ្នាក់ដឹកនាំរបបខ្មែរក្រហម បាននិយាយថា យើងបន្តធ្វើបដិវត្តន៍ ដើម្បីរំលំរបប លន់ នល់ ហើយនិងលុបបំបាត់ពួកមូលធននិយម ចក្រពត្តិនិយម <និងបញ្ញវន្តនិយម>។ ហើយយើង<ធ្វើការរារាំងពួកមូលធននិយមកុំឲ្យ> គាបសង្កត់ប្រជាជន។ យើងចង់លុបបំបាត់ បំបាត់ឲ្យអស់វណ្ណៈអ្នកក្រ និងអ្នកមាន។ យើងចង់លើកតម្កើងឲ្យប្រជាជនទាំងអស់មានភាពស្មើគ្នា។ អង្គការបានយកបងប្អូនទាំងប្រុស ទាំងស្រីមកនេះ ដើម្បីទប់ស្កាត់ជាមួយនឹងពួក<ឈ្លានពាន និងចក្រពត្តិវៀតណាម> ដែលសម្លាប់បងប្អូនប្រុសស្រី ឪពុកម្ដាយរបស់យើង។ អ្នកទាំងអស់គ្នានឹងត្រូវទៅរស់នៅភូមិភាគនិរតី។ <សូមដើរ>តាមរយៈគោលនយោបាយ

របស់កម្ពុជាប្រជាធិបតេយ្យ។ សុំដើរតាមបក្សឲ្យបានស្មោះត្រង់<រហូត> បើអ្នកណាម្នាក់ក្បត់បក្ស អ្នកនោះនឹងត្រូវគេសម្លាប់ចោលហើយ។ ហើយមានសុភាសិតមួយថា <>ទុកក៏មិនចំណេញ ដកអ្នកឯងចេញក៏មិនខាតដែរ។" បញ្ចប់ការដកស្រង់។

[១០:១០:០៦]

ខ្ញុំសូមបន្តទៅទៀត "ក្រោយ ខៀវ សំផន ចែករបស់របរទាំងអស់នេះ ហើយថ្លែងសុន្ទរកថាមក ប្រជាជនបានឡើងជិះឡានទៅស្ថានីយរថភ្លើងនៅម៉ោងប្រាំបួន<ព្រឹក>"។ បញ្ចប់ការដកស្រង់។ អ៊ីចឹងលោកធ្វើការរៀបរាប់លម្អិតលើខ្លឹមសារនៃសុន្ទរកថា លោក ខៀវ សំផន ពីព្រោះថា លោកបានប្រាប់តុលាការថា លោកបានភ្លេចអំពីព្រឹត្តិការណ៍ហ្នឹងហើយ ហើយក្រោយមកបានលោកនឹកឃើញ។ អ៊ីចឹងខ្ញុំសួរលោកថា តើពាក្យពេចន៍ដែលលោកប្រើនេះ ពិតជាពាក្យពេចន៍ដែលលោក ខៀវ សំផន បានថ្លែងមែនទេ ក្នុងសុន្ទរកថារបស់គាត់ ឬក៏ការចងចាំរបស់លោកនោះ វាអាចខុសដែរ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ពាក្យពេចន៍អស់នេះសុទ្ធតែចេញពីឧត្តមគតិរបស់លោក ខៀវ សំផន ពីព្រោះគាត់បាននិយាយថ្លែងការណ៍ពិតប្រាកដមែនក្នុងពេលនោះ។ គាត់និយាយច្រើន ប៉ុន្តែខ្ញុំមិនបានចាំច្រើន។ ខ្ញុំចាំខ្លះ ភ្លេចខ្លះ ពីព្រោះគាត់និយាយហ្នឹង រយៈកាលប្រហែលជាជិតមួយម៉ោងដែរ បាទ ជិតមួយម៉ោងដែរ តែដល់ហើយខ្ញុំអត់បានចាំច្រើន ចាំខ្លះ ភ្លេចខ្លះ។ ហ្នឹងខ្ញុំចាំបានប៉ុណ្ណឹង។

**ស៖** កាលពីម្សិលមិញ លោកបានលើកឡើងថា គាត់និយាយតែប្រហែលជា៣០នាទីនាទីទេ មិនមែន<>មួយម៉ោងអ៊ីចឹងទេ ព្រោះថា គាត់រវល់ គាត់ប្រញាប់។ គាត់ប្រញាប់ដឹកនាំពួកលោកទាំងអស់គ្នាហ្នឹងទៅស្ថានីយរថភ្លើង។ អ៊ីចឹងខ្ញុំសូមបញ្ជាក់ សួរបញ្ជាក់លោកមួយសាទៀត តើប្រហែលកន្លះម៉ោង ឬក៏<>មួយម៉ោង?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយតប! អញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១០:១២:៣០]

**លោកស្រី ទី ស្រ៊ីនណា៖**

ខ្ញុំសូមធ្វើការកត់សម្គាល់ថា មុននឹងបន្តិច បើខ្ញុំស្តាប់ជាភាសាខ្មែរទៅ ដើមបណ្តឹងបានឆ្លើយថា លោក ខៀវ សំផន និយាយជិតមួយម៉ោង មិនមែនជាងមួយម៉ោងទេ ប្រហែលជាមានការភាន់ច្រឡំជាមួយនឹងភាសាបរទេសក៏មិនដឹង។ នេះសូមជូនជាព័ត៌មាន។ សូមអរគុណ។

01391849



**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឥឡូវ ខ្ញុំសួរលោកម្ដងទៀតឲ្យត្រូវ<នឹងឯកសារភាសារខ្មែរ។> <ដូច្នេះ គាត់និយាយប្រហែល>ជិតមួយម៉ោង <នេះផ្ទុយពីអ្វីដែលលោកបាននិយាយថា>កន្លះម៉ោង<កាលពីម្សិលមិញ>?

[១០:១៣:១៣]

**2-TCCP-1063៖**

**ឆ៖** បាទ ខ្ញុំសុំជម្រាបលោកមេធាវី ខ្ញុំនិយាយអំមិញ មិនមែនថានិយាយជាងមួយម៉ោងទេ ខ្ញុំថាគាត់និយាយជិតមួយម៉ោង មិនបានមួយម៉ោងទេ ជិតមួយម៉ោង ប៉ុន្តែលោកស្ដាប់មិនបាន លោកថាជាងមួយម៉ោង បាទសុំទោស។

**ស៖** សំណួរខ្ញុំអម្បាញ់មិញហ្នឹង ទោះបីថាជិតមួយម៉ោង ឬក៏ប្រហាក់ប្រហែលមួយម៉ោងក៏ដោយ <វាមិនមែនជាបញ្ហានោះទេ។> ខ្ញុំដឹងថាលោកនិយាយអ៊ីចឹង ក៏ប៉ុន្តែម្សិលមិញៗ លោកនិយាយថាកន្លះម៉ោងទេ។ អ៊ីចឹងហើយ បានខ្ញុំចង់សួរលោក បើតាមការចងចាំរបស់លោកនៅថ្ងៃនេះផ្ទាល់ តើវាកន្លះម៉ោងទេឬក៏ជិតមួយម៉ោង?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមបញ្ជាក់ សូមផ្ដល់លេខយោងនៃឯកសារដែលថា មានរយៈពេលរហូតដល់៣០នាទីនោះផង <ពីព្រោះប្រហែលជាមានកំហុសខាងការបកប្រែផងដែរ> ដើម្បីធ្វើម៉េចកុំឲ្យមានការច្របូកច្របល់តទៅទៀត។

[១០:១៤:១៨]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំនឹងសុំឲ្យក្រុមការងាររបស់ខ្ញុំរក<ឯកសារយោងពីប្រតិចារឹកនេះ>។ សូមឲ្យគាត់រកផ្នែកដែលពាក់ព័ន្ធនឹងចំនួន ដែលនាទីយោងនេះ។ ខ្ញុំនិយាយនេះ ដោយ<ផ្អែកលើ>ការកត់ត្រា<របស់ខ្ញុំ។>

**<លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖>**

<ខ្ញុំមានឯកសារហ្នឹងហើយ។>

**<កញ្ញា អង់តា ហ្គីសសេ៖>**

<ខ្ញុំគិត>ថា នៅម៉ោង ១១:៥៣នាទី <ហើយចៅក្រម ក្លូឌា ហ្វេនស៍ កំពុងតែសួររកឯកសារនេះ។>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**<លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖>**

<នៅម៉ោង ១៥:៥២ នាទី ឮគាត់និយាយថា “ជាងកន្លះម៉ោង”។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សុំឱ្យចាំមួយភ្លែត។ សូមលោកស្រីនិយាយម្តងទៀត ដោយសារថាមិនមានការបកប្រែ ដែលខ្ញុំអាចស្តាប់បានទេ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

<ខ្ញុំមាន>ប្រតិចារឹកជាភាសាបារាំង<។ ម្សិលមិញនៅ> ម៉ោង ១៥:៥២:<៤៣វិនាទី> គាត់និយាយថា ខៀវ សំផន បាននិយាយជាងកន្លះម៉ោង ប្រហែលជាគាត់ប្រញាប់ទៅកន្លែងផ្សេងហើយបាននិយាយខ្លី។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំអត់<មានពេល>អានប្រតិចារឹកជាភាសាបារាំងទេ <ប៉ុន្តែ>ខ្ញុំអានជាភាសាអង់គ្លេស <ពិតជាអ៊ីចឹងមែន>។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងសំណួរខ្ញុំថា តើអង្កាល់នោះ លោក ខៀវ សំផន គាត់និយាយជិតមួយម៉ោង ឬក៏ជិតកន្លះម៉ោងទេ?

ខ្ញុំឃើញថា លោកស្រីចៅក្រម ហ្វេនស៍ គាត់ញីក្បាល <តើ>មានបញ្ហាអីដែរ <ខ្ញុំអាចជួយបានទេ>?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើមានអ្វីខុសគ្នា<រវាង>រយៈពេល<ច្រើនជាង>កន្លះម៉ោង <ហើយនិង>តិចជាងមួយម៉ោង?<>ឬក៏ថា ខ្ញុំស្តាប់ហ្នឹងវាច្រឡំមិនបានច្បាស់លាស់។ វាខុសគ្នាយ៉ាងម៉េចរយៈពេលអ៊ីចឹង?

[១០:១៦:១១]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំចង់ដឹង ចង់ទទួលព័ត៌មាន<។ ខ្ញុំជឿជាក់ថា> យើងនៅចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី <ដែល>លើកឡើងពីសុន្ទរកថាលោក ខៀវ សំផន ជាលើកទី១ នៅឆ្នាំ២០១៥<>។ អ៊ីចឹង ខ្ញុំគិតថាជារឿងធម្មតាទេ <ក្នុងតួនាទី>ខ្ញុំជាមេធាវី<ការពារក្តី ខៀវ សំផន> ខ្ញុំត្រូវតែស្វែងយល់អំពីព័ត៌មាន

លម្អិត អំពីអ្វីដែលគាត់បានលើកឡើងពីភាពផ្ទុយគ្នា ដែលអង្គជំនុំជម្រះត្រូវគិត ព្រោះ<ខ្ញុំយល់>ថា <យើងមានភាពផ្ទុយគ្នានៅពេលដែល>ទាញការសន្និដ្ឋាន<នៅពេលខាងមុខ ប៉ុន្តែក្នុងករណីណាក៏ដោយ > ខ្ញុំជាមេធាវី<ខ្ញុំគួរតែ>ស្វែងយល់អំពីរបៀបដែលគាត់រៀបរាប់រឿងរ៉ាវពីកាលសម័យនោះ។

លោកប្រធាន ខ្ញុំជិតចប់អស់ហើយ ខ្ញុំប្រហែលជា៥នាទីទៀតចប់ហើយ ប្រសិនជាលោកចង់ឲ្យយើងខ្ញុំសម្រាកឥឡូវក៏បានដែរ ឬក៏ -- ខ្ញុំឃើញថា លោកប្រធានឲ្យខ្ញុំបន្តឲ្យដល់ចប់។

[១០:១៧:០៦]

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកនៅចាំដែរឬទេ កាលពីម្សិលមិញនេះ លោកបាននិយាយថា ខៀវ សំផន បាននិយាយ<ដោយ>ប្រើមីក្រូ <គឺពាក្យជាភាសារបារាំង ពោលគឺជាមីក្រូអត់ខ្សែធំមួយ> តើគាត់និយាយកន្លះម៉ោង <ច្រើនជាកន្លះម៉ោង> ឬក៏មួយម៉ោង<ដោយប្រើមីក្រូ?>

**2-TCCP-1063៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ពេលនោះ ខ្ញុំបាននិយាយថា គាត់ប្រើមីក្រូហ្នឹង។ បាទ ហ្នឹងពីម្សិលមិញ។ មីក្រូនេះ គឺថាមេក្រូដាក់ថ្មៗ។ ខ្ញុំសូមជម្រាបលោកប្រធានអ៊ីចឹង។

**ស៖** លោកក៏បានលើកឡើងផងដែរថា នៅពេលដែលលោក ខៀវ សំផន ថ្លែងសុន្ទរកថា ហ្នឹង គឺលោកនៅក្នុងផ្សារ ហើយខ្ញុំអត់សួរយល់ច្បាស់លាស់ទេ ថាតើពេលនោះ លោកមានមនុស្សប៉ុន្មាននាក់នៅជុំវិញលោក។ <ខ្ញុំជឿជាក់ថា លោកបាននិយាយថា លោកត្រូវបានគេប្រាប់ឲ្យ>តម្រង់ជួរ<។ តើលោក>ឈរតម្រង់ជួរឬក៏មានកន្លែងណាមួយនៅក្នុងផ្សារហ្នឹង<ដែលអាច>ប្រមូលផ្ដុំគ្នាអង្គុយ<បាន>?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន កន្លែងពេលនោះ គឺថាមិនមែនអង្គុយទេ យើងឈរតម្រង់ជួរ។ ប្រជាជនឈរតម្រង់ជួរ ឈរតម្រង់ជួរក្នុងផ្សារហ្នឹង។

**ស៖** តាមកំណត់ត្រារបស់ខ្ញុំ <ព្រមទាំងអ្វីដែលខ្ញុំចាំកាលពី>ម្សិលមិញហ្នឹង គឺថាលោកនៅចម្ងាយ២០ម៉ែត្រពីគាត់ ហើយអ៊ីចឹងខ្ញុំសួរលោកថា ពេលដែលលោក ខៀវ សំផន ថ្លែងសុន្ទរកថាហ្នឹង គឺលោកនៅចម្ងាយ២០ម៉ែត្រពីរគាត់ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ--

[១០:១៩:៣២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ដោយសារតែយើងមានបញ្ហាជាមួយនឹងឯកសារយោង តើ>លោកស្រី<អាច>ផ្តល់ឯកសារយោងនៃប្រតិចារឹក ដែល<វាផ្ទុយគ្នាទៅនឹងការយោងនៅក្នុងកំណត់ត្រារបស់លោកស្រី? ជាក់ស្តែងយើងមានបញ្ហាខាងផ្នែកការបកប្រែ។>

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំនឹងសូមឲ្យក្រុមការងាររបស់ខ្ញុំមកផ្តល់លេខយោងហ្នឹង ហើយសហភាតារបស់ខ្ញុំ<ដែលនិយាយជាភាសារខ្មែរ> គាត់បញ្ជាក់ខ្ញុំហើយថា ម្សិលមិញគាត់បាននិយាយថា នៅចម្ងាយ២០ម៉ែត្រ ពីលោក ខៀវ សំផន មែន។ ប៉ុន្តែអត់អីទេ យើងនឹងផ្តល់លេខយោងឲ្យ<នៅពេលក្រោយ>។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

តើលោក នៅពេលដែលលោក ខៀវ សំផន ថ្លែងសុន្ទរកថាហ្នឹង លោកអាចជម្រាបជូនតុលាការបានទេ លោកនៅចម្ងាយប៉ុន្មានម៉ែត្រពីគាត់ដែរ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ម្សិលមិញ ខ្ញុំបានជម្រាបជូនមួយសាហើយ គឺថាខ្ញុំនៅចម្ងាយពីគាត់ប្រហែលជា២០ម៉ែត្រ។ បាទ ខ្ញុំបានជម្រាបជូនម្តងហើយ។

**ស៖** ហើយនៅ<ពី>មុខលោកហ្នឹង<តើមាន>មានគេឈរនៅមុខ<លោក>ដែរ<ឬទេ?ពីព្រោះថាបើតាមខ្ញុំស្តាប់យល់ លោកមិនឈរនៅជួរទី១ទេ>។ លោកស្រីចៅក្រម ហ្វេនស៍ ម្សិលមិញ គឺគាត់និយាយនៅម៉ោង១៥:១៩នាទី។ សំណួរខ្ញុំអម្បាញ់មិញប្រហែលជាមិនសូវច្បាស់ ឥឡូវ ខ្ញុំសួរម្តងទៀត។ នៅពេលដែលលោកស្តាប់សុន្ទរកថាលោក ខៀវ សំផន ដែលថាលោក ខៀវ សំផន គាត់និយាយមីក្រូ ហើយមានមនុស្សនៅចន្លោះលោក ខៀវ សំផន ហើយនិងរូបលោកផ្ទាល់ ព្រោះថាលោកមិននៅមុខគេទេ មិននៅជួរមុខគេទេ។ តើអ៊ីចឹងមែនទេ?

[១០:២១:២២]

**ឆ៖** បាទ ខ្ញុំអត់បាននៅជួរមុខគេទេ ព្រោះមានគេនៅមុខខ្ញុំទៀត។

**ស៖** ខ្ញុំសូមការបំភ្លឺមួយទៀត។ ម្សិលមិញនោះលោកនិយាយថា មានមនុស្សច្រើនណាស់ នៅផ្សារហ្នឹង ពេលដែលលោក ខៀវ សំផន ថ្លែងសុន្ទរកថា។ តើលោកអាចធ្វើការប៉ាន់ប្រមាណពីចំនួនមនុស្សនៅក្នុងផ្សារហ្នឹងទេ? ខ្ញុំដឹងថាមានអ្នកជម្លៀសច្រើនហើយ ក៏ប៉ុន្តែខ្ញុំសួរថា ឥឡូវពេលដែលគាត់ថ្លែងសុន្ទរកថានៅក្នុងផ្សារហ្នឹង មានអ្នកនៅក្នុងផ្សារហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ព្រោះពេលនោះ ខ្ញុំមិនបានរៀបរាប់មិនបានអីទេ គ្រាន់

ដឹងថាមនុស្សច្រើន។ មិនដឹងប៉ុន្មាន ព្រោះមនុស្សហ្នឹងច្រើនពេក។ ខ្ញុំអត់បានរាប់ចំនួនទេ។ យើងស្មានអត់ត្រូវ។

**ស៖** ខ្ញុំភ្លេចសួរចំណុចមួយទៀត។ សូមបំភ្លឺ គឺឯកសារ E3/10670, ERN ជាភាសាអង់គ្លេស <01190623>, ជាភាសាខ្មែរ <01118429>។ នៅពេលដែលលោកនិយាយ<អំពីអ្នកដែលមកក្នុងពេលដូចគ្នា ជាមួយនឹងលោក ខៀវ សំផន> សូមដកស្រង់ជាអង់គ្លេស៖ "មេដឹកនាំខ្មែរក្រហម <ខៀវ សំផន> និងក្រុមរបស់គាត់ ដែលភាគច្រើន ខ្ញុំមិនស្គាល់ពួកគាត់ទេ គឺថាបានជិះឡាន...។ល។" បញ្ចប់ការដកស្រង់។

[១០:២៣:១៩]

នៅពេលដែលលោកនិយាយថា "អ្នកភាគច្រើន ខ្ញុំអត់ស្គាល់ទេ"។ តើលោកមានស្គាល់អ្នកដែលជិះឡានមកហ្នឹង មានស្គាល់ខ្លះទេ។ បើលោកនិយាយថា "ភាគច្រើន ខ្ញុំមិនស្គាល់ទេ"។ អ៊ីចឹងបានន័យថា លោកស្គាល់ខ្លះ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំអត់បានស្គាល់ផង។ ស្គាល់លោក ខៀវ សំផន ហ្នឹង ដោយសារបងប្អូនដែលគេអ្នកស្គាល់ ធ្លាប់ស្គាល់ ហើយម្យ៉ាងទៀត ខ្ញុំធ្លាប់ឃើញក្នុងខ្សែភាពយន្ត។ បាទ ដល់ហើយខ្ញុំក៏ថា គាត់ហ្នឹងតែម្តង។ ពីព្រោះរូបគាត់ ដល់ឃើញផ្ទាល់ អ៊ីចឹងមែន។ បាទ ហ្នឹងខ្ញុំសូមជម្រាបលោកប្រធានអ៊ីចឹងតែក្រៅពីគាត់ទៀត ខ្ញុំអត់ស្គាល់។

**ស៖** តើលោកមានចាំដែរឬទេ ថាតើលោកបានឃើញ បានឃើញមើលខ្សែភាពយន្តហ្នឹង នៅឆ្នាំណាដែរ?

**ឆ៖** បាទ ខ្ញុំមើលខ្សែភាពយន្តនៅឆ្នាំ៧៥។ បាទ ពេលដែលគេជម្លៀសខ្ញុំ -- អ៊ំ! ពេលដែលខ្ញុំមកពីពោធិ៍សាត់វិញ។ មកដល់ស្រុកភូមិហ្នឹង គឺថាកងទ័ពវៀតណាម -- អ៊ំ! កងទ័ពខាងសម្តេច ហ៊ុន សែន គាត់រំដោះបាន គាត់យកទៅបញ្ចាំងឲ្យប្រជាពលរដ្ឋមើលនៅតាមភូមិ។

[១០:២៤:៥៦]

**ស៖** អ៊ីចឹង លោកចង់និយាយថា លោកបានមើលខ្សែភាពយន្តហ្នឹង ឃើញមានរូបលោក ខៀវ សំផន។ បានន័យថា ក្រោយរបបកម្ពុជាប្រជាធិបតេយ្យហើយ ឬក៏យ៉ាងម៉េច? ឃើញក្រោយពេលដែលអង្គាល់លោកជួបគាត់នៅផ្សារហ្នឹងណា ឬក៏យ៉ាងណា?

**ឆ៖** បាទ សុំទោសខ្ញុំច្រឡំបន្តិចត្រង់ហ្នឹងអំមិញបាទ។ តាមពិតខ្ញុំឃើញគេមុន តែមិនមែន

ឃើញក្រោយរំដោះ៧៩ទេ បាទៗខ្ញុំសុំទោស។ បាទ ពីព្រោះអំមិញខ្ញុំច្រឡំភាសាត្រង់ហ្នឹងដែរ ដូចអំមិញឆ្លើយរឿងថា ជិតមួយម៉ោង ឬកន្លះម៉ោងអ៊ីចឹងដែរបាទ។

**ស៖** អ្នកណាគេបញ្ចាំងខ្សែភាពយន្តហ្នឹង ហើយគេបញ្ចាំងហ្នឹងក្នុងឱកាសអីដែរ?

**ឆ៖** សូមជម្រាបឲ្យច្បាស់លាស់។ ខ្ញុំខ្សែភាពយន្តនេះ ខ្ញុំបានមើលតាំងពីឆ្នាំកាលរបបគាត់នៅកាន់កាប់បាទ កាលរបបកម្ពុជាប្រជាធិបតេយ្យ និងកាលនោះគឺមានកម្លាំងកងទ័ពរណស្សិបាទ និងគាត់យកទៅបញ្ចាំង។ យកទៅបញ្ចាំងតាមសហករណ៍ ដល់ហើយខ្ញុំបានមើលតាំងពីហ្នឹងមក។ ដូចអំមិញខ្ញុំនិយាយថាក្រោយរំដោះ៧៩ហ្នឹងខ្ញុំច្រឡំទេបាទ ខ្ញុំច្រឡំទេ។ តាមពិត ខ្ញុំបានមើលតាំងពីសម័យរបបលន់នល់ -- អ៎នែ! របបប៉ុល ពត។ បាទ ពីព្រោះកាលនោះគេបញ្ចាំងពីកសិករធ្វើស្រែ ជីកព្រែក ជីកប្រឡាយ និងគេយកឯកសារនេះទៅបញ្ចាំងឲ្យមើល។ ហើយម្យ៉ាងទៀតមានថ្នាក់ដឹកនាំ បាទថ្នាក់ដឹកនាំជាន់ខ្ពស់ដើម្បីចូលរួមក្នុងពេលនោះ។ បាទដល់អ៊ីចឹងខ្ញុំទើបនេះទៅ ខ្ញុំបាននឹកឃើញថា អូ៎! មិនមែនទេខ្ញុំច្រឡំទេ ខ្ញុំមានយោបល់អំមិញខ្ញុំសុំទោស បាទ។

[១០:២៧:១៨]

**ស៖** ពេលដែលលោកនិយាយថាខ្សែភាពយន្តហ្នឹងនិយាយអំពីអ្នកដឹកនាំហ្នឹង អ៊ីចឹងខ្ញុំចង់សួរលោកថា គេមានបញ្ជាក់អំពីតួនាទីអ្នកដឹកនាំទេនៅក្នុងខ្សែភាពយន្តហ្នឹង?

**ឆ៖** ខ្សែភាពយន្តនោះ គឺថាជួនឮជួនមិនឮ ដល់ហើយយើងស្តាប់អត់បាន បាទ យើងស្តាប់អត់បានភាសាហ្នឹង។ ម្ល៉ោះហើយខ្ញុំមិនបានចាំទេ មិនបានចាំទេ ពីព្រោះថ្នាក់ដឹកនាំជំនាន់នោះគឺថាប្រែប្រួលតិចអ្នកនេះ តិចអ្នកនោះ ដល់អ៊ីចឹងទៅយើងមិនបានចាំពីភារកិច្ចរបស់គាត់ក្នុងសម័យនោះបាទ។ យើងប្រជាពលរដ្ឋយើងមិនសូវបានចាប់អារម្មណ៍ពីរឿងហ្នឹងភ័យខ្លាចគេសម្លាប់ រងគ្រោះដោយសារគេបង្អត់អាហារ។ មួយទៀត ភ័យខ្លាចគេយកទៅសម្លាប់មិនដឹងថ្ងៃណា ដល់ហើយមិនសូវបានចាប់អារម្មណ៍ពីរឿងអ៊ីចឹងៗទេបាទ។ សូមជម្រាបលោកប្រធានប៉ុណ្ណឹង។

**ស៖** លោកប្រធានសំណួរចុងក្រោយរបស់ខ្ញុំ ហើយខ្ញុំសូមអភ័យទោសដែលខ្ញុំសួរវែង ហើយយូរជាងដែលខ្ញុំគ្រោងទុក។ ខ្ញុំយល់មិនសូវច្បាស់ថា ខ្ញុំសួរលោកណា៎ តើដោយចិត្តឯងលោកទៅទាក់ទងមេធាវីរបស់លោកដើម្បីផ្តល់ព័ត៌មានបន្ថែមឲ្យអំពីលោក ខៀវ សំផន ទៅមេធាវីរបស់លោកនៅឆ្នាំ <២០១៤> ឬក៏២០១៥ ឬក៏មិនមែនអ៊ីចឹងទេ<?> សូមលោកជួយបញ្ជាក់បន្តិច?

[១០:២៩:១១]

**ឆ៖** បាទ កាលនោះខ្ញុំ ដូចថាមានខាងអង្គការឲ្យខ្ញុំរកមេធាវី បាទឲ្យខ្ញុំរកមេធាវី ដល់រកមេធាវី ក៏ខ្ញុំបានទំនាក់ទំនងជាមួយគាត់ ដើម្បីឲ្យគាត់ជួយបំពេញឯកសារបន្ថែម។

**ស៖** លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ប៉ុន្តែលោកមេធាវី គង់ សំអុន គាត់ថាគាត់មានសំណួរមួយ<ចំនួន>ចង់សួរដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរអង្គជំនុំជម្រះ ហើយនិងលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំចង់សួរបញ្ជាក់លោក ទាក់ទងទៅនឹងវត្ថុមានរបស់លោកនៅផ្សារច្បារអំពៅ នៅពេលដែលលោកថាលោកទទួលសម្ភារៈមួយចំនួនពីលោក ខៀវ សំផន។ ខ្ញុំចង់សួរលោកថា តើលោកនៅពេលដែលឈរទទួលហ្នឹង មានប៉ុន្មានជួរដែរ?

[១០:៣០:២០]

**2-TCCP-1063៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ពេលឈរនោះ ខ្ញុំមិនបានរាប់ជួរ ពីព្រោះវាច្រើន បាទមិនដឹងប៉ុន្មានជួរទេ ខ្ញុំអត់បានចាំទេ បាទ។

**ស៖** លោកអាចសរុបបានទេថា វាច្រើនជាង១០០ជួរ ឬវាតិចជាង១០០ជួរ?

**ឆ៖** បាទៗ បើតាមខ្ញុំស្មានមើលទៅ បែបមិនលើពី១០០ទេ បែបក្រោម១០០។

**ស៖** ក្រោមតិចតួច ឬក៏ក្រោមរហូតដល់ពាក់កណ្តាល?

**ឆ៖** បាទ ក្រោមតិចទេ មិនមែនក្រោមច្រើនទេ។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ពីម្សិលមិញថា លោកអាចស្ថិតនៅក្នុងជួរមួយដែលមានក្នុងចន្លោះពី២០នាក់ បានន័យថា លោកមានគេនៅខាងមុខ២០នាក់ហើយ លោកមិនមែនជាអ្នកឈរជួរមុខទេ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវអ៊ីចឹងមែន ព្រោះនេះការប៉ាន់ស្មាន បាទ ការប៉ាន់ស្មាន យើងមិនបានរាប់ថា

ចំនួនបួនដប់ម្ភៃនាក់ទេ តែខ្ញុំប៉ាន់ស្មានប្រហែលជា២០នាក់នៅមុខខ្ញុំបាទ ពីព្រោះពេលនោះ គ្មាននរណាបានទៅរាប់ជួរមួយៗថា កំណត់ពីមុខមកទល់នឹងខ្ញុំថា ប៉ុន្មាននាក់ៗ គ្មាននរណាបានរាប់ដូចលោកសួរអ៊ីចឹងទេ។ បាទ សូមជម្រាបលោកប្រធាន។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា ក្នុងចំណោមជួរដែលលោកឈរហ្នឹង លោកឈរចំកណ្ដាល ចំកៀន ឬក៏នៅក្នុងទីតាំងណា លោកអាចបញ្ជាក់បានទេ?

[១០:៣២:៣១]

**ឆ៖** បាទ សូមជម្រាបលោកប្រធាន ដល់សួរអ៊ីចឹង ខ្ញុំពិបាកឆ្លើយ ពិបាកកំណត់។ បើខ្ញុំឆ្លើយថាកំណត់ថា ឃ្លាតពីមុខមក១៥ ក្រែងលោខុសសម្ដីដូចលោកប្រធានសួរអំមិញថា កន្លះម៉ោង ឬជិតមួយម៉ោង ជាងមួយម៉ោង។ បាទ ក្នុងនេះហើយបានជាខ្ញុំថា ខ្ញុំមិនអាចកំណត់បានទេ។ បាទ សូមជម្រាបលោកប្រធានប៉ុណ្ណេះ។

**ស៖** បាទ លោកអាចធ្វើការប្រៀបធៀបទៅនឹងខាងឆ្វេងដៃ និងខាងស្ដាំដៃ លោកអាចគិតថាលោកស្ថិតនៅចំណុចកណ្ដាល ឬក៏នៅផ្នែកខាងស្ដាំច្រើនជាង នៅខាងផ្នែកខាងឆ្វេងច្រើនជាងនៅក្នុងចំនួនជួរដែលលោកថា ជិត១០០ជួរនោះ?

**ឆ៖** បាទ ខ្ញុំនៅឈរផ្នែកខាងស្ដាំបាទ។ ផ្នែកខាងស្ដាំហ្នឹង ខ្ញុំរាងចុងគេបាទ មិនជាចុងទេ តែចុងគ្រាន់ថាយើងស្ទើងជាងគេ បាទ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ថា ជួរដែលនៅខាងស្ដាំលោកទៀត ដែលលោកថាស្ទើងជាងហ្នឹង ប្រហែលជាប៉ុន្មានជួរទៀត បានៗមកដល់លោក?

**ឆ៖** បាទ ប្រហែលជាជាងដប់ជួរ បានដល់មកខ្ញុំ បាទ ហ្នឹងពីឆ្វេងទៅស្ដាំ។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ពីម្សិលមិញ លោកថា លោក ខៀវ សំផន បានចែកប្រជាពលរដ្ឋហ្នឹងក្នុងនាមជាតំណាងទេ។ លោកថា លោក ខៀវ សំផន ចែកប្រហែលជា១៤នាក់ទៅ២០នាក់ ហើយក៏ចេញទៅ។ តើលោកចាំថា នេះជាសម្ដីរបស់លោកដែរទេ?

[១០:៣៤:៤២]

**ឆ៖** បាទ ពាក្យនេះ គឺថាខ្ញុំបាននិយាយអ៊ីចឹងមែន ម្សិលមិញ បាទ។

**ស៖** បាទ សូមអរគុណ។ ហើយលោកបានបញ្ជាក់ទៀតថា ក្នុងចំណោមប្រហែល២០នាក់ ដែលបានទទួលអីវ៉ាន់ពីលោក ខៀវ សំផន ហ្នឹង គឺលោកម្នាក់ដែរជាអ្នកបានទទួល។ លោកចាំសម្ដី

លោកអ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ព្រោះខ្ញុំបានទទួលមែន បាទ ខ្ញុំបានទទួលមែន។

**ស៖** បាទ សូមអរគុណ។ ពេលដែលចែកហ្នឹង គឺចែកនៅក្នុងជួរអ៊ីចឹងមែនទេ លោកអាចបញ្ជាក់ផង?

**ឆ៖** បាទ ចែកហ្នឹង គឺថាចែក គេហៅចេញមកក្រៅជួរបាទ ទទួលចៃដន្យទៅគេហៅចំដល់ខ្ញុំទៅ ក៏បានចេញមកទៅ ហ្នឹងគេហៅអ៊ីចឹង។

**ស៖** គេហៅយ៉ាងម៉េច លោកអាចបញ្ជាក់បានទេ មានបញ្ជីឈ្មោះហៅ ឬក៏ស្រែកហៅតែម្ដង?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់! កុំអាលទាន់ឆ្លើយ នេះក្បាលមីក្រូហ្វូនវាអត់ទាន់ប្រតិបត្តិការ។

**2-TCCP-1063៖**

**ឆ៖** បាទ សុំទោស។ បាទ ក្នុងពេលគេចែកនោះ គឺថា គេហៅ ក្រុមការងាររបស់គាត់ដើរតាមជួរ មួយជួរយកមួយ មួយជួរយកពីរ អ្នកនៅមុខៗហ្នឹង តែមិន -- ខ្លះមុខ ខ្លះក្នុង បាទ ក្នុងពេលហ្នឹង។ តែដល់ខ្ញុំ វាត្រូវចំទៅ គេហៅចូលទៅ នៅក្នុងពេលហ្នឹង។ ហើយខ្ញុំក៏មិនបានចាំគ្រប់គ្រង ជ្រុងជ្រោយដូចលោកសួរអ៊ីចឹងដែរ ព្រោះពេលនោះ យើងមិនបានចាប់អារម្មណ៍ពីបញ្ហាថា ពេលទទួលអំណោយ តើមានប៉ុន្មាននាក់ៗ ដូចលោកសួរអ៊ីចឹង គឺថាអត់មានអារម្មណ៍អ៊ីចឹងទេ។ បាទ ខ្ញុំសូមជម្រាបលោកប្រធានអ៊ីចឹង។ បើសួរអ៊ីចឹង ខ្ញុំក៏វល់ដែរ។

[១០:៣៦:៥៤]

**ស៖** បាទ បញ្ហាដែលខ្ញុំមានចម្ងល់នេះ គឺថា ដែលលោក ខៀវ សំផន តាមសក្ខីកម្មរបស់លោកថាចែកឱ្យមនុស្សតែ១៤នាក់ ឬទៅ២០នាក់ទេ ហើយលោកឈរនៅជួរទី២០ ក្នុងជួររបស់លោក ហើយមានច្រើនជួរទៀត។ អ៊ីចឹងហេតុអីបានជាក្នុងចំណោមតែ១៤នាក់ ទៅ ២០នាក់នេះ បែរជាទៅដល់លោកដែលជាអ្នកឈរចុងក្រោយនោះបានមកទទួលដែរ។ នេះជាចំណុចដែលៗធ្វើឱ្យខ្ញុំឆ្ងល់ ហើយខ្ញុំជឿថាអង្គជំនុំជម្រះអាចឆ្ងល់លើចំណុចនេះដែរ។ លោកអាចបញ្ជាក់យ៉ាងម៉េច ដែលថា លោកថាមានក្រុមការងាររបស់គាត់ហ្នឹងមកហៅលោកផ្ទាល់ហ្នឹង ហៅយ៉ាងម៉េច បានជាទៅបានដល់លោកអ្នកដែលនៅខាងក្រោយ មកទទួលយកសម្ភារៈនៅខាងមុខនេះ?

**ឆ៖** បាទ កាលនោះ ខ្ញុំអត់បានដឹងអ៊ីចឹងដែរ ព្រោះយើងវាអត់បានចាប់អារម្មណ៍ ស្រាប់គេមក

ហៅទៅ យើងទៅ។ ខ្ញុំអត់បានដឹងអីចឹង មិនដឹងគម្រោងគេរបៀបម៉េច ខ្ញុំអត់ដឹង។

[១០:៣៨:០៩]

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាចុងក្រោយនេះ គឺលោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោក វេទនា ស្ថានភាពលំបាក និងស្ថានភាពព្យសនកម្មរបស់លោកក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលលោកបានអះអាងថា លោកបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

សូមអញ្ជើញ!

**2-TCCP-1063៖**

បាទ ខ្ញុំសូមជម្រាបលោកប្រធាន បាទ ខ្ញុំ ដូច្នេះខ្ញុំបាទ សូមជម្រាបជូនពីបញ្ហាទុក្ខសោកលើរូបកាយរបស់ខ្ញុំ។ តាំងពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីស្វាយរៀង។ ចេញពីស្វាយរៀង ពេលនោះ កងទ័ពខ្មែរក្រហមចូលដល់ទីក្រុងស្វាយរៀង បានដេញ បានជំរុញប្រជាពលរដ្ឋឱ្យចេញពីទីក្រុង។ ដូចរូបខ្ញុំផ្ទាល់គឺថា កងទ័ពវៀតណាមចូលដល់ មកដល់ គេដេញគេស្រែក គេថា បងប្អូនពុកម៉ែចេញឱ្យឆាប់ៗ។ អ្នកណាមិនចេញគេត្រូវបាញ់ចោល។ ទទួលចែងឡៗចេញដំណើរមកគ្រាន់តែចេញពីភូមិមក ឡើងដល់លើថ្នល់ ស្រាប់តែមានតាមួយគាត់ចាស់ គាត់ដើរមិនរួច តតែលតតោលដល់ហើយគេស្រែក ស្រែកថា លឿនៗៗ។ តានោះគាត់ចាស់ហើយ គាត់ដើរមិនរួច ហើយវាថាតាឯងធ្វើអីចឹងបាញ់ចោលឥឡូវ។ មិនត្រឹមតែស្រែក គេបាញ់បណ្ដោយ ដួលនៅមុខខ្ញុំៗ។ បាទ ដួលនៅមុខខ្ញុំហ្នឹង ខ្ញុំក៏ធ្វើដំណើររហូតមកបាទ។ ពេលនោះហើយ ដែលខ្ញុំមានការតក់ស្លុត ភ័យរន្ធត់ ដោយសារឃើញគេបាញ់សម្លាប់នៅខាងមុខ។ ពេលនោះ គឺថាខ្ញុំរួមទាំងប្រជាជនទាំងអស់ មិនខុសគ្នាទេ មិនខុសគ្នាពីខ្ញុំ ក្នុងចេញក្នុងមួយខេត្តហ្នឹង។ គឺថាគ្មានយកបានទ្រព្យសម្បត្តិអ្វីទេ គឺថាយកបានតែខោអាវបន្តិចបន្តួច ខោអាវបន្តិច ខោអាវ អង្ករបន្តិចបន្តួចទៅ បើគេប្រថំ គេជំរុញហើយ ហើយគេប្រាប់ទៀត គេថាពុកម៉ែបងប្អូនចេញតែពីរបីថ្ងៃទេ អង្គការឱ្យចូលមកនៅផ្ទះសម្បែងវិញហើយ កុំភ័យ មិនបាច់យកអីទៅច្រើនទេ មិនបាច់យកអីច្រើនទេ។ ដល់ហើយប្រជាពលរដ្ឋគាត់ក៏ភ័យ ទាំងគេ ទាំងខ្ញុំ ក៏ចេញដោយ

វណាត់វណែង។ រហូតដល់ហើយ ចេញមកដល់ភូមិតាដៃហ្នឹង គឺថា ខ្ញុំសម្រាក គេឲ្យសម្រាកនៅភូមិ បាទ សម្រាកនៅក្នុងភូមិតាដៃហ្នឹងអស់រយៈកាល១ខែ ស្រាប់តែគេដឹងថា បងខ្ញុំ បងប្រុសខ្ញុំហ្នឹងគាត់ធ្វើទាហាន ធ្វើទាហានលន់ នល់ គេក៏យកបងខ្ញុំហ្នឹងទៅរៀនសូត្រនៅវត្តគ្រួស។ ដល់ហើយតាមពិតគេមិនយកទៅរៀនសូត្រទេ គេយកទៅសម្លាប់ចោលតែម្តង។ បាត់ខ្លួនទល់នឹងអំមិញ។

[១០:៤១:៤៥]

ក្រោយមកទៀត ប្រហែលជាកន្លះខែទៀត គេមកយកឪពុកខ្ញុំ បាទឪពុកខ្ញុំហ្នឹង គេយកឪពុកខ្ញុំទៅ ទៅរៀនសូត្រនៅវត្តតាជ។ គេថា ឪពុកខ្ញុំហ្នឹងធ្វើកងស្វ័យត្រាណ បាទធ្វើកងស្វ័យត្រាណ តែតាមពិតឪពុកខ្ញុំជាកសិករ ប៉ុន្តែគ្រាន់ថា មេឃុំគេឲ្យអាវុធដើម្បីជួយការពារនៅសមរភូមិក្រោយ ហ្នឹងការពិតអ៊ីចឹងមែន ហើយគេឲ្យទៅរៀននៅវត្តតាដៃ។ បានកន្លះខែទៀត គេដឹងថា ខ្ញុំហ្នឹងធ្វើទាហានលន់ នល់ បាទ ធ្វើទាហានលន់នល់ តែតាមពិតខ្ញុំបានធ្វើទាហាន លន់ នល់ មែន។ ខ្ញុំបានធ្វើរយៈកាល៣ខែ ទទួលខ្ញុំត្រូវរបួស ក៏ខ្ញុំដេកពេទ្យជា ក៏ខ្ញុំចេញមកសម្រាកនៅផ្ទះ គេជំរុញឲ្យខ្ញុំចូលកងស្វ័យត្រាណទៀត។ ពីពេលមុនមក ខ្ញុំប្រាប់គេថា កងស្វ័យត្រាណ ដល់ក្រោយមកគេដឹងថា ខ្ញុំធ្វើទាហាន គេក៏យកខ្ញុំទៅរៀនសូត្រជាមួយឪពុកនៅវត្តតាដៃ។ ពេលទៅរៀនសូត្រនោះ ពេលនុំងបានខ្ញុំកាន់តែវេទនា បាយក៏ហូបមិនឆ្អែត គេប្រើដូចគោ ដូចក្របី ជីកព្រែក ជីកប្រឡាយ លើកភ្លឺស្រែ ត្រូវថ្ងៃណាគេចាត់កម្លាំងឲ្យទៅតាមភូមិ គេឲ្យយើងយករទេះទៅអូស ដឹកឧស យើងទឹមរទេះមួយពីរនាក់ហ្នឹង ធ្វើជាគោ។ ដឹកឧសពីក្នុងព្រៃមក មកដាក់រោងបាយ ហ្នឹងខ្ញុំជាក់ស្តែង។ អ៊ីចឹងបានថា ខ្ញុំទុក្ខសោកវេទនាខ្ញុំ វាអស្ចារ្យពេក ក្នុងពេលនោះ។ រហូតដល់ហើយឆ្នាំ១៩៧៦--

**ប្រធានអង្គជំនុំ៖**

ឈប់ៗ ផ្អាកសិនចុះ!

បាទ មានបញ្ហាអស់ -- ផ្លាស់ឌីសថ្មី បាទ អស់ឌីសថតសំឡេង។

[១១:៤៣:៥២]

*(សម្រាករយៈពេលខ្លី)*

បាទ អញ្ជើញបន្តទៀតណ៎ា! អំមិញចាប់ពី ១៩៧៦ ណ៎ះ!

**2-TCCP-1063៖**

បាទ អរគុណ។

បាទ នៅឆ្នាំ១៩៧៦ ខែមិថុនា អង្គការបានលើកទិសដៅ។ បាទ លើកទិសដៅមួយសា លើកទី១ ហ្នឹង ជម្លៀសប្រជាជនចេញពីខេត្តមួយសាទៀត។ ពេលជម្លៀសនោះ មានដោយរួមដោយទាំងគ្រួសារខ្ញុំ ៗ ឪពុកម្ដាយ បងប្រុស បងស្រី ប្អូនប្រុស ប្អូនស្រី គិតទៅវាគ្នាឪពុកមួយ ម្ដាយពីរ បងស្រីមួយ មានចំនួនប្រាំនាក់ បាទ ប្រាំនាក់ និងជម្លៀសឲ្យចេញពីភូមិតាដៃ ឃុំខ្ពស់ចំលង ស្រុកស្វាយជ្រំ ខេត្តស្វាយ-រៀង។ ដល់ចំណែកខ្ញុំ និងប្រពន្ធខ្ញុំ គេមិនឲ្យមកតាមទេ។ គេប្រាប់ថា ឯងមាន ប្អូនឯងមានគ្រួសារហើយ មិនបាច់ទៅតាមគាត់ទេ។ ហ្នឹង គេប្រាប់អ៊ីចឹង អង្គការប្រាប់អ៊ីចឹង។ ដល់ហើយ គេមិនឲ្យខ្ញុំមកទេ គេបញ្ជូនឪពុកម្ដាយខ្ញុំមកមុន បាទ មកព្រៃវែង។ មកព្រៃវែងហ្នឹង មកនៅស្រុកពាមជរ ខេត្តព្រៃវែង។ មានរួមចំណែកទាំងម្ដាយក្មេកខ្ញុំក៏បានគាត់មកដែរ។ ដល់រហូតដល់មក មកនេះ បើតាមខ្ញុំដឹង ពីអ្នកដែលរស់ប្រាប់ខ្ញុំទេ ខ្ញុំមិនបានឃើញផ្ទាល់ភ្នែកទេ បាទ។ មកដល់ហ្នឹងរយៈកាលពីរខែ ពីរខែគេស៊ើបដឹងថាបងស្រីខ្ញុំហ្នឹង ប្ដីគាត់ធ្វើជាទាហាន បាទ ធ្វើជាទាហាន ដល់ហើយ គេមកយកបងស្រីខ្ញុំទៅសម្លាប់ចោលនៅកោះដាច់។ ហ្នឹងតាមព័ត៌មានដែលគេប្រាប់ខ្ញុំ។ បាទ ហ្នឹងជាក់ស្ដែង។ ហើយរហូតបាត់ខ្លួនទល់អំមិញហ្នឹងទៅ។

[១០:៤៦:០៥]

ត្រឡប់ទៅវិញ ដល់ហើយ គាត់ក៏នៅហ្នឹង។ ខ្ញុំដល់ឆ្នាំ៧៧ ហ្នឹងរឿងគាត់មួយវគ្គ។ ៧៧ហ្នឹង ខ្ញុំត្រូវគេជម្លៀសវគ្គទី២ បាទ ជម្លៀសវគ្គទី២ហ្នឹង ចំនួនក្នុងមួយឃុំវាចូល៧០នាក់ ៧០គ្រួសារ បាទ គ្រាន់តែក្នុងភូមិតាដៃ វា២០គ្រួសារ ដើម្បីឲ្យទៅនៅពោធិ៍សាត់ បាត់ដំបង។ ពេលនោះហើយ ដែលខ្ញុំចេញពីផ្ទះមក ចេញពីផ្ទះមក គឺថាធ្វើដំណើរដោយថ្មើរជើង អត់ទាំងទ្រនាប់ជើងទៀត សម័យនោះ គ្មានពីណាមានទ្រនាប់ជើងទេ។ យើងដើរទទេ ចេញពីភូមិមក មកដល់ក្រោលគោ ចម្ងាយប្រហែលជា២៥គីឡូ ក្នុងមួយថ្ងៃដើរ បាទ។ មកដល់ហ្នឹងគឺថាគេឲ្យសម្រាកនៅហ្នឹងមួយយប់ហើយ។ សម្រាកៗនៅហ្នឹង គឺថាយប់នោះ ភ្លៀងទាល់ភ្លឺ គ្មានបានដេក បានពួនទេ ពីព្រោះអត់មានកន្លែងជ្រក។ ជ្រក នាំគ្នាជ្រកតាមសំយ៉ាបម៉ាស៊ីនកិនស្រូវ។ ដល់ហើយព្រឹកឡើងៗ គេឲ្យចេញដំណើរមកទៀត ឲ្យចេញដំណើរមកទៀតមកសម្រាកនៅភូមិត្របែកមួយយប់ទៀត បាទ។ សម្រាកនៅភូមិត្របែក គឺថាពេលចេញដំណើរមកហ្នឹង រែកតត្រិកតត្រាក់ ខោអាវម៉ាកំប៉ុកហ្នឹង ហើយនិងអង្ករ គេឲ្យបន្តិចបន្តួចទេ បាទ គេឲ្យមកបន្តិចបន្តួចដែរ អង្ករ ចេញពីសហករណ៍មកហ្នឹង។ ហើយយើងមកធ្វើដំណើរដល់ហ្នឹង ដេកហ្នឹងមួយយប់ទៀត ដល់កំពង់ត្របែក។ ព្រឹកឡើង អង្គការលើកទិសដៅថា ជំរុញពីកំពង់ត្របែកឲ្យដល់អ្នកលឿង។

ទោះបីយ៉ាងណាត្រូវឲ្យដល់អ្នកលឿង។ មកសម្រាកអ្នកលឿង៧យប់៧ថ្ងៃ។ ហ្នឹងគេប្រាប់អ៊ីចឹង។ ដល់មក គឺថាចេញពីនោះព្រឹកឡើង មកទៀត ធ្វើដំណើរដោយថ្មើរជើងទៀត។ មកដល់ហ្នឹងគឺថា សម្រាកនៅហ្នឹងបាន៧យប់៧ថ្ងៃ។ ទាល់ដល់គ្រប់ គេដឹកតាំងពីខ្ញុំមកដល់ ប៉ុន្តែគ្រាន់តែថា វាអត់ទាន់ខាងខ្ញុំ។

[១០:៤៨:១៦]

យើងនៅសម្រាកនេះ ដើម្បីរង់ចាំកាណូត កប៉ាល់ដឹកជញ្ជូនមកដាក់នៅភ្នំពេញនេះ។ អ៊ីចឹងបានខ្ញុំមកដល់អ្នកលឿង ដល់ថ្ងៃគ្រប់ទី៧ ខ្ញុំ យប់ថ្ងៃទី៦ហ្នឹង គេហៅឈ្មោះ បាទហៅឈ្មោះតាមគ្រួសារឲ្យឡើងកប៉ាល់ទាំងយប់ ម៉ោង១២យប់។ បាទ ម៉ោង១២យប់ ចេញដំណើរមក មកដល់ច្បារអំពៅហ្នឹង គិតថា ម៉ោងប្រហែលជាប្រាំបួន ម៉ោងដប់ ហ្នឹងខ្ញុំប្រហែលទេ ហ្នឹងគឺយើងអត់មានម៉ោងមើលទេ។ ហ្នឹងដូចខ្ញុំនិយាយមុនអ៊ីចឹង។ ខ្ញុំអត់បានកំណត់ថា ម៉ោងមួយ ម៉ោងពីរ ឬកន្លះម៉ោង ខ្ញុំអត់បានកំណត់ពេលវេលាអ៊ីចឹងទេ គ្រាន់តែប្រហែលៗ។ បាទ ពីព្រោះយើងអត់មានម៉ោង។ រហូតមកដល់អ្នកលឿងហ្នឹង ដល់បានឡើងកប៉ាល់ហើយ ឡើងកប៉ាល់មកចុះនៅច្បារអំពៅនេះ ម៉ោងប្រហែលជាប្រាំបួន បាទ ម៉ោងប្រហែលប្រាំបួន។ ហ្នឹងយើងសម្រាកនៅច្បារអំពៅហ្នឹង គេប្រាប់ថា សម្រាកបីថ្ងៃ។ បាទ ៣ថ្ងៃ រហូតដល់ថ្ងៃទី៣ ក៏បានមានថ្នាក់ដឹកនាំជាន់ខ្ពស់ មានលោក ខៀវ សំផន ដែលគាត់អញ្ជើញមកចែកសម្ភារៈហ្នឹង ដូចលោកសួរខ្ញុំអំមិញហ្នឹង បាទ។ ចែកសម្ភារៈហ្នឹង ដែលលោកមានបានថ្លែងសុន្ទរកថាដូចខ្ញុំបានជម្រាបជូនតាំងពីម្សិលម៉្ងៃះ បាទ ហ្នឹងគឺថាគាត់បានជម្រាបអ៊ីចឹង ប្រាប់បងប្អូនណែនាំអ៊ីចឹង។ ហ្នឹងខ្ញុំនិយាយដូចថា មិនអស់ទៀត តែបើថាអស់ គឺវែង។ រហូតដល់ខ្ញុំឡើងរទេះភ្លើង បាទ ខ្ញុំឡើងរទេះភ្លើងហើយហ្នឹង ចេញរទេះភ្លើង ចេញពីហ្នឹងទៅម៉ោងមួយ ទៅដល់ព្រៃស្វាយ ដល់រ៉ាព្រៃស្វាយហ្នឹង គឺថាម៉ោង ប្រហែលជាម៉ោងដប់ពីរ ឬម៉ោងមួយយប់។ ដល់នុ៎ង គេឲ្យយើងចុះពីរទេះភ្លើង ចុះពីរទេះភ្លើងហ្នឹង គេនាំយើងដើរតាមរទេះភ្លើង តាមផ្លូវរទេះភ្លើងហ្នឹង ហើយអត់មានទ្រនាប់ជើងទៀត បាទ ទាំងយប់ហ្នឹង នាំដើរទាំងយប់ចម្ងាយខ្ញុំប៉ាន់ស្មានមើលទៅប្រហែលជា៥គីឡូ ត្រឹម៥គីឡូចុះ បាទមិន៥គីឡូឡើងទេ។ ទៅដល់មានទួលមួយ បាទមានទួលមួយហ្នឹងយប់ មិនដឹងទួលអីខ្ញុំអត់ស្គាល់ មានទួលមួយអត់មានដើមឈើទេទួលហ្នឹង។ ទទួលថ្ងៃហ្នឹងភ្លៀងនោះភ្លៀងបាទ ខែហ្នឹងខែភ្លៀង បាទខែភ្លៀងទៅដល់ហ្នឹងភ្លៀងនោះភ្លៀងយប់ហ្នឹង អត់មានអីជ្រកនាំគ្នាទទូរកន្ទេល បាទកន្ទេលយើងដេកហ្នឹងដាក់តែទទូរអង្គុយសំកុកទៅ អង្គុយសំកុកចាំទម្រាំហ្នឹងភ្លឺ។ ភ្លឺម៉ោងប្រាំ ប្រហែលជាម៉ោងប្រាំ បាទប្រហែលជាប្រាំ ឬប្រាំជាងហ្នឹង មានប្រធានសហករណ៍តាមសហករណ៍មួយៗ ប្រហែលជាគេចែកកម្លាំងហើយ

មើលទៅតាមខ្ញុំស្មានបាទ មកទទួលតាមរោងបាយគេចែកគ្នា។ ដល់ហ្នឹងបែកគ្នាអស់ហើយ ប្រជាជនមកពីខេត្តស្វាយរៀងហ្នឹងបែកគ្នាអស់ហើយ មកពីក្នុងភូមិតែមួយហ្នឹង គេចែកទៅក្នុងមួយសហករណ៍ពីរគ្រួសារ បីគ្រួសារឲ្យចែកទៅហ្នឹង។ ដល់ចំណែកខ្ញុំវិញ ចំណែកខ្ញុំ ខ្ញុំគេឲ្យចាត់តាំងទៅខាងសហ-ករណ៍ ព្រែកជីក ឃុំស្វាយស្ព័រ។ ព្រឹកឡើងចេញដំណើរទៅខាងប្រធានសហករណ៍គេមក មកទទួលហ្នឹងគឺថាឲ្យយើងដាក់អីវ៉ាន់ទៅ តែក្នុងពេលដែលខ្ញុំដើរតាមផ្លូវរទេះភ្លើងទៅយប់ហ្នឹង វាងងឹតជើងទទេវាដើរជំពប់ដុំថ្មបែកដៃបែកជើង អ្នកមានកូនចៅយំស្រែកពេញវាល គិតទៅវាអសោចអសារយប់ហ្នឹងដូចជាអស្ចារ្យពេកបាទ មហាអស្ចារ្យតែម្តងបាទនៅយប់ហ្នឹង ដើរកាត់ដុំថ្មមិនជាស្អីឯណាយើងស្រុកអ្នកស្រុកស្រែមានដែលមានដុំថ្មឯណា។ ដល់អ៊ីចឹងយើងដើរកាត់យប់ហ្នឹង អ៊ីចឹងបានខ្ញុំដូចជាឆ្ងល់ដែរផ្លូវដីមានគាត់មិននាំយើងដើរ គាត់នាំដើរលើថ្នល់រទេះភ្លើងបាទសឹកដុំថ្មហ្នឹង បាទខ្ញុំដូចឆ្ងល់។ អ៊ីចឹងបានដល់ពេលហើយព្រឹកឡើងខ្ញុំបានចេញដំណើរ បាទ ចេញដំណើរទៅ អីវ៉ាន់ឆ្នាំងចានអង្ករបន្តិចបន្តួចហ្នឹងគេយកដាក់រទេះ បាទដាក់រទេះគោ។ រទេះគោហ្នឹងគេចេញដំណើរទៅមុនទៀត ខ្ញុំចេញដំណើរតាំងពីប្រហែលជាម៉ោងប្រាំមួយ បាទម៉ោងប្រាំមួយ ឬប្រាំមួយជាងបន្តិចបន្តួចហ្នឹង ទៅដល់សហករណ៍ព្រែកជីក ម៉ោងជិតប្រាំពីរយប់បាទបានដល់។ ខ្ញុំគិតទៅក្នុងមួយថ្ងៃនោះខ្ញុំអត់មានបានបាយហូប អត់មានបានបាយហូប ដាច់បាយតែម្តងក្នុងមួយថ្ងៃហ្នឹង ព្រោះឆ្នាំងចានអង្ករគេដាក់រទេះទៅមុនហើយ បាទយើងដើរតែខ្លួនហ្នឹង ដើរតែខ្លួនជាមួយប្រធានកងគេនាំទៅ។ ក្នុងពេលនោះហើយដែលខ្ញុំមានការទុក្ខសោកវេទនាជាទីបំផុតលើរូបកាយរបស់ខ្ញុំបាទ។ គិតទៅយើងអស់កម្លាំងពីនេះទៅហើយ ទៅដល់នោះយើងត្រូវដាច់ស្បៀងទៀត អត់មានអីហូបទៀត។ ទៅដល់សហករណ៍ព្រែកជីកហ្នឹងទៀត គឺថាទៅដល់ហ្នឹងគេឲ្យបាយ បាយហ្នឹងគឺថាទៅមុនដំបូងបានពីរវែកបាទ គេឲ្យបាយពីរវែក ហ្នឹងនិយាយតាមជាក់ស្តែងតាមយុត្តិធម៌បាទ ជាក់ស្តែង និងអង្ករសម្រួបទៀតបាយពីរវែក។

[១០:៥៣:៣១]

ដល់ក្រោយមក ប្រហែលជាកន្លះខែគេឲ្យតែមួយវែកៗទេ បាទមួយវែកៗទេ មិនដឹងមូលហេតុអីទេ។ ពេលខ្ញុំទៅនោះ តាមពិត ទៅដល់នោះសហករណ៍ហ្នឹង ក្នុងមួយសហករណ៍គេហៅ កាលនោះគេហៅការដ្ឋានបាទ ការដ្ឋានព្រែកជីកហ្នឹងមានតែប្រាំគ្រួសារទេ បាទមានតែប្រាំគ្រួសារទេ ទទួលខ្ញុំទៅពីនេះប្រាំទៀត បាទទៅពីហ្នឹងប្រាំគ្រួសារទៀត បាន១០គ្រួសារ។ ដល់ហើយខ្ញុំស៊ើបសួរបងប្អូននៅហ្នឹងថាម៉េចក៏មានប្រជាជនតិចម្ល៉េះ? គាត់ថាប្រជាជនមានច្រើន ប៉ុន្តែកាលនោះ គឺថាអត់បាយដាច់ពោះស្លាប់

អស់ទៅនៅសល់ប៉ុណ្ណឹង។ ហ្នឹងគេនិយាយត្រង់ៗអ៊ីចឹង។ ហើយខ្ញុំក៏មិនដឹងដែរ ហ្នឹងតាមខ្ញុំសួរគាត់អ៊ីចឹង ហើយខ្ញុំពេលហ្នឹងហើយដែលយើងខ្ញុំមានអារម្មណ៍មួយកាន់តែភិតភ័យទៀត ខ្ញុំថា អ៊ូ!ខ្ញុំក្នុងមកស្លាប់ដូច គេហ្នឹង។ បើអ្នកមកមុនគេស្លាប់ហើយ ដូចខ្ញុំវានៅប៉ុនណាទៀត គេបង្អត់ដូចតែគ្នា។ ហើយដល់ហើយ គេឲ្យខ្ញុំធ្វើការ គេធ្វើការហ្នឹងគេឲ្យខ្ញុំទៅកាស់គល់ឈើ កាប់រានព្រៃដើម្បីយកដីធ្វើស្រែ ហើយនិងទៅធ្វើ ស្រែ ធ្វើស្រែហ្នឹងគេឲ្យទៅធ្វើស្រែនៅ គេថាស្រូវបង្កើនរដូវនៅតំបន់វាលស្រែស្ពោ គេថាវាលស្រែ១០០ ត្រង់ហ្នឹងក្បែរអាងទឹកមួយ តែមិនដឹងអាងទឹកអីខ្ញុំអត់ស្គាល់ត្រង់ហ្នឹង។ បាទ ខ្ញុំខំធ្វើការនោះខំធ្វើៗៗ ទាល់នឹងឈឺបាទ ទាល់ហ្នឹងឈឺ។ បាទ ហ្នឹងខ្ញុំសូមស្ដេះប៉ុណ្ណឹង។ តែចំណែកឪពុកម្ដាយខ្ញុំវិញ ឪពុក ម្ដាយខ្ញុំ គេជម្លៀសចេញពីព្រៃវែងមកទៀត បាទ ហ្នឹងដល់ពេលអ្នកនៅរស់ត្រឡប់ទៅវិញ និងជួបខ្ញុំទល់ រាល់ថ្ងៃ។ ដល់ហើយគាត់គេជម្លៀសមកមួយសាទៀត តាមពិត គេជម្លៀសជាមួយខ្ញុំហ្នឹង តែគេមិនឲ្យ ជួប បាទ គេអត់ឲ្យជួបទេ ឪពុកកូន។ គេជម្លៀសមកជាមួយគ្នា តាមខ្ញុំសួរទៅគាត់ គេជម្លៀសមកៗស្អី សហករណ៍បាក់ចិញ្ចៀន បាទ សហករណ៍បាក់ចិញ្ចៀនៗ ខេត្តពោធិ៍សាត់។ មកដល់ហ្នឹង តាមតែអ្នក នៅរស់ គាត់ប្រាប់ខ្ញុំ បានប្រហែលជារយៈកាលប្រហែលជាពីរបីខែ ប្រហែលប៉ុណ្ណឹងយ៉ាង គេយកឪពុក ខ្ញុំទៅសម្លាប់ទៀត។

[១០:៥៥:៥៣]

ប្អូនស្រីខ្ញុំពីរនាក់ វានៅកុមារ គេទៅហៅពីកន្លែងកុមារមក យកទៅសម្លាប់ជុំគ្នាម៉ែកូន ឪកូន។ គិតទៅ ស្លាប់នៅបាក់ចិញ្ចៀនហ្នឹង បួននាក់ បាទ បួននាក់ ឪពុកម្ដាយ ប្អូនប្រុស ប្អូនស្រីពីរនាក់ បាទ គិតទៅបួននាក់។ ហ្នឹងក្នុងការខ្ញុំ មានការសោកទុក្ខវេទនា ព្រាត់ប្រាសឪពុកម្ដាយ បងប្អូន ក្នុងពេលនេះ គឺថាខ្ញុំបានឮគេនិយាយអ៊ីចឹង គឺថាខ្ញុំស្លុតអស់ បាទតក់ស្លុត។ ចំណែកបង គេសម្លាប់នៅឯស្រុកនោះ មួយ មួយទៀត គេសម្លាប់នៅព្រៃវែង។ បន្ទាប់មកទៀត គេមកសម្លាប់ដល់បាក់ចិញ្ចៀន បាទ។ ហើយ ចំណែកខ្ញុំៗដល់កន្លែងព្រែកដីក ហើយ ខ្ញុំឈឺ។ ខ្ញុំឈឺ គេឲ្យខ្ញុំទៅដេកពេទ្យ។ ទៅដេកពេទ្យគុជដី – ដេក ពេទ្យគុជដី ខ្ញុំដេកពេទ្យបានកន្លះខែ បាទ កន្លះខែ ខ្ញុំរាងគ្រាន់ – គ្រាន់គេឲ្យខ្ញុំចេញ ឲ្យចេញទៅសហករ ណ៍វិញ។ បាទ ចេញទៅសហករណ៍ គេឲ្យខ្ញុំចាំចម្ការម្ដង ព្រោះខ្ញុំអត់ទាន់មានកម្លាំង ឲ្យខ្ញុំចាំចម្ការ។ ចាំ ចម្ការបានប្រហែលជាមួយខែជាង ទទួលកងទ័ពវៀតណាមចូលពីគាស់ក្រឡ។ ចូលពីគាស់ក្រឡមក គេ ខ្លាចកងទ័ពវៀតណាមគៀរយើងចេញពីគេ គេឲ្យយើងអ្នកឈឺ និងអ្នកពោះធំចាស់ជរា ទៅឡើងចូលព្រៃ ត្រជាក់ចិត្ត បាទ ចូលព្រៃត្រជាក់ចិត្ត។ ពេលចូលទៅចូលព្រៃត្រជាក់នុំង មួយសាទៀត។ ពេលដើរទៅ

01391864



ហ្នឹង គេនាំយើងដើរកាត់គល់ឈើ កូនឈើគេកាប់នៅក្នុងព្រៃស្រួចៗហ្នឹង។ នាំគ្នាដើរកាត់កូនគល់ឈើហ្នឹងទៅ។ ដើរតាំងពីម៉ោងប្រាំបួន ប្រហែលជាម៉ោងបួនរសៀលបានដល់កន្លែងព្រៃត្រជាក់ចិត្ត ដែលគេសម្រាក ហ្នឹង។ គេជម្លៀសចេញពីសហករណ៍ព្រៃជីក។ អ្នកដែលនេះហ្នឹង គេជម្លៀសទៅមុន។ ហើយអ្នកដែលនៅធ្វើការបាន គេឲ្យនៅក្រោយ។ ដល់ក្រោយមកទៀត គេឲ្យទៅទាំងអស់គ្នា បាទ ទៅទាំងអស់គ្នា។

[១០:៥៨:១៥]

ពេលនោះហើយ ដែលខ្ញុំកាន់តែពិបាកទៀត ព្រោះយើងខ្លួនយើងឈឺ បាទ ខ្លួនយើងឈឺ។ ដល់ពេលទៅដល់ព្រៃត្រជាក់ចិត្តហ្នឹង នៅសម្រាកហ្នឹង ខ្ញុំអត់បានចាំថ្ងៃខែដែរ ប៉ុន្តែវាយូរដែរ ប្រហែលជាមួយខែ ជិតពីរខែនោះ។ ទទួលមានកប៉ាល់ហោះ បាទ កប៉ាល់ហោះហ្នឹង ដាក់មីក្រូស្រែក បោះត្រាក់ឲ្យបងប្អូនចេញពីព្រៃត្រជាក់ចិត្តជាបន្ទាន់ បើមិនចេញ កប៉ាល់ហោះទម្លាក់បេ បាទ ទម្លាក់បេ។

ដល់ទទួលខាងកងទ័ពខ្មែរក្រហម គេឮ ខាងឈ្លបឮ គេឲ្យយើងចេញ បាទ គេឲ្យយើងចេញពីព្រៃត្រជាក់ចិត្តហ្នឹងទៀត បាទ ចេញពីព្រៃត្រជាក់ចិត្ត មកៗចូលភ្នំកូនខ្លា បាទ ខ្ញុំអត់ស្គាល់ទេ តែឮតែអ្នកដែលគេស្គាល់ គេថា ភ្នំកូនខ្លា។ បាទ ចូលភ្នំកូនខ្លា ដល់ហើយទទួលមកដល់ហ្នឹង សម្រាកបាន មិនបានចូលទេ កនខ្ញុំហ្នឹង អ្នកដែលទៅបូព៌ា គិតទៅវាជាងម្ភៃគ្រួ ដែលទៅជាមួយខ្ញុំ សរុបទាំងអស់។ ដល់ពេលហើយជុំគ្នា បាទ ជុំគ្នា ចេញពីសហករណ៍មួយៗទៅជុំគ្នានៅព្រៃត្រជាក់ចិត្តហ្នឹង ជួបគ្នា ដល់ហើយ គេមកកៀងមួយសាទៀត យើងបានជួបគ្នា។ ដល់ជួបគ្នា គេបបួលទៅ កៀងឲ្យទៅ យើងអត់ព្រមទៅ យើងអត់ហ៊ានទៅ ព្រោះកងទ័ពវៀតណាមចូលជិតដល់ យើងមើលឃើញថា ទៅ តែកងវៀត-ណាមសម្រុកចូល យើងត្រូវតែស្លាប់។ ដល់ហើយ យើងអត់ព្រមទៅ។ អត់ព្រមទៅ ស្រាប់តែខាងឈ្លបហើយនិងប្រធានសហករណ៍គេហ្នឹង គេថាបងប្អូនមានស្លាប មានស្លាបហើយ ចង់ហើរចោលគេហើយ។ ហ្នឹងគេថាអ៊ីចឹង។ ដល់ហើយពួកគេហ្នឹង ក៏គេមិនប្រចំយើងដែរ គេអត់ប្រចំ ប្រហែលជាគេដឹង។ ដល់ហើយហ្នឹង កងខាងខ្ញុំហ្នឹងគេចៗពីពួកគេហ្នឹង ឡប់ទៅក្រោយវិញ។ ឡប់ទៅក្រោយហ្នឹង ឡប់មកសម្រាកខាងត្បូងដំណាក់រុន នៅកណ្ដាលវាលតែម្ដង បាទ។ ខាងត្បូងដំណាក់រុន បាទ។

[១១:០០:១៧]

**ប្រធានអង្គជំនុំ៖**

បាទ បានហើយ ប៉ុណ្ណឹងបានហើយ។ យើងឲ្យថ្លែងពីទុក្ខលំបាក ហើយនិងអន្តរាយ ខូចខាតតែ

ប៉ុណ្ណឹង។ នេះរៀបរាប់រាប់ដំណើរជីវិតមួយរបបតែម្តង។

បាទ អរគុណ។ អង្គជំនុំជម្រះ អរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី ហើយសវនាការស្តាប់សក្ខីកម្មនិងសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មក្នុងឋានៈលោកជាដើមបណ្តឹងរដ្ឋប្បវេណីដែលលោកអះអាងថា បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះបានដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ វត្តមានរបស់លោក នៅអ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះ នឹងធ្វើសវនាការ ស្តាប់សក្ខីកម្មសាក្សី 2-TCW-1069។

ម៉េចទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងបានផ្ញើជូនអង្គជំនុំជម្រះកាលពីម្សិលមិញនូវសំណួរដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះចង់សួរទៅកាន់លោក ខៀវ សំផន តាមរយៈលោកប្រធាន។ ដូច្នេះ ខ្ញុំគិតថាអង្គជំនុំជម្រះបានទទួល។

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីមានអីចង់សួរទេ? អញ្ជើញសួរ!

[១១:០១:៥៨]

**2-TCCP-1063៖**

បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ បាទ ខ្ញុំសូមសួរសំណួរទៅតាមរយៈលោកប្រធាន។ សួរសំណួរទៅលោក ខៀវ សំផន។ គាត់មានប្រសាសន៍ថា គាត់មិនបានដឹង មិនបានឃើញថា គេសម្លាប់ ឬជម្លៀសប្រជាជនទេ។ បាទ ព្រោះពេលមុនគាត់បានឆ្លើយថាអ៊ីចឹងមែន ហ្នឹងតាមខ្ញុំឮ ខ្ញុំដឹង។ តើរឿងហ្នឹង គាត់ប្រកែកថា គាត់មិនបានដឹង មិនបានទទួលស្គាល់ ថាជម្លៀស និងសម្លាប់មែនឬអី? តើគាត់

អាចឆ្លើយបានដែរ លោកប្រធាន? បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមរំឭក ជម្រាបជូនលោកដើមបណ្តឹងរដ្ឋប្បវេណីថា ក្នុងកិច្ចដំណើរការសវនាការលើកអង្គសេចក្តី ពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ តាំងពីដើមដំបូងនៃសវនាការ ជនជាប់ចោទទាំងពីររូប នួន ជា និងខៀវ សំផន សុទ្ធតែបានឆ្លើយបញ្ជាក់ថា គាត់មិនមាន -- គាត់អនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបនូវសំណួររបស់ភាគី ដែលសួរនៅក្នុងអង្គជំនុំជម្រះ។ ហើយក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ក៏លោក ខៀវ សំផន ឆ្លើយបញ្ជាក់អំពីការដែលគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរដែរ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់គាត់ក្នុងការលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការយល់ព្រមឆ្លើយតបនឹងសំណួរទេ។ ហើយតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ទាំងច្បាប់ជាតិ ទាំងច្បាប់អន្តរជាតិគឺ តុលាការមិនអាចចាប់បង្ខំឲ្យជនជាប់ចោទត្រូវតែឆ្លើយតបនូវសំណួរនោះឡើយ។

ជាបន្តទៅនេះ សវនាការនៅបន្តទៅទៀត អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-1069។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ ដប់ប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:០៤ នាទី ដល់ម៉ោង ១១:១៨ នាទី)*

[១១:១៨:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការតទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-1069 ហើយអង្គជំនុំជម្រះសូមបញ្ជាក់ថា ព័ត៌មានថ្មីដែលអង្គជំនុំជម្រះទទួលបានហ្នឹង គឺសាក្សីរូបនេះ មានមេធាវីប្រឹក្សាសាក្សី គឺលោក ចាន់ សំបូរ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**លោក រ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូម<យក>ឱកាស<នេះ>លើកបញ្ហាមួយចំនួនពាក់ព័ន្ធទៅនឹងសាក្សីរូប <នេះ>។ <ជាការពិត កាលពីម្សិលមិញ>នៅក្នុងពេលដែលខ្ញុំធ្វើការរៀបចំកាលពីម្សិលមិញដើម្បីសួរសាក្សីរូបនេះ ក៏ដូចជា TCW-1070 នោះផងដែរ <ខ្ញុំបានដឹងថា ទំហំនៃការយល់ដឹង>របស់សាក្សីរូបនេះ ពាក់ព័ន្ធទៅនឹង<ហេតុការណ៍នៅ>ភូមិភាគបូព៌ា <គឺមានភាព>ទូលំទូលាយ<ណាស់។> ហើយយោងទៅលើសេចក្ដីសម្រេចពីខាងដើមរបស់អង្គជំនុំជម្រះ ដែល<មាន>គម្រោងថានឹងចំណាយពេល ២ថ្ងៃ សម្រាប់សួរសាក្សី 1065*(ស៊ីក)* <ដែលបានផ្ដល់សក្ខីកម្មកាលពីប៉ុន្មានសប្ដាហ៍មុន> ខ្ញុំយល់ថាវាមានសារៈសំខាន់ណាស់<ដែលយើងគួរតែស្ដាប់>សាក្សីរូបនេះ ឲ្យបានលើសពី១ថ្ងៃ<ដូចដែលបានរំពឹងទុក។ ដូច្នេះ ការស្នើសុំរបស់ខ្ញុំគឺមិនត្រឹមតែ>ទាក់ទង<នឹង>សាក្សី<រូប>នេះទេ <ប៉ុន្តែ>ក៏ពាក់ព័ន្ធទៅនឹងសាក្សី 1070<ផងដែរ> ដែល<នឹង>ត្រូវ<ចំណាយ>ពេលយ៉ាងហោចណាស់ ក៏មួយថ្ងៃកន្លះ<ឬរហូត>ទៅ<ដល់>២ថ្ងៃ ដើម្បីសួរទៅកាន់សាក្សីរូបនោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ចាំមើល>ថាតើភាគីដទៃទៀតមានយោបល់ថាម៉េចដែរ <ហើយបន្ទាប់មកយើងនឹងធ្វើសេចក្ដីសម្រេច>នៅពេលបាយថ្ងៃត្រង់<។>

**លោក នីកូឡាស គូមជែន៖**

<សូមអរគុណ> ខ្ញុំយល់ឃើញថា មួយថ្ងៃគ្រប់គ្រាន់ហើយ<។ ប្រហែលជាយើងចាំមើលថាតើព្រឹកហ្នឹងយើងចំណាយពេលអស់ប៉ុន្មាន ប៉ុន្តែខ្ញុំយល់ថាមិនមានភាពចាំបាច់ជាក់លាក់ណាមួយទេ។ ម្យ៉ាងវិញទៀត> យើងខ្ញុំមិនជំទាស់ទេ <ពីព្រោះថា វាមិនប៉ះពាល់អ្វីនោះទេ ដោយគ្រាន់តែយើងអូសបន្លាយពេលនៃអង្គជំនុំជម្រះឲ្យយូរបន្តិច>។

[១១:២១:០៣]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន គឺខាងយើងខ្ញុំអត់មានជំទាស់ទេ គឺខាងយើងអត់មានជំទាស់អ្វីទេ។

**ប្រធានអង្គជំនុំ៖**

មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណលោកប្រធាន។ ខ្ញុំអត់បានស្ដាប់ឮពេលដែលមេធាវី កូប៉េ គាត់និយាយផង អម្បាញ់មិញនេះ ព្រោះខ្ញុំទៅចុចដូរប៉ុស្តិ៍ ទៅរកប៉ុស្តិ៍បារាំង។ ក៏ប៉ុន្តែខ្ញុំយល់ពីសំអាងហេតុដែលគាត់លើកឡើងដើម្បីសុំពន្យារពេល។ យើងខ្ញុំគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះ យើងទទួលបានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលតាមរយៈនោះ ទ្រឹស្ដីរបស់មេធាវីការពារក្ដីមួយចំនួនទៅលើការបះបោរ ត្រូវបានច្រានចោលដោយអង្គជំនុំជម្រះតុលាការកំពូលហើយ។ អ៊ីចឹង ខ្ញុំគិតថាអង្គជំនុំជម្រះសាលាដំបូង គួរតែចងចាំចំណុចនេះ នៅពេលដែលខ្លួនឯកភាព ឬមិនឯកភាពក្នុងការផ្ដល់ពេលវេលាបន្ថែមទៅមេធាវី នួន ជា នោះ។ ដូច្នេះ ខ្ញុំគិតថាវាមានភាពប៉ះពាល់ផងដែរ តាមរយៈសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនោះ ក៏ប៉ុន្តែទោះយ៉ាងណាក៏ដោយយើងខ្ញុំគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះ។

[១១:២២:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ អង្គជំនុំជម្រះនឹងពិនិត្យពិចារណាសំណើសុំនេះ ហើយនិងមតិយោបល់ផ្សេង ភាគីដទៃទៀតពាក់ព័ន្ធ ដើម្បីកំណត់បញ្ជាក់អំពីពេលវេលាក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះនៅក្រោយពេលអាហារថ្ងៃត្រង់។ បានន័យថា នៅចាប់ផ្ដើមដំបូងនៃសវនាការនៅរសៀលនេះ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកឈ្មោះអី លោកអាចប្រាប់យើងបានដែរទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ ស៊ិន អ៊ឹង។

**ស៖** អរគុណលោក ស៊ិន អ៊ឹង តើលោកកើតនៅថ្ងៃទីខែឆ្នាំណាដែរ លោកចាំដែរទេ?

**ឆ៖** ថ្ងៃទី៨ ខែ៣ ហ្នឹងយ៉ាងខ្ញុំភ្លេចទៅ ប៉ុន្តែដឹងតែឆ្នាំ៥៧ -- ១៩៥៧។

**ស៖** បាទ អរគុណ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណាដែរ?

**ឆ៖** ខ្ញុំបាននៅភូមិសង្គម ឃុំគគីរសោម បច្ចុប្បន្នស្រុកស្វាយទៀប ខេត្តស្វាយរៀង។

**ស៖** ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** បាទ នៅភូមិឃុំដដែលហ្នឹង ភូមិសង្គម ឃុំគគីរសោម ខេត្តស្វាយរៀងដដែល។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01391869



**សះ** ហើយលោកប្រកបមុខរបរអ្វីសព្វថ្ងៃនេះ?

**ផះ** មុខរបរខ្ញុំបាទ ធ្វើស្រែ។

[១១:២៤:២២]

**សះ** ឪពុកបង្កើតលោកឈ្មោះអី ហើយម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ផះ** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ យស់ សារី គាត់ស្លាប់ហើយ។ ម្ដាយនៅ ម្ដាយខ្ញុំឈ្មោះ ស៊ិន ប៉ែន នៅហ្នឹង នៅរស់។

**សះ** ម្ដាយឈ្មោះ ស៊ិន ប៉ែន ឬក៏ ស៊ិន ប៉ែត?

**ផះ** ស៊ិន ប៉ែន។

**សះ** ស៊ិន ប៉ែន?

**ផះ** បាទ ស៊ិន ប៉ែន។ បាទ ខ្ញុំយកត្រកូលម្ដាយ។

**សះ** បាទ អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ផះ** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**សះ** កុំទាលអាន់ឆ្លើយលឿនពេក ចាំ រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការឲ្យភ្លើងសញ្ញាក្រហម នៅក្បាលមីក្រូហ្វូន អាន់ុងលោកនិយាយទៅដើម្បីសំឡេងរបស់លោកបានចែកចាយទៅដល់ភាគីពាក់ព័ន្ធ រួមទាំងពិសេសទៅអ្នកបកប្រែភាសា ដើម្បីបកប្រែភាសានូវចម្លើយរបស់លោកហ្នឹង គឺទៅជាពីរភាសាទៀត បារាំង និងអង់គ្លេស ដែលភាសាទាំងបីនេះ ប្រើប្រាស់ជាផ្លូវការនៅ អ.វ.ត.ក នេះ។

**ផះ** ប្រពន្ធខ្ញុំបាទ ឈ្មោះ ឡុង សំអាត។ មានកូនប្រាំនាក់ ខ្ញុំបាទ។

[១១:២៦:១០]

**សះ** បាទ អរគុណ។ ហើយលោក ស៊ិន អ៊ឹង តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញ ថាសមត្ថភាពដែលលោកអាចដឹងបាន គឺលោកមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន ក៏ដូចជាបុគ្គលទាំងឡាយដែលត្រូវបានទទួលយកភាគីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះទេ។ តើរបាយការណ៍នេះ ពិតជាត្រឹមត្រូវដែរឬទេ?

**ផះ** បាទ របាយការណ៍នេះ ពិតជាត្រឹមត្រូវមែន។ ខ្ញុំមិនបានជាប់សាច់ញាតិរបស់ជនជាប់ចោទហ្នឹងទេ។

**សះ** តើលោកបានធ្វើសម្បថនៅមុខចំពោះលោកតាដំបងដែកនៅពីខាងកើតសាលជំនុំជម្រះនេះ

ហើយឬនៅ មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ?

**ឆ៖** បាទ ខ្ញុំធ្វើការសម្បថរួចហើយ។

[១១:២៧:០៦]

**ស៖** បាទ អរគុណ។ តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់លោកក្នុងឋានៈលោកជាសាក្សី នៅចំពោះមុខអង្គជំនុំជម្រះ។ លោក ស៊ិន អ៊ឹង ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬសុំឱ្យលោកធ្វើអត្ថាធិប្បាយរៀបរាប់ណាដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ឯអំពីករណីយកិច្ច លោក ស៊ិន អ៊ឹង លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគីឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក ឡើកលែងតែសំណួរណានាំឱ្យចម្លើយតបរបស់លោក ឬការអត្ថាធិប្បាយរៀបរាប់របស់លោកនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់សាក្សីរួចហើយ អម្បាញ់មិញនេះ។ ក្នុងឋានៈជាសាក្សីត្រូវតែឆ្លើយការណាដែលពិត ដែលបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏ធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ ហើយលោកសាក្សី តើលោកបានធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេក្នុងរយៈពេលកន្លងមក?

[១១:២៨:២៤]

**ឆ៖** ខ្ញុំបាទមិនដែលបានមកចូលមកកន្លែងហ្នឹងទេ។ គ្រាន់តែថាបើមានគេអ្នកទៅសម្ភាសដល់ផ្ទះមានខ្លះដែរ។ មាន បើថាកន្លែងហ្នឹងមិនដែលបានមកទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយនៅពេលនេះ លោកបានទទួលជំនួយមេធាវីប្រឹក្សាដែលអង្គជំនុំជម្រះបានផ្តល់ឱ្យតាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញរួចហើយ គឺមេធាវីប្រឹក្សាសាក្សី លោក ចាន់ សំបូរ ហើយដូចជាលោកបាន លោកមេធាវីអង្គុយក្បែរលោកនោះហើយ ដើម្បីពិភាក្សាក្នុងករណីចាំបាច់នៃសំណួរដែលមានការសង្ស័យថា ជាសំណួរនាំឱ្យចម្លើយតប ឬក៏ធ្វើអត្ថាធិប្បាយតបរបស់លោកដាក់បន្ទុកលើខ្លួនឯង។ បាទ ហើយដោយសារនៅដល់ពេលវេលាបន្តិចបន្តួចប៉ុណ្ណោះ នាថ្ងៃ -- នាពេលនេះ

ដូច្នេះ ក៏សមល្មមនឹងសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឱ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយនិងបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យនាំខ្លួនគាត់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឱ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣០ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីសួរដេញដោលសាក្សីរូបនេះ អង្គជំនុំជម្រះសុំចេញសេចក្តីសម្រេចផ្ទាល់មាត់ពាក់ព័ន្ធទៅនឹងសាក្សី 2-TCW-920។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះអំពីកិច្ចសម្ភាសន៍ដែលធ្វើឡើងយោយជម្ពូមណ្ឌលឯកសារកម្ពុជា ជាមួយនឹងសាក្សី 2-TCW-920 ដែលមាននៅក្នុងសំណុំរឿង០០៤។ ដោយពិចារណាឃើញថាឯកសារនេះគឺជាឯកសារដែលអាចរកបានជាសាធារណៈ ហើយនិងដើម្បីចៀសវាងសំណើផ្សេងៗទៅកាន់សហចៅក្រមស៊ើបអង្កេត ដើម្បីឱ្យការដាក់ឯកសារ អង្គជំនុំជម្រះបានទទួលយកឯកសារនេះដោយផ្ទាល់ពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានផ្តល់ទៅឱ្យភាគីផ្សេងមុនពេលការផ្តល់សក្ខីកម្មសាក្សីរូបនេះ។ សូមរំឭកដល់ការអនុវត្តរបស់អង្គជំនុំជម្រះក្នុងការទទួលយកចម្លើយពីមុនៗរបស់សាក្សីដែលមកផ្តល់សក្ខីកម្ម អង្គជំនុំជម្រះសម្រេចទទួលយកកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយនឹងសាក្សី 2-TCW-920 ហើយដាក់លេខឯកសារជា E3/10762។

[១៣:៣៣:២០]

បាទ ហើយបញ្ហាមួយទៀតគឺ តាមសំណើរបស់លោកមេធាវី វ៉ិចទ័រ កូប៉េ កាលពីព្រឹកមិញ ក្នុងការសុំបន្ថែមពេលវេលាសម្រាប់សួរដេញដោលសាក្សីរូបនេះ អង្គជំនុំជម្រះសម្រេចពេលវេលារួមរវាងភាគីពាក់ព័ន្ធនៅក្នុងការដេញដោលសាក្សីរូបនេះគឺមានរយៈពេលមួយថ្ងៃកន្លះ។ អ៊ីចឹងភាគីខាងការពារក្ដីមានបីវគ្គ ហើយនិងមេធាវី -- ខាងសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលបីវគ្គនៃថ្ងៃសវនាការ។

បាទ តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដីលោក នួន ជា ដើម្បីសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ស៖** ជម្រាប<សួរ>សាក្សី ខ្ញុំជាមេធាវីអន្តរជាតិការពារលោក នួន ជា។ ខ្ញុំមានសំណួរខ្លះសួរលោកនៅរសៀលនេះ។ បាទ ខ្ញុំសុំសួរសំណួរពីរបីដំបូងនូវអ្វីដែលលោកបានធ្វើចន្លោះពីឆ្នាំ១៩៧៥ ដល់ ១៩៧៩។ តើលោកអាចរៀបរាប់ជូនតុលាការបានទេ? គិតមកដល់ថ្ងៃ១៧ មេសា ១៩៧៥ <តើលោកនៅទីណា? ហើយ> តើលោកបានធ្វើអ្វីខ្លះ?

[១៣:៣៥:០៣]

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** ខ្ញុំបាទជំនាន់ពី៧៥ ឆ្នាំ៧៥ មកឆ្នាំ១៩៧៩ ហើយអំមិញ! បាទ ជំនាន់នុ៎ង៧៥ ខ្ញុំធ្វើជា ក្នុងរបបខ្ញុំធ្វើជាកងចល័តរែកដី រែកដី ដល់បែក៧៥ រួចចន្លោះនុ៎ងមក ខ្ញុំនៅធ្វើទាល់តែដល់ចូលឆ្នាំ៧៦ បានខាងភូមិភាគ សោ ភឹម ហ្នឹងយកខ្ញុំមកនៅភូមិភាគ។ បាទ ខ្ញុំប៉ុណ្ណឹងបាទ។ មកនៅក្នុងខាងភូមិភាគហ្នឹងដំបូងយើងធ្វើ ការធ្វើដាំបន្លែ រៀនសូត្រហាត់រៀនក្បួនយោធា បន្ទាប់ពីហ្នឹងមកដាំបន្លែ ធ្វើស្រែ ស្រូវបន្ទាប់មកក៏ធ្វើជា -- យប់យាម ដល់ពេលចាស់ៗគាត់ដូរចេញទៅ គេទៅនៅនេះទៅ ខ្ញុំធ្វើជាអង្គរក្សតាសោ ភឹម។ ខ្ញុំបាទហ្នឹងធ្វើជាកងការពារ។ ពេលទៅណាមកណាអ៊ីចឹងគាត់យកយើងទៅការពារគាត់ហ្នឹង យប់គាត់នៅនឹងផ្ទះ យើងយាមគាត់ទៅ ផ្លាស់វេនគ្នាយាមមួយម៉ោងម្នាក់អ៊ីចឹងទៅ យាម ប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណចំពោះការឆ្លើយល្អិតល្អន់នេះ។ ខ្ញុំមានសំណួរមួយចំនួនតូចទៀត តើត្រឹម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ត្រូវដែរឬទេដែលថាទាក់ទងទៅនឹងតួនាទីរបស់លោកដែលបានធ្វើជាការជាមួយនឹង សោ ភឹម នោះគឺលោកទទួលបានការបណ្តុះបណ្តាលផ្នែកយោធាអស់រយៈពេលជាច្រើនខែដែរ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អស់រយៈពេលច្រើនខែដែរ ពីរបីខែដែរ ក៏ប៉ុន្តែវាមិនជាប់ទេ ជួនកាលថ្ងៃណាបានហាត់រៀនទៅបាន ថ្ងៃណាមិនបានក៏មិនបានក៏អត់ដែរ។ បាទ សូមអស់យោបល់។

[១៣:៣៨:០៣]

**ស៖** បាទ សំណួរមួយទៀត គឺថាលោកបានឆ្លើយយ៉ាងល្អិតល្អន់ទៅនឹងកិច្ចសម្ភាសន៍តាមរយៈអង្គការមួយហៅថាមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយចម្លើយរបស់លោកនោះ គឺត្រូវបានសរសេរនៅក្នុងឯកសារ E3/10716, ERN ជាភាសាអង់គ្លេស 01353342, ខ្មែរ 01340556 លោកប្រធានសូមអធ្យាស្រ័យដោយសារថា ពេលវេលាខ្ញុំមិនអាចផ្តល់លេខ ERNជាភាសាបារាំងបានទាន់ពេលវេលាទេ។

លោកសាក្សី លោកនិយាយថាលោកធ្វើការនៅមន្ទីរការពារ ឬក៏ធ្វើការនៅខាងផ្នែកមន្ទីរការពារ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ ខ្ញុំធ្វើការនៅមន្ទីរការពារភូមិភាគបាទ។

**ស៖** ហើយថាតើសហការីប៉ុន្មាននាក់ដែលធ្វើការជាមួយលោកនៅមន្ទីរការពារនោះ?

**ឆ៖** បាទ ធ្វើការនៅជាមួយខ្ញុំនឹងមានបុគ្គលិកទាំងអស់ទាំងស្រី ទាំងប្រុស ទាំងតូច ទាំងធំចំនួនប្រហែល ៦០នាក់ គ្រាន់ថាគេអត់មាននៅជុំគ្នា ព្រលឹមឡើងគេបែងចែកដែលខ្លះទៅខាងណេះ ខ្លះទៅខាងណោះទៅណ៎ា វាមិននៅជុំគ្នាទេ បាទ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេថានៅពេលនោះ តើអ្នកណាជាប្រធានមន្ទីរការពារនេះ?

**ឆ៖** បាទ មុននៅ ខ្ញុំនៅនុ៎ង គឺឈ្មោះ ប្រាក់ ជឿក ដែលគាត់ជាប្រធានមន្ទីរការពារ បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចូលទៅសួរមនុស្សម្នាក់ដែលលោកបាននិយាយពីឈ្មោះគាត់ហើយ គឺ សោ ភឹម។ តើត្រឹមត្រូវដែរឬទេ ដែលថាលោកនេះ ជាប់សាច់ឈាមជាមួយនឹង សោ ភឹម? បើជាប់សាច់ឈាមជាមួយនឹង សោ ភឹម ហ្នឹង លោកជាប់សាច់ឈាមក្នុងកម្រិតណាដែរ?

[១៣:៤០:៤៨]

**ឆ៖** បាទ ខ្ញុំឮយាយ ខ្មោចយាយខ្ញុំថា គាត់ជាប់សាច់ឈាមនឹងខ្មោចយាយខ្ញុំ។ យាយខ្ញុំប្រហែលជាជីដូនមួយ ឬក៏ជីដូនអី ឮថាគាត់អ៊ីចឹង។ ហើយដល់មកខ្ញុំហ្នឹងក៏វាឆ្ងាយដែរ ព្រោះយាយនឹង

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យាយ គាត់ជីដូនមួយហើយ ទម្រាំដល់ម៉ែខ្ញុំ ហើយមកដល់ខ្ញុំទៀត វាឆ្ងាយដែរ។ ដល់នេះ ខ្ញុំមិនសូវដឹងច្បាស់ពីខ្ញុំ ហើយនិងគាត់ទេ បើយាយខ្ញុំ ហើយម៉ែខ្ញុំ បានគាត់ដឹងថា ជាប់សាច់ឈាម។ បាទ ប៉ុណ្ណឹង។

**ស៖** ហើយនៅក្នុងឆ្នាំ១៩៧៦ នៅពេលដែល សោ ភឹម ឱ្យលោកចូលធ្វើការនៅមន្ទីរការពារនោះ តើ សោ ភឹម បានដឹងថា លោកជាប់សាច់ឈាមជាមួយនឹងគាត់ដែរឬទេ?

**ឆ៖** បាទ ព្រោះ សោ ភឹម ហ្នឹង គាត់ដឹងៗថា ខ្ញុំក្មួនពីនេះ ពីនោះ អ៊ីចឹងគាត់អាចដឹងថា ជាប់សាច់ឈាម តែខ្ញុំ សម្រាប់ក្មេងៗ អត់ៗដឹងទេ។ ទាល់តែចាស់ប្រាប់ បានដឹង។ ដល់គាត់ គាត់ដឹង ព្រោះគាត់ចាស់ គាត់ដឹងថា បងប្អូនត្រូវជាសាច់ញាតិ សាច់អីហ្នឹង គាត់ដឹង បាទ។

**ស៖** សូមអរគុណលោកសាក្សី។

**លោក វិ៊ចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញរូបថតមួយ ក្នុងចំណោមរូបថតបីសន្លឹក ដែលខ្ញុំបានយកមកបង្ហាញជូនសាក្សី។ ខ្ញុំសូម<អនុញ្ញាត>បង្ហាញជូនជាដំបូងនូវរូបថត E3/3259, គឺៗមានតែ ERN មួយទេ<ដែលចាប់ផ្ដើមដោយអក្សរ "ភី" ហើយ "ភី" មកពីពាក្យ "ហ្វូតូ"> គឺ <P004166559>។ បាទ ខ្ញុំបានថតចម្លងរូបថតមួយ ជូនឱ្យសាក្សីមួយដែរ ហើយនិងមានសល់មួយសន្លឹកទៀត ដើម្បីយកទៅដាក់បញ្ចាំងនៅលើអេក្រង់ បាទ។ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វិ៊ចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកមានស្គាល់អ្នកណាម្នាក់ដែរទេ នៅក្នុងរូបថតនេះ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំស្គាល់ម្នាក់នុ៎ង តា សោ ភឹម។ កាលដែលនោះ គាត់នៅក្មេងតាំងពីខ្ញុំមិនទាន់ទៅទេនេះ ដែលៗរូបថតនេះ។ កាលដែលខ្ញុំទៅហ្នឹង គាត់ចាស់ហើយ ស្គូវ សក់ក៏នៅតិចដែរ។ ថត មុនខ្ញុំទៅទៀត ថតហ្នឹង បាទ។ ហើយប៉ុន្មាននោះ មិនសូវស្គាល់ទេ មើលមិនសូវច្បាស់ ចាំមិនបានទេ ដល់ច្រើនអ៊ីចឹង។

**ស៖** លោកសាក្សី ឥឡូវនេះ លោកថាស្គាល់ហ្នឹង កំពុងតែនិយាយពីមនុស្សទី៣ឬ បើរាប់ពីខាងឆ្វេងដៃទៅ?

[១៣:៤៤:៤៦]

**ប្រធានអង្គជំនុំ៖**

លោកមើលៗនៅក្នុងអេក្រង់ទូរទស្សន៍ បានមើលច្បាស់ ដែលថាគេមានគូសរង្វង់ៗពណ៌ក្រហម ពិនិត្យមើល។

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំឃើញម្នាក់ ដែលរាប់ពីខាងឆ្វេងដៃហ្នឹង ទី៣ហ្នឹង គូសរង្វង់ចំហ្នឹង ស្គាល់ម្នាក់ បាទ តា សោ ភឹម ហ្នឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី <តើ>លោកស្គាល់អ្នកដែលឈរនៅខាងឆ្វេងដៃគាត់ រាប់ពីខាងឆ្វេងទៅទី២ <ដែល>គាត់កំពុងតែញញឹម <តើ>លោកស្គាល់ទេ?

**ឆ៖** ខ្ញុំមើលមិនដឹងច្បាស់ដែរ មិនដឹងអ្នកណាមួយដែរ មិនស្គាល់។ អត់ស្គាល់ផង។

**ស៖** លោកពិតជាស្គាល់គាត់ ហើយ<នៅពេលក្រោយ យើងនឹង>និយាយ<អំពីគាត់យ៉ាង> ច្រើន<ក្នុងថ្ងៃនេះ>។ បាទ រូបនេះ គឺរូបនួន ជា។ <តើ>លោកស្គាល់ នួន ជា ទេ?

**ឆ៖** បាទ នួន ជា ហ្នឹង ខ្ញុំ-- កាលដែលគាត់អញ្ជើញទៅ ខ្ញុំនៅហ្នឹង ខ្ញុំស្គាល់មិនស្គាល់ច្បាស់ទេ ស្គាល់តែតាមរយៈខ្ញុំសួរចាស់ដែលគេនៅហ្នឹង គេប្រាប់ ដែលឲ្យខ្ញុំការពារហ្នឹងថា *(ឮមិនច្បាស់)* ព្រោះ ភ្ញៀវមកសុទ្ធតែអ្នកធំៗមកហ្នឹង មាន នួន ជា, មានលោក ប៉ុល ពត អី គេប្រាប់អ៊ីចឹង។ បើថា ឲ្យខ្ញុំ ស្គាល់ច្បាស់ មិនច្បាស់ទេ ស្គាល់ត្រឹមដូចថា គេប្រាប់ខ្ញុំ។ ស្គាល់ឲ្យជួយចំណាំអ៊ីចឹង ព្រោះខ្ញុំនៅខាង ក្រោយ នៅខាងក្រៅ នៅខាងការពារនៅឯខាងនេះទេ បើថាឲ្យស្គាល់ជាក់លាក់មិនស្គាល់ទេ គ្រាន់ថាគេ ប្រាប់ឲ្យចំណាំហ្នឹង ឲ្យជួយប្រាប់អ៊ីចឹង។ បាទ ប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមសួរបន្តទៅទៀត។ សូមសួរបន្តអំពី នួន ជា នេះនៅក្នុងចម្លើយរបស់លោកឆ្លើយជូន មជ្ឈមណ្ឌលឯកសារកម្ពុជា E3/10716, ERN អង់គ្លេស 01353347, ខ្មែរ 01340559។ លោកបាន និយាយដូចតទៅអំពី នួន ជា។ បាទ ខ្ញុំសូមអានឲ្យលោកស្តាប់ "នៅពេលនោះ តើលោកស្គាល់ តានួន ជា ច្បាស់ទេ? ហើយលោកឆ្លើយថា នួន ជា បានទៅសម្រាកនៅមន្ទីររបស់ខ្ញុំនោះ ពីរបីបួនដងដែរ ចឹមិន ស្គាល់។ ដេកនៅមន្ទីរណា<ដែរ>? ដេកនៅស្លូង មន្ទីរការពារ។ ដេកនៅមន្ទីរការពារ<នៅស្លូង>បានបី បួនដងដែរឬ? លោកឆ្លើយ៖ បាទ។ នួន ជា នេះគឺឧស្សាហ៍មកណាស់។ នួន ជា, សុន សេន, ជួន ជឿន

អីក៏ឧស្សាហ៍ទៅដែរ។" តើលោកនៅចាំថា ១ឆ្នាំ<មុន> គឺមួយឆ្នាំកន្លះទៅហើយ<ដែល>លោកបានឆ្លើយប្រាប់អ្នកសម្ភាសមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាថាដូច្នេះ <តើ>លោកនៅចាំទេ?

[១៣:៤៨:៤០]

**ឆ៖** បាទ វាមានភ្លេចភ្លាំងខ្លះ កាលនោះ ខ្ញុំថាស្គាល់មែន តែស្គាល់តាមរៀមច្បងគេប្រាប់។ គ្រាន់តែមិនស្គាល់ជាក់លាក់ ប៉ុន្តែគ្រាន់ស្គាល់ថាចំណាំ ប៉ុន្តែបើឲ្យស្គាល់ថិតថេររាល់ថ្ងៃ ក្រឡេកឃើញស្គាល់ វាមិនស្គាល់ទេ ជំនាន់មុនស្គាល់មែន កាលនោះ។ ឥឡូវវារយៈពេល សាមសែបឆ្នាំហើយ ៣០ឆ្នាំជាងហើយ ខ្ញុំភ្លេចហើយដល់មកឥឡូវហ្នឹង ភ្លេចស្រពិចស្រពិលហើយ វា ដូចថាមិនបានចាប់អារម្មណ៍បាទ។ បើថាឲ្យស្គាល់ច្បាស់ថិតថេរជំនាន់នោះស្គាល់មែន ស្គាល់ព្រោះគាត់មកខ្ញុំសួរគេ បងៗរៀមច្បងខ្ញុំដែលនៅនោះ គេថាស់ៗហ្នឹងគេថា នេះមួយ នួន ជា, នេះមួយ តាសុន សេន អីចឹងណ៎ា ហើយខ្ញុំចេះតែនេះទៅ ចំណាំតាមគេនឹងទៅ។ ប៉ុនដល់មកមើលរូបថតនេះវាខុស បាទ មើលរូបថតនេះខុស ខុសកាលដែលខ្ញុំមើល កាលលើកមុនបាទ។

**ស៖** បាទ ខ្ញុំសូមចូលសួរលោកនូវរូបថតទី២។ ប្រហែលជារូបថតទី២ នេះវាច្បាស់ជាងហើយនៅក្នុងរូបថតទី២ នេះក៏មានមនុស្សម្នាក់ដែលខ្ញុំចង់សួរលោកផងដែរ ក្រែងលោកស្គាល់។ លោកប្រធាន គឺ<ខ្ញុំចង់សំដៅទៅលើ>ឯកសារ E3/3250 ដែលមាន ERN P00416551។

បាទ សូមការអនុញ្ញាតបញ្ចាំងរូបថតនេះ នៅលើអេងក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<គ្រាន់តែជាការកត់សម្គាល់ទូទៅរបស់ខ្ញុំ ពីព្រោះខ្ញុំគាត់ថា ការបង្ហាញនេះដូចជាលឿនជាងរាល់ដង។> គឺពេលដែលដាក់រង្វង់ពណ៌ក្រហមបង្ហាញហ្នឹងណ៎ា កុំអាលទាន់ដាក់ គឺចាំពេលរហូតដល់ពេលសួររួចរាល់សិន សឹមដាក់អាពណ៌ក្រហមសួរបញ្ជាក់។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកស្រីចៅក្រម ខ្ញុំធ្វើដូច្នេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំនឹងជួយរំឭកដល់ការចងចាំ<របស់លោក>បន្តិចនៅត្រង់នេះ <>មនុស្ស

មួយក្រុមនៅក្នុងរូបថតនេះ ជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ដែលបានថតនៅឯព្រលានយន្តពោធិ៍ចិនតុង<។> ឥឡូវ ខ្ញុំចង់សួរលោកពីខាងស្តាំទៅឆ្វេង អ្នកដែលនៅខាងស្តាំគេ ហើយបង់កក្រមានេះ គឺប៉ុល ពត ហើយបន្ទាប់ ប៉ុល ពត គឺ នួន ជា។ បន្ទាប់ពី នួន ជា គឺ សោ ភឹម ហើយបន្ទាប់មកយើងឃើញ អៀង សារី បន្ទាប់មកទៀត វន វ៉េត ហើយបន្ទាប់មកទៀតគឺ កុយ ធួន ហើយបន្ទាប់មកបានឃើញបុរសម្នាក់រាងមាឌល្អិតបន្តិចនេះ នៅខាងឆ្វេង។

[១៣:៥២:០១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ ខ្ញុំមិន<យល់ច្បាស់>ពីគោលបំណងនៃការបង្ហាញឈ្មោះរបស់អ្នក<ទាំងអស់>ដែលនៅក្នុងរូងថតនេះ<ទេ>។ លោកកំពុងតែផ្តល់សក្ខីកម្មខ្លួនឯង ឬក៏ចង់ឲ្យសាក្សីផ្តល់សក្ខីកម្ម? ខ្ញុំគិតថា <បើសិនជាលោកចង់ឲ្យសាក្សីផ្តល់សក្ខីកម្ម> លោកគួរតែទុកឲ្យ<សាក្សី>ឆ្លើយប្រាប់យើងវិញ <ហើយសួរគាត់>ថាអ្នកនេះឈ្មោះអីនៅលើរូបថតនេះ យើងមិន<មែនមកទីនេះដើម្បី>ចាំស្តាប់លោកទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសាកសួរគាត់នេះ ជជីកសាកសួរចង់ដឹងថា គាត់ស្គាល់បុគ្គលម្នាក់មាឌល្អិតបន្តិចនៅខាងឆ្វេងទេ តែប៉ុណ្ណោះទេ។ <អ្នកផ្សេងទៀត យើងបានស្គាល់ច្បាស់អស់ហើយ។> បាទ អ៊ីចឹងខ្ញុំមិន -- នឹងមិន<ឲ្យគាត់>បញ្ជាក់អត្តសញ្ញាណអ្នកនេះ គ្រាន់តែជួយទៅគាត់បន្តិចតែប៉ុណ្ណោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ចំណាប់អារម្មណ៍របស់ខ្ញុំនោះ គឺខ្ញុំចង់ដឹងអំពីបុរសដែលមានមាឌល្អិតបន្តិច<ដែល>ឈរនៅខាងឆ្វេង គាត់ក៏មានបង់កក្រមាដែរ <តើ>លោកស្គាល់ទេ បុរសដែលមានល្អិតនៅខាងឆ្វេងនេះ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ដូចអត់ស្គាល់ផង ដល់មើលរូបថតអត់ស្គាល់ រូបថត មនុស្សស្គាល់ ដល់មើលរូបថតអត់ស្គាល់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៥៣:៣៤]

**ស៖** ប្រហែលជាមិនអាច<ទៅរួចទៀត>ទេ។ ចុះលោកស្គាល់មនុស្សម្នាក់ឈ្មោះ ភួង ដែរ ឬទេ? ភួង ជាប្រធានចម្ការកៅស៊ូ ជាសមាជិក<គណៈមជ្ឈិម> ហើយក៏ជាមនុស្សដែលឋានៈលេខ២ នៅភូមិភាគបូព៌ានោះដែរ។ អ៊ីចឹងលោកស្គាល់ឈ្មោះ ភួង ដែរឬទេ?

**ឆ៖** បាទ លោកខ្ញុំមិនស្គាល់ទេ ភួង នោះបាទ។ មិនដែលឃើញមុខ បើទុកជាជួបក៏មិនស្គាល់ដែរ បើគេមិនប្រាប់ ទាល់តែមានគេប្រាប់បានស្គាល់បាទ។

**ស៖** មិនថ្វីទេលោកសាក្សី សូមអរគុណ។ លោកប្រធាន ខ្ញុំក៏សូមការអនុញ្ញាតបង្ហាញនៅរូបថតទី៣ ជាចុងក្រោយនេះផងដែរ ដើម្បីសួរមើលថា តើគាត់អាចនឹងស្គាល់អ្នកណានៅក្នុងរូបថតនេះខ្លះដែរឬទេ? យើងខ្ញុំក៏សូមការអនុញ្ញាតបញ្ចាំងនៅលើអេក្រង់ផងដែរ ហើយខ្ញុំមានរូបថត មួយសន្លឹកដែលបានមកពីភាពយន្តឯកសារពីខាងដើមនេះ ដែលបានយកមកសួរសាក្សី<ផ្សេង>មកពីភូមិភាគបូព៌ានេះគឺ E3/3015R ហើយមានបុគ្គលម្នាក់ដែលយើងអាចមើលឃើញ គឺថាយើងមើលឃើញរូបគាត់ហ្នឹងក្នុង រយៈពេល១នាទី៥៣វិនាទី។ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើយើងមានត្រៀមដាក់បញ្ចាំងនៅលើអេក្រង់ហើយឬនៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ រួចរាល់ហើយ។

[១៣:៥៦:០៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកស្គាល់គាត់ទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំដូចមិនស្គាល់ទេ។ ខ្ញុំស្រពេចស្រពិលរូបហ្នឹង ខ្ញុំមិនដូចមិនស្គាល់ទេ។ មិនបានស្គាល់ទេរូបនេះ។ ដល់រូបថត ហើយមកឥឡូវវាខុសគ្នាឆ្ងាយ។ មនុស្សភាគច្រើនវាជួបគ្នា ជួបហ្នឹងស្គាល់តែមុខហ្នឹង បើថា ហើយមុខហ្នឹងមិនដឹងថានៅឯណា តួនាទីអី។ ហ្នឹងអត់ដឹងដែរ។ ព្រោះមិនបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្លាប់រស់នៅជិតស្និទ្ធ ហើយយូរដល់ជួបរយៈពេលខ្លី មួយភ្លែតម៉ាអ៊ីចឹង ចំណាំមិនបានទេ។ បាទ សូមអស់យោបល់។

**ស៖** តើបុគ្គលរូបនេះ អាចជាបុគ្គលម្នាក់ដែលលោកបានឆ្លើយច្រើនមកហើយ ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺហេង សំរិន<>?

**ឆ៖** ហើយណាមួយ គាត់នៅក្មេង។ ដល់គេថតអ៊ីចឹង មើលទៅក្មេង។ ដល់អ៊ីចឹង ចាស់។ ដល់ឥឡូវ ចាស់ មិនដឹង បាទ កាលហ្នឹង គាត់នៅក្មេង ដល់ជួបអាពេលជួបខ្ញុំបាទហ្នឹង គាត់អង្គាល់ហ្នឹង ដូចជារាងចាស់។ អង្គាល់ដល់ ក្មេង ហើយនិងចាស់ ហើយជួប យូរៗជួបម្ដងអ៊ីចឹងមិនសូវជាស្គាល់ទេ នៅក្នុងរូបថត។ ទាល់តែបញ្ជាក់ច្បាស់លាស់ថា អត្តសញ្ញាណអ្នកណាៗនុ៎ង បានស្គាល់។ ថាដល់យើងគ្រាន់តែមើលរាវ ហើយប្លែកគ្នាយូរហើយហ្នឹង មិនស្គាល់ មិនបានស្គាល់ មិនចាំ មិនចំណាំបានច្បាស់លាស់ទេ បាទ ទាល់តែប្រាប់ឈ្មោះបានដឹងបាទ។ បាទ សូមអស់យោបល់។

[១៣:៥៨:៤៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរសំណួរបញ្ជាក់មួយសំណួរ។ តើលោកកំពុងតែនិយាយថា <> "រូបនេះ មិនមែនជាហេង សំរិន ទេ"<> ឬក៏លោកថា "ខ្ញុំមិនស្គាល់<ថា រូបនេះគឺជា>គាត់ទេ" តើលោកកំពុងតែឆ្លើយសំណួរណាមួយ ឥឡូវនេះ?

**លោក ស៊ិន អ៊ឹង៖**

បាទ ខ្ញុំថាមើលទៅក្នុងរូបថត ខ្ញុំមិនស្គាល់ទេ តែបើប្រាប់ឈ្មោះថា ហ្នឹងរូបថតពិតជាគាត់ហ្នឹងមែន។ អាហ្នឹង វាស្គាល់ហើយ។ សូម្បីតែ នែ៎ ប្លែកយូរហើយ ដល់ទៅវាភ្លេច។ ដល់ពេលឥឡូវ ដល់គាត់ប្រាប់ថា ហេង សំរិន ហ្នឹង--

**ប្រធានអង្គជំនុំ៖**

មិនមែនសំណួរ មិនមែនអ៊ីចឹងទេ! សំណួរសួរថា រូបថតហ្នឹង ដែលលោកបានមើលឃើញហ្នឹងរូប ហេង សំរិន ឬក៏មិនមែនទេ? ពីមុន គេសួរថា តើលោកស្គាល់ថា រូបថតនេះ ជារូបអ្នកណាទេ? អ្នកណាគេ? លោកថាអត់ស្គាល់ទេ។ ហើយក្រោយមក សួររូបថតនេះ វាទំនង គ្រាន់តែទំនងទេ ដែលគេខាងណោះ មិនមានមូលដ្ឋានអីដែរទេ។ គ្រាន់តែសួរថា តើវា រូបហ្នឹង បើតាមលោកចំណាំបានទេ លោកហេង សំរិន មែនដែរឬទេ? តែប៉ុណ្ណឹងតើ! មែន ឬក៏មិនមែនទេ? លោកមិនអាចឆ្លើយពាក់កណ្ដាលទី

អ៊ីចឹងទេ។ លោកស្គាល់ទេ? ចេះឆ្លើយទេ? អាសំណួរថា ឆ្លើយថា មែន ឬមិនមែនហ្នឹង តែប៉ុណ្ណឹងទេ។ បើលោកមិនច្បាស់ គឺស្មើមិនមែនហើយ។

**លោក ស៊ិន អ៊ុំង៖**

**ឆ៖** បាទ សុំទោស ខ្ញុំបាទមិនច្បាស់ដែលរូបនុ៎ង ប៉ុនមិនដឹងថាប្រាកដជារូប ហេង សំរិន ទេ។ ប៉ុនខ្ញុំមើលមិនស្គាល់ទេ រូបនេះ។ មិនដឹងថា រូបគាត់ ឬក៏រូបអ្នកណា ក៏ខ្ញុំមិនដឹង ព្រោះខ្ញុំវាអត់ស្គាល់ក្នុងរូបថត។ វាអត់ច្បាស់ បាទ។

[១៤:០០:៣៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មិនថ្វីទេ លោកសាក្សី។ <ប៉ុន្តែឥឡូវនេះ យើងស្ថិតនៅលើសាច់រឿងនេះ> នៅក្នុងចម្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយអំពី ហេង សំរិន នេះជាច្រើនលើកច្រើនសា។ ហើយលោកបានឆ្លើយថា គាត់គឺជាមេបញ្ជាការកងពលលេខ៤ ដែលឈរជើងនៅឯមេមត់។ ហើយលោកថា គាត់គឺជាសមាជិកសេនាធិការភូមិភាគបូព៌ា។ លោកនៅចាំទេថា លោកបានឆ្លើយយ៉ាងដូច្នេះទៅមជ្ឈមណ្ឌលឯកសារកម្ពុជា?

**ឆ៖** បាទ ខ្ញុំនៅចាំដែរ។ កាលហ្នឹងគាត់សួរខ្ញុំអ៊ីចឹងមែន។ បាទ ខ្ញុំចាំ។ កាលហ្នឹងគាត់នៅកាន់កងពលនៅមេមត់មែន។ ខ្ញុំបានឆ្លើយអ៊ីចឹងមែនបាទ ព្រោះខ្ញុំទៅដល់គាត់។ បាទ សុំអស់យោបល់ចម្លើយ។

**ស៖** ខ្ញុំនឹងមកសួរអំពីគាត់នេះឡើងវិញនៅពេលក្រោយ។ ឥឡូវនេះខ្ញុំចូលទៅសួរអំពី សោ ភឹម សិន។ លោកក៏បានលើកឈ្មោះសមាជិកគ្រួសារ សោ ភឹម យកមកនិយាយផងដែរ ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា <ហើយខ្ញុំចាប់អារម្មណ៍នូវអ្វីដែលលោកបាននិយាយ>។ ឥឡូវនេះខ្ញុំសុំចូលសួរប្រពន្ធរបស់ សោ ភឹម គឺយាយការ៉ូ។ តើលោកនៅចាំ អាចប្រាប់អង្គជំនុំជម្រះបានអ្វីខ្លះដែរ អំពីប្រពន្ធរបស់ សោ ភឹម គឺយាយការ៉ូ នេះ?

**ឆ៖** ខ្ញុំចាំបាន យាយការ៉ូ គាត់ ខ្ញុំ -- ព្រោះខ្ញុំនៅនុំជាប់ជាង១០ថ្ងៃនៅកន្លែងគាត់ហ្នឹង ហើយឧស្សាហ៍ចុះឡើង មកដេកមួយយប់អី ឧស្សាហ៍មកដែរ។ ប្រពន្ធគាត់ហ្នឹង ខ្ញុំបានដឹង បានស្គាល់ បាទ។

[១៤:០២:៥២]

**ស៖** លោកសាក្សី នៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា អង់គ្លេស <0135

3324>, ខ្មែរ 01340545 លោកបានឆ្លើយថា យាយការ៉ូ និង សោ ភឹម ហ្នឹងមានមន្ទីរផ្សេងពីគ្នា។ យាយការ៉ូ នៅឯ<ការដ្ឋានកសិដ្ឋាន> ហើយ តាសោម ភឹម នោះនៅមន្ទីរភូមិភាគ។ ហើយមានមន្ទីរការពារផ្សេងទៀត ហើយគាត់នៅកន្លែងមន្ទីរការពារហ្នឹងទៅ។ តើត្រឹមត្រូវអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ គឺត្រឹមត្រូវអ៊ីចឹងមែន បាទ។

**ស៖** ហើយតើត្រឹមត្រូវដែរឬទេ ដែលថា យាយការ៉ូ ហ្នឹងគឺជាប្រធានកសិដ្ឋានមួយនៅភូមិភាគបូព៌ា?

**ឆ៖** បាទ យាយការ៉ូ ហ្នឹងគាត់គឺឈ្មោះគាត់មន្ទីរកសិដ្ឋានផង់គាត់ហ្នឹង ឃើញតែគាត់នៅហ្នឹង។ ដល់គាត់នោះ គាត់ប្រធានហើយបានគាត់ចាំមួយកន្លែងហ្នឹង ទោះពីណាក៏គេកោតគោរពគាត់ដែរ ប្រធានដែរ នៅកន្លែងនុ៎ង កន្លែងកសិដ្ឋានហ្នឹង។ អ្នកណាក៏គេខ្លាចគាត់ដែរនៅជំនាន់នុ៎ង ព្រោះគាត់ប្រធានហើយ គាត់លើគេហើយ។ គាត់ប្រាប់គេថា ធ្វើអ៊ីចឹងធ្វើអ៊ីចុះ ហើយគេទៅធ្វើតាម មានតែគាត់ប្រធាន។ បាទ ប៉ុណ្ណឹង ខ្ញុំដឹងប៉ុណ្ណឹង បាទ។

**ស៖** តើត្រឹមត្រូវដែរឬទេថា យាយការ៉ូ គឺជាសាច់ឈាមជាមួយនឹងតា ជា ស៊ីម?

**ឆ៖** អារឿងថាជាប់សាច់ញាតិតា ជា ស៊ីម អានេះមិនដឹងទេគ្រាន់តែថាភូមិនៅភូមិនុ៎ងជាមួយគ្នាត្រង់សាច់ញាតិអីអាហ្នឹងខ្ញុំមិនសូវដឹងច្បាស់ដែរ ព្រោះវាឆ្ងាយពីគ្នាណាស់។ ហើយបើថាជាប់សាច់ជាប់អីនេះ អាហ្នឹងមិនដឹងទេ ប៉ុន្តែបើថាភូមិជាមួយគ្នា ឮគេថា ជា ស៊ីម ស្រុកនៅហ្នឹងដែរ ដែលអ្នកកាសែតចេះតែសួរខ្ញុំ អ៊ីចឹងខ្ញុំថានៅនុ៎ងដែរប្រហែលជាភូមិជាមួយគ្នាយ៉ាង។ បាទ តែប៉ុណ្ណឹង។

[១៤:០៥:៣៩]

**ស៖** បាទ សួរបន្តអំពីតា ជា ស៊ីម។ តើលោកបានឃើញ ជា ស៊ីម ញឹកញាប់ដែរឬទេនៅចន្លោះពេលពីឆ្នាំ៧៥ ទៅដល់ ថ្ងៃទី២៥ ឧសភា ១៩៧៨ លោកធ្លាប់បានឃើញគាត់ញឹកញាប់ដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ជួបគាត់បីដង។ បាទ ខ្ញុំទៅស្ទឹង១ហ្នឹង ទៅការពារ តា សោ ភឹម – តា សោ ភឹម ក៏ចូលទៅនុ៎ង ចូលទៅផ្ទះនៅកន្លែងស្ទឹងហ្នឹងបាទ។ បានទៅបីដង កន្លែងនោះផ្ទះត្រង់នុ៎ងដូចតែផ្ទះមានឈើព្រៃដូចតែទើបតែកាប់ឈើ កាប់អីធ្វើសង់ឈើធម្មតា ផ្ទះតូចដែរ។ ចប់ឃោបល់ហើយ។

**ស៖** លោកបាននិយាយចំនួនបីដងជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកថា លោកបានទៅផ្ទះ តា ជា ស៊ីម ហ្នឹងញឹកញាប់ដែរ។ នៅក្នុងចម្លើយរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកថា សោ ភឹម នេះក៏បានទៅផ្ទះរបស់តា ជា ស៊ីម<ដែរ>។ គឺ ERN 01353319 ហ្នឹងជាភាសា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អង់គ្លេស, ខ្មែរ 01340542 លោកថា "សោ ភឹម នេះគឺថាបានទៅជួបជាមួយនឹងតា ជា ស៊ីម នេះជាញឹកញាប់"។ តើលោកពិតជាបានឆ្លើយថាអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំពិតជាឆ្លើយអ៊ីចឹងដែរមែនបាទ ញឹកញាប់មែន។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា សោ ភឹម និង តាជា ស៊ីម ហ្នឹងជួបគ្នាញឹកញាប់បានប៉ុនណាដែរ? ហើយបើជួបញឹកញាប់ហ្នឹងជួបនៅឯណា?

**ឆ៖** បាទ គាត់ជួបនៅអាផ្ទះកន្លែងខ្ញុំ ថានៅស្ទឹងហ្នឹង ភូមិស្ទឹងហ្នឹង ទៅកន្លែងហ្នឹង។ ក្រៅពីហ្នឹង--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ! អត់សំឡេង ខ្ញុំស្មានថាផន់ខ្ញុំអស់ថ្ម។

*(សម្រាករយៈពេលខ្លី)*

[១៤:០៨:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ លោកសាក្សីសូមឆ្លើយតប បើសិនជាលោកនៅចាំសំណួរ។

**លោក ស៊ិន អ៊ីង៖**

**ឆ៖** បាទ ជួបនៅផ្ទះគាត់ហ្នឹង ទៅផ្ទះគាត់ហ្នឹង ហើយជួនក៏តាហ្នឹងក៏គាត់មកលេងដល់កន្លែងមន្ទីរការពារដែរ គាត់មកដែរ តែកិច្ចការគាត់មកមានការអីហ្នឹងក៏ ខ្ញុំមិនសូវដឹងដែរ ព្រោះគាត់ជំនុំគ្នាប៉ុនគ្រាន់ថាគាត់មកហ្នឹង ជាមួយជំនុំជម្រះគ្នានឹងគាត់ហ្នឹង ប៉ុនគ្រាន់មិនដឹងជំនុំពីសាច់ការអីដែរ ខ្ញុំគ្រាន់តែនៅខាងក្រៅ។ បាទ ប៉ុណ្ណឹង។

**ស៖** លោកបានឆ្លើយទៅនឹងសំណួរបន្ទាប់ខ្ញុំរួចទៅហើយ ប៉ុន្តែសំណួរចុងក្រោយអំពីលោក ជា ស៊ីម លោកបានប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់ហ្នឹងគឺជាចៅហ្វាយស្រុកពញាក្រែក លោកឆ្លើយថាអ៊ីចឹង ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ គាត់ឆ្លើយ គាត់ចៅហ្វាយស្រុកពញាក្រែកមែនជំនាន់នោះបាទ។

**ស៖** តើលោកធ្លាប់មានធ្វើកិច្ចការអ្វីជាមួយ ជា ស៊ីម ដែរឬទេ? ឬក៏ថា លោកបានឃើញ ជា ស៊ីម នេះ ដោយសារតែលោកនៅជាមួយនឹងចៅហ្វាយរបស់លោក គឺ សោ ភឹម?

[១៤:១០:២៣]

**ឆ៖** បាទ ខ្ញុំមិនដែលជិតដិតអីនឹង ជា ស៊ីម ទេ គ្រាន់តែខ្ញុំដែលឃើញគាត់ ដោយសារខ្ញុំនៅជាមួយ តា សោ ភឹម ហ្នឹង បាទ ដោយសារគាត់ទៅៗ ជួបគ្នាហ្នឹងអីចឹងទៅ។ ហើយតា សោ ភឹម ហ្នឹងក៏គាត់ទៅលេងនុ៎ងទៅ។ ដល់ខ្ញុំជាការពារគាត់នុ៎ង ទៅហ្នឹង ជួបដោយសារអីចឹងទេ។ បាទ សូមចប់យោបល់ ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចូលសួរអំពីកូនៗរបស់ សោ ភឹម។ តើលោកមាននៅចាំឈ្មោះកូនៗរបស់ សោ ភឹម ដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាននៅចាំដែរ បាទ នៅចាំឈ្មោះកូន សោ ភឹម ហ្នឹង គ្រាន់តែចាំឈ្មោះ ប៉ុនឥឡូវមិនដែលឃើញទេ ស្លាប់បាត់អស់ហើយ។ ឈ្មោះ-- ១) ឈ្មោះ ណាត ២) ឈ្មោះ ស៊ី ៣) ឈ្មោះ តាដេវ ៤) ឈ្មោះ យុច។ យុច នោះនៅកុមារ ប្រហាក់ប្រហែលតែខ្ញុំដែរ កាលនុ៎ង យុច នុ៎ង គេហៅតែ អាយុចៗហ្នឹង ប្រុស។ ប្រុសពីរ ស្រីពីរ ខ្ញុំចាំបានតែបួន កូនគាត់បួននាក់ហ្នឹង។ បាទ ប៉ុណ្ណឹង។

**ស៖** <លោកពិតជាបានពន្យល់ក្បោះក្បាយពីកូនៗរបស់គាត់> តើត្រឹមត្រូវដែរឬទេ <ដែលថាឈ្មោះ> ណាត នេះ គឺជាប្រធានមន្ទីរពេទ្យ ព-២ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ជំនាន់នុ៎ង គាត់ជាប្រធានពេទ្យ ព-២ មែន បាទ នៅខាងអូររាំងឪហ្នឹង បាទ។

**ស៖** លោកក៏លើកឈ្មោះ ស៊ី យកមកនិយាយដែរ។ លោកដឹងទេ នៅពេលហ្នឹង ស៊ី រៀបការ <ជាមួយអ្នកណាដែរ>?

[១៤:១២:៣៩]

**ឆ៖** បាទ កាលដែល ស៊ី ហ្នឹង ខ្ញុំមិនបានឃើញឈ្មោះទេ តែបងប្អូនគេហ្នឹង និយាយប្រាប់ខ្ញុំព្រោះខ្ញុំនៅនុ៎ង អាយុច អាអីហ្នឹង វានិយាយឈ្មោះ ពីព្រោះគេការមុនខ្ញុំទៅហ្នឹង ប្រហែលជាប្អូនដប់ថ្ងៃមុនហ្នឹង គេការចេញទៅ ហើយបានខ្ញុំទៅពីក្រោយ។ ដល់ទៅហ្នឹង ស៊ី រៀបការហើយ មកទៅ មកខាងប្តីបាត់ទៅ។ ខ្ញុំមិនទាន់ឃើញទេ ប៉ុន្តែគ្រាន់ថាបងប្អូននៅតែនិយាយ ស៊ី និយាយអីៗថា បងប្អូនមានប៉ុណ្ណឹង បាទ។

**ស៖** តើ ស៊ី រៀបការជាមួយនឹងកូនប្រុសរបស់ប្រធានភូមិភាគៗពាយ័ព្យ <ឈ្មោះ រស់ ញឹម> មែនទេ? លោកដឹងថា អីចឹងមែនទេ?

**ឆ៖** បាទ គាត់រៀបការមកកូនគណៈភូមិភាគពាយ័ព្យមែន ពីព្រោះតានុ៎ង គាត់ដល់អ្នកចាស់ៗនៅមន្ទីរជាមួយខ្ញុំនុ៎ង គេនិយាយថា ហ្ន៎! តា រស់ ញឹម ប្រធានភូមិភាគពាយ័ព្យហ្នឹង គាត់មកលេងដន្លង

គាត់ ឪក្មេកបង ស៊ី។ អ្នកនៅមន្ទីរន្ទុំងគេនិយាយអ៊ីចឹងពិតប្រាកដមែន បាទ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍នោះ គឺថាលោកអត់ចាំឈ្មោះកូនប្រុសរបស់ រស់ ញឹម ទេ។ ចុះបើខ្ញុំសួរលោកថា មានមនុស្សម្នាក់ឈ្មោះ ជាល លោកស្គាល់ទេ?

**ឆ៖** បាទ ជាល ខ្ញុំមិនស្គាល់ទេ បាទ អត់ដែលស្គាល់ទេ។

**ស៖** ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានឆ្លើយថា <កូនប្រុសរបស់> ស៊ី និង <>រស់ ញឹម <ឈ្មោះថា>ជាល ឬក៏ហៅ<ថា> អាឆ្នាំង <ហើយ>ពួកគេ<បាន>រៀបការនៅក្នុងឆ្នាំ ១៩៧៦ តើលោកនៅចាំទេ លោកបានឆ្លើយថា អ៊ីចឹង?

[១៤:១៥:00]

**ឆ៖** បាទ ពីព្រោះការហ្នឹង នៅ បាទ ដែលការនៅឆ្នាំន្ទុំង ព្រោះអ្នកដែលមកការនៅជំនាន់ហ្នឹង នៅដែរក្បែរផ្ទះខ្ញុំ បងជីដូនមួយខ្ញុំ ក៏មកការនៅហ្នឹងដែរ ក៏មករៀបការនៅហ្នឹងដែរ ការជាមួយគ្នាហ្នឹង។ ខ្ញុំនៅចាំបានប៉ុណ្ណឹង។ ឥឡូវគាត់នៅហ្នឹងដែរ ការរបស់គាត់ ប្ដីគាត់ស្លាប់ទៅ ប្រពន្ធដែលប្រធានការពារ ប្រាក់ ជឿក ប្រធានការពារខ្ញុំហ្នឹង ប្រពន្ធគាត់នៅដែរឥឡូវ។ គាត់មកការជាមួយគ្នាហ្នឹងដែរ។ បាទ ខ្ញុំនៅចាំប៉ុណ្ណឹង។

**ស៖** លោកកំពុងនិយាយថា ស៊ី នៅរស់ ឬក៏លោកច្រឡំជាមួយនឹងកូនស្រី<មួយទៀត>របស់ សោ ភឹម ដែលនៅរស់ដែរនោះ ឈ្មោះ <>ក្ដេវ នេះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំ<សូមស្នើ>ឲ្យ<លោកមេធាវី>សួរសំណួរជាជាងការផ្ដល់ចម្លើយ<។ គាត់កំពុងតែ>ផ្ដល់សក្ខីកម្មថា អ្នកណានៅរស់ ឬមិននៅរស់នោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ឬមួយក៏>សូមឲ្យលោកផ្ដល់<ឯកសារ>យោង<ឲ្យយើង>ផងនៅពេលដែលលោក<លើកយកឈ្មោះមកសួរគាត់នោះ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអត់បានផ្ដល់សក្ខីកម្មខ្លួនឯងទេ ខ្ញុំគ្រាន់តែដកស្រង់ចេញពីសំណុំរឿង។ <ខ្ញុំមានឯកសារយើង

ដែលថា> ក្តេវ ហ្នឹងគឺនៅរស់។ គឺនៅក្នុងចម្លើយរបស់សាក្សី 2-TCW-1070 នៅក្នុងបទសម្ភាសន៍របស់គាត់ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ <សូមជម្រាបលោកប្រធាន> ជាភាសាអង់គ្លេស ខ្ញុំមានគឺ 01354173*(ស៊ីក)* ពេលនោះ គឺសួរថា <"តើកូននោះឈ្មោះអ្វី?" គាត់ឆ្លើយថា "ឈ្មោះក្តេវ"> "ឈ្មោះក្តេវ ហ្នឹង នៅរស់មែនទេ? គាត់ឆ្លើយថា បាទ គាត់នៅរស់ គឺនៅភ្នំស្រុក"។ ហើយ <មុននេះបន្តិច>យើងក៏បានស្នើដាក់ចូលជាភស្តុតាងនូវកិច្ចសម្ភាសន៍ ដែលគាត់បានផ្តល់ជូននូវកាសែតខ្មែរមួយឈ្មោះថា "រស្មីកម្ពុជា" <ប៉ុន្តែ>សំណើរបស់យើងត្រូវបានបដិសេធ។ ហើយក្នុងហ្នឹង យើងដឹងថា គាត់នៅរស់ទេ កូនស្រីម្នាក់នេះនោះ <ដោយសារគាត់ទើបតែផ្តល់កិច្ចសម្ភាសន៍ថ្មីៗនេះ>។ អ៊ីចឹងលោកប្រធាន អនុញ្ញាតឱ្យខ្ញុំបន្តទៅទៀតទេ?

**ស៖** លោកសាក្សី ប្រហែលជាលោក ច្រឡំ ស៊ី ហើយនិងក្តេវ អ្នកណាដែលនៅរស់ពិតប្រាកដនោះ?

[១៤:១៧:៥៦]

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ រឿងនៅរស់ មិននៅរស់ ខ្ញុំដឹងតែឈ្មោះ ក្តេវ ហ្នឹងដែលពេលខ្ញុំឃើញបាត់ៗពីគ្នារហូតដល់ឥឡូវហ្នឹង បើថា ឱ្យតែនៅរស់ ដូចមិនដឹងដែរ រឿងរស់រឿងស្លាប់។ ប៉ុន ស៊ី ហើយនិង ក្តេវ, ស៊ី នោះផ្សេង។ ស៊ី នោះជាកូនប្រហាររបស់ តាញឹម រស់ បើ តាដេវ នោះនៅ នៅជាមួយម៉ែឪ នៅហ្នឹងទួលសំរោងហ្នឹង។ ដល់ពេលក្រោយមកទៅបាត់ បែកបាក់គ្នាបាត់ទៅ ហើយរត់រសាត់រសាយទៅ ខ្ញុំក៏មិនថានៅរស់ដែរទេ បាទ។ រស់មិនរស់ ខ្ញុំអត់ដឹងទេបាទ។ ប៉ុនថា ស៊ីផ្សេង តាដេវផ្សេង។ ខ្ញុំដឹងតែ តាដេវ ទេ បើស៊ី ហ្នឹងដឹងហ្នឹង ដឹងថា នៅជាមួយគ្នានៅទួលសំរោងហ្នឹងបាទ អ៊ីចឹង។ ដល់ពេលក្រោយមក ខ្ញុំអត់ដឹងទេ។ សូមចប់យោបល់។

**ប្រធានអង្គជំនុំ៖**

ឈ្មោះអីពិតប្រាកដ? ឈ្មោះ ក្តេវ អ៊ីចឹង ឬក៏ឈ្មោះ កាដេវ នៅក្នុងឯកសារដែលគេដាក់មក គឺឈ្មោះ កាដេវ ទេហើយហៅឱ្យវាសមរម្យបន្តិចទៅ ឈ្មោះ ដល់ពេលហៅ ក្តេវ ដាច់សាច់ពេក។ ហើយឈ្មោះយ៉ាងម៉េចពិតប្រាកដ តាមលោកចាំ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំចាំ នៅកន្លែងនោះ គេហៅតែ តាដេវ ៗៗ អ៊ីចឹងតែម្តង។ ម៉ែគាត់ យាយ ក៏ហៅអ៊ីចឹងដែរ។ បាទ សូម្បីតែយាយការ៉ូ ម៉ែតាដេវ ក៏ហៅ តាដេវៗៗអ៊ីចឹងតែម្តង ហើយដល់នេះ ខ្ញុំចាំឈ្មោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តែ តាដេវ អ៊ីចឹងតែម្តង។ តែឈ្មោះពិតប្រាកដ គេមិនដឹងគេឈ្មោះអី។ ប៉ុន្តែដឹងថា ឈ្មោះគេហៅក្រៅ ហៅតែអ៊ីចឹង បាទ។ ខ្ញុំចាំតែប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

<សូមអរគុណ> តាម<ការយល់ឃើញរបស់>ខ្ញុំ<អំពីចម្លើយរបស់សាក្សី ខ្ញុំគិតថា> សាក្សី គាត់និយាយដូចជា មានការច្រឡំ<នៅពេលដែលគាត់ត្រូវបានសួរអំពីការរៀបការ។> គាត់និយាយថា គាត់ឮពីគេ ហើយនិយាយថា "គាត់នៅរស់" <បន្ទាប់មកទៀតគាត់ពន្យល់ពីប្រពន្ធរបស់ប្រធានមន្ទីរ ការពារ> ពាក់ព័ន្ធនឹងឈ្មោះ <តាដេវ> នេះ គាត់ដូចអត់មាននិយាយពីឈ្មោះ ស៊ី ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អាចអ៊ីចឹងដែរ ប្រហែលជាកំហុសខ្ញុំ។

[១៤:២០:២៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំចាប់អារម្មណ៍ខ្លាំងទៅលើឈ្មោះ ស៊ី ដែលរៀបការជាមួយនឹង ជាល នៅក្នុងបទសម្ភាសលោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកថា គាត់រៀបការនៅក្នុងឆ្នាំ៧៦ <ហើយលោកថា វានៅក្នុងរដូវភ្លៀង>។ អ៊ីចឹងលោកសង្កេតឃើញដោយផ្ទាល់ពេលនុ៎ង ពេលគាត់ការហ្នឹង ឬក៏មានអ្នកណាប្រាប់លោកទេ <ថាវានៅក្នុងរដូវភ្លៀងហ្នឹង>?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំការហ្នឹង ខ្ញុំដូចខ្ញុំនិយាយខាងដើម ថាខ្ញុំមកអត់ទាន់គេការទេ។ ព្រោះគេការបានប្រហែលជា១០ថ្ងៃ បានខ្ញុំមកពីក្រោយ ហើយអារោងការ គេមិនទាន់រុះទេ។ ខ្ញុំមកដល់ហ្នឹងឃើញរោងធំណាស់ ខ្ញុំនៅដេកលេងតែអាក្រោមរោងគេការហ្នឹង កាលដែលខ្ញុំមកដល់ហ្នឹង។ ខ្ញុំដឹងតែប៉ុណ្ណឹង ប៉ុន្តែគេការខ្ញុំមកអត់ទាន់បាទ មិនឃើញច្បាស់រូប ឈ្មោះ ឮតែឈ្មោះហ្នឹង ប៉ុន្តែមិនឃើញរូបផង គេការហ្នឹង។ បាទ ប៉ុណ្ណឹង។

**ស៖** ខ្ញុំដឹងថា វាហួសពីការដឹងឮរបស់លោក ក៏ប៉ុន្តែ<វាពិតជាសំខាន់ណាស់ដែល>យើងចង់ដឹងឲ្យបានច្បាស់ថា តើ ស៊ី និង ជាល ឬ ឆ្នាំង អ្នករៀបការនៅពេលណាឲ្យប្រាកដ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។

លោកប្រធាន ខ្ញុំយោងទៅលើឯកសារ E3/10665 ដែលជាប្រតិចារឹកនៃបទសម្ភាសន៍ ដែល រ៉ូបឺត លឹមគិន បានសម្ភាសជាមួយនឹងសាក្សីឈ្មោះ <ទាត់ ធឿន> ជាភាសាអង់គ្លេសគឺ 01151760, ជាភាសាខ្មែរ 01168447, <ទាត់> ជាកូនចិញ្ចឹម របស់ ញឹម គាត់ថា ស៊ី ហ្នឹងការនៅក្នុងខែ សីហា ឆ្នាំ ៧៥។ អ៊ីចឹងវាអាចទេ លោកសាក្សីថា គាត់ការនៅខែសីហា ឆ្នាំ១៩៧៥?

[១៤:២២:៥៥]

**ឆ៖** បាទ រឿងការហ្នឹង ខ្ញុំមិនដឹងទេ ដូចខ្ញុំប្រាប់ថា ខ្ញុំមកមិនទាន់ គ្រាន់តែដឹងថា គាត់ការ ធ្វើជន្លងជាមួយតារស់ ញឹម ហ្នឹង ប៉ុន្តែការថ្ងៃណាៗ ខ្ញុំមិនដឹង ព្រោះខ្ញុំមកអត់ទាន់។ ខ្ញុំអត់ដឹង កន្លែងដែលខ្ញុំដឹង បានខ្ញុំនិយាយបាទ។ អាហ្នឹងគ្រាន់តែឮពី គេប្រាប់នៅកន្លែងនុ៎ង គេប្រាប់ថា ការជន្លងជាមួយតា រស់ ញឹម ហ្នឹងកូនប្រសា។ បាទ ប៉ុណ្ណឹង។

**ស៖** សាក្សីមួយរូបទៀតដែលមកផ្តល់សក្ខីកម្ម គឺ 2-TCW-1070 គាត់នឹងមកផ្តល់សក្ខីកម្ម គាត់បានផ្តល់បទសម្ភាសន៍ គឺគាត់បាននិយាយអំពីការរៀបការរវាង ស៊ី និង ជាល នៅរកាខ្នុរ។ ខ្ញុំនឹងផ្តល់លេខ ERN នៅពេលក្រោយ។ លោកនឹកឃើញទេលោកសាក្សី ថាពួកគាត់រៀបការហ្នឹងនៅរកាខ្នុរ? បាទ គឺឯកសារ E3/10717 ERN--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេធាវីការពារក្តីនិយាយម្តងទៀត ស្តាប់អត់ទាន់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមៗអានឯកសារ លេខឯកសារសាជាថ្មីម្តងទៀត ព្រោះអ្នកបកប្រែ បកអត់ទាន់ទេ។

[១៤:២៤:៣៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ គឺឯកសារ E3/10717, ERN ជាភាសាអង់គ្លេស ខ្ញុំមានតែជាភាសាអង់គ្លេសទេ គឺទើបតែទទួលបានការបកប្រែកាលពីម្សិលមិញ គឺ 01354165*(ស៊ីក)*។ គាត់បាននិយាយថា ការរៀបការហ្នឹងប្រព្រឹត្តទៅនៅរកាខ្នុរ លោកសាក្សី លោកមាននៅនឹកឃើញទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ អារឿងថាការនៅឯណាៗនោះ ពីព្រោះខ្ញុំមិនដឹង ព្រោះខ្ញុំមកមិនទាន់។ អ៊ីចឹងការនៅឯណា ខ្ញុំមិនដឹងទេ។ ខ្ញុំទាន់តែរោងការនៅកន្លែងទួលសំរោងហ្នឹង គឺមានរោងការមែន ធំណាស់។ ការហ្នឹង។ ព្រោះគេការ មុនខ្ញុំមកប្រហែលជា១០ថ្ងៃ ខ្ញុំមកដេកនៅរោងការហ្នឹង។ ប៉ុន្តែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនដឹងការប៉ុន្មានគូៗទេជំនាន់ហ្នឹង។ ការម្តង ច្រើនណាស់ បាទ ខ្ញុំចាំតែប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

នៅសំរោងហ្នឹង នៅក្នុងភូមិសាស្ត្រអីគេ? ភូមិអី? ឃុំអី? ស្រុកអីដែរ តាមលោកចាំ?

[១៤:២៥:៥៨]

**លោក ស៊ិន អ៊ឹង៖**

បាទ លោកចៅក្រម ទួលសំរោង ពីអង្កាល់ហ្នឹងមក ខ្ញុំមិនបានដឹងច្បាស់ថា នៅក្នុងភូមិណា ឃុំណាទេ ប៉ុនស្រុក បើមិនស្រុកពញាក្រែក ស្រុកកំចាយមា បាទ ត្រង់នុ៎ងវាព្រំប្រទល់គ្នា។ បើថាឥឡូវមិនដឹងជាស្រុកណា ភូមិណាទេ ព្រោះត្រង់នុ៎ង សុទ្ធតែព្រៃដែរ គេរុក គេរាន បាទ។ អ៊ីចឹង វាអត់ដឹងចាំថា ភូមិឃុំណាជំនាន់។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវ វាច្រឡំអ៊ីចេះ ព្រោះបញ្ហា អ្នកមួយនិយាយភូមិថាការនៅភូមិ "*អ៊ុច*" ទៅ ហើយអ្នកណាមួយនិយាយថា ឃុំ។ ថានៅឃុំ "*អ៊ីហ្គារិច*" អ៊ីចឹងទៅ។ អ៊ីចឹង វាមិនច្បាស់លាស់ ព្រោះជួនកាលវាកន្លែងតែមួយ ប៉ុន្តែអានិយាយពីចំណុចតំបន់នោះ វានិយាយខុសគ្នា បានយើងសួរបញ្ជាក់នេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សាក្សី<ហាក់ដូចជា> គាត់និយាយថា គាត់មិនដឹង<ទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អ៊ីចឹង ខ្ញុំបន្តទៅមុខទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោក<មិន>នៅក្នុងពិធីរៀបការហ្នឹង<ទេ ហើយ>លោកមិនដឹងថា គេការនៅកន្លែងណាច្បាស់ទេ។ <ប៉ុន្តែតើជាការត្រឹមត្រូវទេដែលថា> ឪពុកក្មេករបស់ ស៊ី គឺ រស់ ញឹម មកភូមិភាគបូព៌ាញឹកញាប់ទេ ដើម្បីមកសួរសុខទុក្ខៗ សោ ភឹម នោះ?

[១៤:២៧:៣៥]

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ដែលខ្ញុំធ្លាប់ឃើញហ្នឹង មកបីដង បាទ។ គាត់មកតែម្នាក់គាត់។ មកដល់កន្លែងការពារហ្នឹង។ គាត់មក។ ដល់ខ្ញុំធ្លាប់ឃើញមកបីដង។ បាទ ខ្ញុំជួបតែប៉ុណ្ណឹង។

**សៈ** លោកអាចរៀបរាប់ពេលដែល រស់ ញ៉ឹម មកសួរសុខទុក្ខដន្លងរបស់គាត់នោះ គឺសោ ភឹម នៅ<មេ>ភូមិភាគ<បូព៌ា>។ លោកអាចរៀបរាប់បានទេ ថាពេលគាត់មកហ្នឹង រស់ ញ៉ឹម មកជួប សោ ភឹម ហ្នឹង គាត់ជួបគ្នានៅកន្លែងណា<ពិតប្រាកដ>ដែរ?

**ឆៈ** បាទ គាត់មកហ្នឹង ខ្ញុំនៅធ្វើការខាងក្រៅ គ្រាន់តែថា ហ្ន៎! ឡានតាដន្លងគាត់មកហើយ មកលេងហើយ គាត់ទុកឡានហើយ គាត់ក៏ដើរចូលទៅក្នុងផ្ទះទៅ មានពីណាទៅនៅក្បែរគាត់ទេ គាត់នៅតែត្រង់នុង មិនដឹងគាត់និយាយទំនាក់ទំនងអីគាត់ ព្រោះខ្ញុំនៅតែក្រៅ នៅធ្វើការនៅខាងក្រៅ មានដឹងថាគាត់និយាយពីស្អីៗទេ។ អត់ដឹងដែរ អារឿងហ្នឹង អាការណ៍ណាមិនច្បាស់ ខ្ញុំមិននិយាយ ព្រោះមិនដឹង បាទ ប៉ុណ្ណឹង។

**សៈ** <នៅពេលដែលនិយាយគ្នា> តើ រស់ ញ៉ឹម និង សោ ភឹម <ជួបគ្នាតែពីរនាក់ ឬមានអ្នកផ្សេងទៀត?>

**ឆៈ** បាទ ខ្ញុំថា ខ្ញុំអត់ដឹងថាគាត់និយាយដូចម៉េចទេ ព្រោះខ្ញុំនៅខាងក្រៅ។ បាទ ខ្ញុំសូមបញ្ជាក់ជូន គ្រាន់តែថាឃើញឡានគាត់មកហ្នឹង ដឹងដន្លងគាត់ហើយ គាត់មកចតឡាន អាកន្លែងឡាន ហើយនិងផ្ទះ គាត់ទុក នៅឆ្ងាយប្រហែលជា៥០ម៉ែត្រ។ ហ្នឹង គាត់ទុកឡានហើយ គាត់អញ្ជើញដើរចូលទៅផ្ទះដន្លងគាត់ហ្នឹងទៅ។ ហើយមិនដឹងគាត់និយាយទំនាក់ទំនងគាត់ដូចម៉េច អាហ្នឹងខ្ញុំមិនដឹងដែរ រឿងហ្នឹង។ បាទ ខ្ញុំចាំដឹងតែប៉ុណ្ណឹង។

[១៤:៣០:០០]

**សៈ** តើ រស់ ញ៉ឹម និង សោ ភឹម ហ្នឹង តែងតែជួបគ្នានៅក្នុងផ្ទះដដែលហ្នឹងឬ?

**ឆៈ** បាទ ជួបនៅផ្ទះដដែលហ្នឹង បាទ។

**សៈ** លោកអាចរៀបរាប់ពិពណ៌នាអំពីផ្ទះហ្នឹងបន្តិចបានទេ <ផ្ទះហ្នឹងនៅកន្លែងណា?> ផ្ទះហ្នឹងរូបរាងយ៉ាងម៉េចដែរ ភិនភាគផ្ទះហ្នឹង?

**ឆៈ** បាទ ផ្ទះហ្នឹងផ្ទះខ្មែរយើង។ ផ្ទះធ្វើធម្មតា នៅផ្ទះយើងបីខ្នង។ ផ្ទះហ្នឹងប្រក់ក្បឿង ធ្វើពីឈើ ជញ្ជាំងក្តារ។ ផ្ទះនៅកន្លែងការពារហ្នឹង គ្មានផ្ទះថ្មទេ សុទ្ធតែឈើទាំងអស់។ បាទ ខ្ញុំដឹងប៉ុណ្ណឹង បាទ។

**សៈ** ផ្ទះហ្នឹងនៅស្លូង ឬក៏នៅកន្លែងណាផ្សេង?

**ឆៈ** នៅហ្នឹង នៅស្លូងហ្នឹង ប៉ុននៅមកជាយភូមិខាងជើងផ្លូវជាតិប្រហែល៣០០ម៉ែត្រ ៣០០ ក៏

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

២០០ជាងទេយ៉ាង មើលទៅដីត្រង់នុ៎ង ប្រហែលបីចុះ ប្រហែល៣០០ម៉ែត្រហ្នឹង ខាងជើងថ្នល់ជាតិ។ មិនមែននៅចំក្បែរផ្សារស្នួងទេ នៅជាយឯខាងទេ មកមាត់ស្រឡះ ខាងជើងហើយខាងលិច។ កាលហ្នឹងអត់សូវមានផ្ទះទេ។ ឥឡូវផ្ទះជិតអស់ហើយ ទៅក៏មិនស្គាល់ រកមិនឃើញ ឥឡូវ។ បាទ ខ្ញុំចាំបានប៉ុណ្ណឹង បាទ។

**ស៖** ខ្ញុំគិតថា ខ្ញុំសួររួចមកហើយ ក៏ប៉ុន្តែដើម្បីឲ្យច្បាស់ថា តើ រស់ ញឹម ហ្នឹងគាត់ នៅពេលដែលគាត់ជួបជាមួយ សោ ភឹម ហ្នឹង គាត់តែម្នាក់ឯងទេ ឬក៏មានកងការពារនៅជាមួយគាត់ ឬក៏មានកម្មាភិបាលដែលមកពាយ័ព្យអីនៅជាមួយ?

[១៤:៣២:១៥]

**ឆ៖** បាទ ពេលដែលខ្ញុំឃើញគាត់ ៗមក គាត់មកតែឯង។ ជួនមកជាមួយកូនក្មេងតូចមួយ។ បាទ បើថា មាន អត់មានកងអង្គរក្សការពារអីមកទេ អត់ទេ ៗមកតែឯង។ ជួនពីរនាក់ បែបចៅយ៉ាងមក។ ខ្ញុំឃើញតែប៉ុណ្ណឹង មករបៀបមកលេង។ ចាំដែលពេលដែលខ្ញុំឃើញប៉ុនណា ខ្ញុំឃើញតែប៉ុណ្ណឹង បាទ ប៉ុណ្ណឹង។

**ស៖** តើ រស់ ញឹម នៅស្នួងហ្នឹងរយៈពេលប៉ុន្មានដែរ? មួយថ្ងៃ ឬក៏ច្រើនថ្ងៃ ពេលដែលគាត់មកម្តងៗហ្នឹង? លោកចាំទេ?

**ឆ៖** បាទ ពេលដែលគាត់មកហ្នឹង មិនបានយូរទេ ប្រហែលជាយូរណាស់ មួយម៉ោងជាង ទៅពីរម៉ោង។ គាត់ខំទៅវិញ ខ្លាចយប់ផ្លូវ ព្រោះផ្លូវកាលនុ៎ង វាពិបាកជិះមកវិញ ផ្លូវវាឆ្ងាយ។ គាត់ទៅដល់នុ៎ងថ្ងៃរសៀលអ៊ីចឹង គាត់ប្រហែលជាពីរម៉ោង មួយម៉ោងជាង គាត់វិលទៅវិញ។ បាទ ខ្ញុំចាំតែប៉ុណ្ណឹង បាទ។

**ស៖** សាក្សីមួយរូបដែលនឹងមកផ្តល់សក្ខីកម្មនាពេលខាងមុខនេះ ខ្ញុំគិតថាលោកស្គាល់គាត់ច្បាស់។ ខ្ញុំហៅគាត់ថា គាត់ 2-TCW-1070។ គាត់បញ្ជាក់ថា តាញឹម មកលេងជាញឹកញាប់។ ហើយសាក្សីរូបនេះក៏និយាយថា សោ ភឹម នៅបូព៌ាហ្នឹង គាត់ទៅលេង រស់ ញឹម ញឹកញាប់នៅពាយ័ព្យដែរ គឺនៅបាត់ដំបង។ លោកដឹងចំណុចហ្នឹងទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សុំលេខយោងឯកសារផង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ គឺឯកសារ E3/10716 គឺ ERN 01353350 បាទ ខ្ញុំមើលឯកសារខុស គឺ E3/10717 ទេ អម្បាញ់មិញខ្ញុំច្រឡំឯកសារ។ អង់គ្លេសគឺ 01354165 គាត់បាននិយាយជាច្រើនដងថា “សោ ភឹម ទៅលេង រស់ ញឹម នៅបាត់ដំបង” លោកសាក្សីលោកដឹងរឿងហ្នឹងទេថា សោ ភឹម នៅបូព៌ាហ្នឹងទៅជួប រស់ ញឹម នៅពាយ័ព្យនៅខេត្តបាត់ដំបងហ្នឹងញឹកញាប់ណាស់?

**ឆ៖** ខ្ញុំបាទសូមឆ្លើយពេលដែលទៅពាយ័ព្យនោះខ្ញុំមិនដែលបានទៅជាមួយគាត់ទេតាំងពីខ្ញុំនៅមកធ្វើការពារគាត់ហ្នឹង។ ក្រែងគេទៅអង្កាល់មុនខ្ញុំទៅនៅមិនដឹង បើថាខ្ញុំមកនៅ ខ្ញុំមិនដែលបានទៅពាយ័ព្យម្តងផងជាមួយគាត់ហ្នឹងបាទ។

[១៤:៣៦:២៣]

**ស៖** ខ្ញុំសូមអានចម្លើយដែលសាក្សីបានផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ E3/10717, អង់គ្លេស 01354168។ គេសួរថា៖ “តើ តា រស់ ញឹម ទៅលេងតា សោ ភឹម ញឹកញាប់ទេ គឺទៅបាត់ដំបង? ហើយអ្នកណាទៅលេងអ្នកណាញឹកញាប់ជាង? ពេលនោះគាត់ឆ្លើយថា៖ គឺថាខាងយើងហ្នឹងទៅលេងខាងគេញឹកញាប់ជាង។” ខាងក្រោមមកទៀតថា៖ “យាយការ៉ូ ហើយនិងតា សោ ភឹម ហ្នឹងទៅលេង<ទាំងពីរនាក់>។” ហ្នឹងគាត់បញ្ជាក់ច្បាស់ត្រង់ចំណុចនេះ។ អ៊ីចឹងលោកមិនចាំទេថា <តើ> សោ ភឹម ទៅភូមិភាគពាយ័ព្យញឹកញាប់ជាងការដែល រស់ ញឹម មកលេងគាត់នៅភូមិភាគបូព៌ា?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយថា ពេលដែលខ្ញុំមកការពារគាត់ហ្នឹង ខ្ញុំមិនដែលបាននាំគាត់ទៅពាយ័ព្យទេ គាត់ក៏មិនដែលនាំឲ្យខ្ញុំជូនទៅនុ៎ងដែរ ព្រោះខ្ញុំមិនដែលទៅផង។ បើមានតែតាហ្នឹងមក ក្រែងតែទៅពេលណាដែលខ្ញុំអត់បាននៅ ខ្ញុំពេលខ្ញុំគេឲ្យទៅស្ទូងស្រែ ធ្វើស្រែនៅរកាឃ្មួចក៏មិនដឹង អាពេលគេទៅលាក់ បានគាត់ទៅលេងនោះមិនដឹង ព្រោះការពារវាមានផ្លាស់វេនណ៎ា ជួន មុនមួយអាទិត្យម្នាក់ដើរតាមជាប់មួយអាទិត្យហ្នឹង ដល់មួយអាទិត្យម្នាក់គេរើសអ្នកនៅក្នុងហ្នឹងទៅការពារម្តងម្នាក់ៗ។ អាពេលនុ៎ងក្រែងអត់មានវេនខ្ញុំ វេនគេ គេទៅក៏មិនដឹង ប៉ុន្តែបើវេនខ្ញុំៗមិនដែលទៅ។ បាទ ខ្ញុំឆ្លើយប៉ុណ្ណឹងបាទ។

**ស៖** <សាក្សីផ្សេងទៀត-->

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមានមតិយោបល់ខ្លីមួយ។ យើងអាច<មានភាពច្បាស់លាស់ជាជាងអ្វីដែល>ថា គាត់ទៅញឹកញាប់ <ពីព្រោះសាក្សី 2-TCW-1070 នៅទំព័រ 01354165 បានផ្តល់សក្ខីកម្មថា> “ម្តងទៅពីរដងក្នុង

មួយឆ្នាំ”។ អ៊ីចឹងខ្ញុំគិតថា មេធាវីការពារក្ដីបានយោងទៅលើកំណត់ត្រារបស់ រ៉ូប៊ឺត លឹមគិន <ពីការសម្ភាសដែល លឹមគិន និយាយ ឬក៏ជាកំណត់ត្រាដែលថា លោកមេធាវីនិយាយថាឈ្មោះ ទាត់ ធឿន ទាក់ទងនឹងការបរិច្ឆេទនៃការរៀបការ ហើយខ្ញុំគិតថា ខ្ញុំបានឮលោកមេធាវីនិយាយថា វាបានធ្វើឡើងនៅឆ្នាំ១៩៧៥។ ប៉ុន្តែ ជាការពិត> សាក្សីដែលសម្ភាសដោយ លឹមគិន <ដែលមាននៅក្នុង>ឯកសារដែលលើកឡើងដោយ<លោកមេធាវីគឺ E3/106665 នៅទំព័រ 01156806។> គេសួរគាត់ថា “តើគេរៀបការនៅឆ្នាំ១៩៧៥?” <សាក្សីឆ្លើយ>ថា “<១៩៧៥>” គេសួរថា <នៅខែណា>? <គាត់ឆ្លើយថា ខែមករា ឆ្នាំ១៩៧៦>។

[១៤:៣៩:៥០]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ <ប៉ុន្តែខ្ញុំបានអានអំពីអ្វីដែល> ទាត់ ធឿន បាននិយាយ<ទាក់ទងនឹង>ការរៀបការនៅក្នុងឆ្នាំ១៩៧៥ <គឺខែសីហា ឆ្នាំ១៩៧៥>។

**លោក នីកូឡាស គូមជែន៖**

សូមឯកសារយោង។

**លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <បាទ ខ្ញុំទើបតែនិយាយមុនហ្នឹង> គឺ <ERN អង់គ្លេស> 01151760, ខ្មែរ 01168447 ឯកសារ E3/10665។ សំណួរមួយទៀតលោកសាក្សីពាក់ព័ន្ធជាមួយនឹង ការដែល សោ ភឹម និង រស់ ញឹម ទៅសួរសុខទុក្ខគ្នាទៅវិញទៅមក។ សាក្សីដែលនឹងមកផ្តល់សក្ខីកម្មនាពេលខាងមុខនេះ បាននិយាយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា សោ ភឹម និង រស់ ញឹម នេះគឺពេលដែលជួបគ្នាម្តងៗ គឺតែងតែនិយាយលេងសើចជាមួយគ្នា។ លោកចាំត្រង់ចំណុចហ្នឹងទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំពេលតារស់ ញឹម ហើយ សោ ភឹម មកគេជួបគ្នាហ្នឹង ខ្ញុំមិនដែលនៅជាប់ក្បែរគាត់ផង ខ្ញុំគ្រាន់ថា ឃើញគាត់មកហ្នឹង។ បើថា គាត់នៅនិយាយសំណេះសំណាលគ្នា អត់ឮព្រោះនៅឆ្ងាយពីគ្នា។ ខ្ញុំនៅធ្វើការនៅតាមខាងក្រៅនេះ។ ខ្ញុំអត់បានទៅជិតអី បាទ ខ្ញុំយាបល់ប៉ុណ្ណឹង។

[១៤:៤១:៣៦]

**ស៖** បាទ សាក្សីដែលនឹងមកផ្តល់សក្ខីកម្មនៅពេលខាងមុខនេះ បាននិយាយនៅក្នុងឯកសារ

E3/10717 ERNជាភាសាអង់គ្លេស 01354177 ថា សោ ភឹម ហៅ រស់ ញឹម អាសៀម ឬសៀម ហ្នឹងគឺសំដៅទៅលើថៃ។ ហើយ សោ ភឹម ហ្នឹងហៅ រស់ ញឹម វិញថា អាយួន <ដែលសំដៅទៅលើ វៀតណាម>។ គឺពួកគាត់ហៅគ្នាលេងសើចគ្នាទៅវិញទៅមក អាយួន អាថៃ អ៊ីចឹង។ លោកធ្លាប់ឮ ពាក្យហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំមិនធ្លាប់ផង មិនដែលធ្លាប់ទេ មិនឮផង។ សូមចប់យោបល់។

**ស៖** បាទ នេះជាព័ត៌មានលម្អិត តែវាមិនសំខាន់ប៉ុន្មានទេ លោកសាក្សី។ អ្វីដែលសំខាន់ហ្នឹង គឺចំណុចដូចតទៅ <ហើយនេះជាមូលហេតុដែល>ខ្ញុំនិយាយអំពីការជួបគ្នា<នេះអស់ពេលយ៉ាងយូរ>។ បុគ្គលដដែលហ្នឹងបាននិយាយថា ការរៀបការហ្នឹងគឺនៅខែសីហា ឆ្នាំ៧៥ គឺ ទាត់ ធឿន ដែលជាកូន ចិញ្ចឹមរបស់ រស់ ញឹម គឺនៅក្នុងឯកសារ E3/10665, ERNជាភាសាអង់គ្លេស 01151766, ជាភាសា ខ្មែរ 01168457។ គាត់ថា ពេលដែលពួកគាត់ជួបគ្នា ជជែកគ្នា "ពួកគាត់រៀបចំកម្លាំងទ័ព" សូមបញ្ចប់ ការដកស្រង់។ ដូច្នេះ ខ្ញុំក្នុងនេះគឺច្បាស់ហើយ គឺពួកគាត់រៀបចំផែនការបះបោរប្រឆាំងនឹង ប៉ុល ពត។ លោកធ្លាប់ឮអំពីខ្លឹមសារនៃការពិភាក្សាគ្នារវាង សោ ភឹម និង រស់ ញឹម ពាក់ព័ន្ធនឹងផែនការបះបោរ ប្រឆាំង ប៉ុល ពត ទេ?

[១៤:៤៣:៥០]

**ឆ៖** បាទ កន្លែងណាដែលខ្ញុំមិនឮ ខ្ញុំមិនដឹង ខ្ញុំមិនហ៊ាននិយាយព្រោះវាមិនដឹងមែន អត់ដឹងការ ពិភាក្សាទេ រឿងប្រឆាំងបះបោរនេះ ទើបនឹងពេលគេដេញចាប់ពួកខ្ញុំទៅសម្លាប់តើ បានមានគេបាច ត្រាក់ចេញពីយន្តហោះ បាចក្រដាសផ្ទាំងប៉ុនៗហ្នឹង គេដាក់ថា សោ ភឹម ក្បត់ ចូលយួន ចូលអីហ្នឹង។ ដល់ពេលហ្នឹងមក បានខ្ញុំនឹកឃើញថាភ័យ ខ្លាចគេតាមចាប់រាល់ថ្ងៃអ៊ីចឹង។ បើថា ពិភាក្សាគ្នារឿងផ្ទៃ ក្នុងស្អី អាហ្នឹងខ្ញុំអត់បានដឹង អត់បានឮ។ ខ្ញុំសូមឆ្លើយតែប៉ុណ្ណឹងបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាក។ អង្គជំនុំជម្រះសម្រាកហើយ អង្គជំនុំជម្រះ ប្រកាសសម្រាក ចាប់ពីពេលនេះ តទៅរហូតដល់ម៉ោង បី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការ សវនាការ។

សូមឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សី មក

កាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ វិញនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី លោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំសូមសំណួរមួយខ្លីទេ ទាក់ទងទៅនឹងឈ្មោះ ស៊ី ការបកប្រែជាភាសាអង់គ្លេស ប្រហែលជាមិនបានត្រឹមត្រូវ ឬក៏ថា មិនអាចយល់បានស្រួលទេ ឈ្មោះនេះ ក៏ប៉ុន្តែត្រឹមត្រូវដែរឬទេ ដែលថា ប្រពន្ធរបស់ ប្រាក់ <ជឿក> នៅរស់នៅឡើយ ហើយគាត់ក៏រៀបការនៅពេលដំណាលគ្នា ជាមួយនឹងឈ្មោះ ស៊ី ដែលកូនស្រីរបស់ សោ ភឹម នេះ អ៊ីចឹងមែន ឬក៏យ៉ាងណា?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** ខ្ញុំបាទ ខ្ញុំមិនបានដឹងទេ ពេលរៀបការប៉ុន្មានហ្នឹង ហើយនិងថា នៅរស់ហ្នឹងក៏មិនដឹងដែរ បាទ ព្រោះមិនបានឃើញបាទ។

[១៥:០៥:០០]

**ស៖** មិនថ្វីទេ លោកសាក្សី។ និយាយអំពី ប្រាក់ ជឿក ដែលជាប្រធានមន្ទីរការពាររបស់លោក នេះ តើប្រាក់ ជឿក នេះជាក្មួយប្រុសរបស់ សោ ភឹម ឬ?

**ឆ៖** បាទ ប្រាក់ ជឿក ហ្នឹងក្មួយជីដូនមួយ មិនជាក្មួយបង្កើតទេ។

**ស៖** តើលោកដឹងទេថាប្រាក់ ជឿក នេះ គេចាប់ខ្លួននៅពេលណាដែរ ហើយចាប់នៅឯណាដែរ?

**ឆ៖** បាទ ប្រាក់ ជឿក ពេលដែលគេចាប់នោះ ខ្ញុំមិនចាំទេ ប៉ុន្តែចាប់នុំងនៅស្នួង គាត់ទៅដោះ

ស្រាយ ថាគេចាប់បុគ្គលិកនៅមន្ទីរជាមួយគ្នាគាត់ហ្នឹង ជាមួយនឹងខ្ញុំហ្នឹង គេចាប់នៅនុ៎ង គាត់ថាគាត់ឡើងទៅដោះស្រាយ។ គាត់ ប្រាក់ ជឿក ហ្នឹងគាត់ឡើងទៅ គេចាប់ទាំងអស់នុ៎ងតែម្ដង។ ហើយខ្ញុំមិនចំណាំពេល មិនបានកត់ថ្ងៃខែអីទេ មិនដឹងទេ ប៉ុន្តែជំនាន់នុ៎ងវាយូរពេកហើយបាទ។

**ស៖** ឯកសារ <E3/2014> គឺថា ប្រាក់ ជឿក ហ្នឹងចាប់ខ្លួននៅថ្ងៃទី<២៦> ឧសភា ឆ្នាំ ១៩៧៨ ERN ជាភាសាអង់គ្លេស 01305698។ លោកសាក្សីសំណួរចុងក្រោយមួយពាក់ព័ន្ធទៅនឹង ប្រាក់ ជឿក តើត្រឹមត្រូវដែរឬទេ ដែលថា សោ ភឹម នេះទុកចិត្ត ប្រាក់ ជឿក នេះ និងអ្វីដែលលោកបានឆ្លើយជាមជ្ឈមណ្ឌលឯកសារកម្ពុជាថា សោ ភឹម ទុកចិត្តតែទៅលើ ប្រាក់ ជឿក អីចឹង ឬក៏យ៉ាងណា?

**ឆ៖** ត្រឹមត្រូវហើយបាទ។ ពិតជាត្រឹមត្រូវមែនបាទ។

**ស៖** សំណួរពាក់ព័ន្ធទៅនឹង ប្រាក់ ជឿក នេះ ថាតើ សោ ភឹម នៅពេលមួយនោះ ក៏គេហៅថា <>ប្រាក់ ចាម អីចឹងមែនទេ?

**ឆ៖** បាទ ឮចាស់ៗគាត់ថា ពីដើម សោ ភឹម ហ្នឹងឈ្មោះ ប្រាក់ ចាម មែនបាទ។

**ស៖** តើ សោ ភឹម មានប្អូនស្រីឈ្មោះ ប្រាក់ <ឈុន> តើមានទេ?

[១៥:០៨:៣៥]

**ឆ៖** បាទ ខ្ញុំមិនស្គាល់ មិនបានច្បាស់ទេត្រង់ប្អូនស្រីគាត់។ គាត់ចាស់ហើយ បើចាស់ៗបានដឹង មិនដឹងបងប្អូនគាត់ពីណាខ្លះទេ។ ស្គាល់តែដែលនៅក្នុងស្រុកនុ៎ងមាន តែបងគាត់ ហើយនិងប្អូនគាត់មួយ ខ្ញុំស្គាល់តែបីហ្នឹង។ តែបីនាក់នឹងតាភឹម ហ្នឹង ហើយពីរនាក់បងប្អូនហ្នឹងបាទ។ ១) ឈ្មោះ ប្រាក់ ឈុន ហ្នឹងនៅប្រធានសហករណ៍នៅនឹងស្រុកហ្នឹង ហើយមួយទៀត ប្រាក់ ទិត ហ្នឹង។ ស្គាល់តែពីរហ្នឹង។

**ស៖** មូលហេតុដែលខ្ញុំសួរអំពី ប្រាក់ <ឈុន> នេះ គឺដោយសារថា លោកបាននិយាយអំពី ប្រាក់ <ឈុន> នេះជាមួយនឹងអ្នកសម្ភាសមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ERN គឺ 01353378 ដល់ 79, ខ្មែរ 01340578 ដល់ <9>។ លោកបានឆ្លើយថា៖ "បងស្រីរបស់ សោ ភឹម គឺតឹងរ៉ឹងណាស់ គាត់បានធ្វើបាបប្រជាជនយ៉ាងខ្លាំង ហើយគឺថា សូម្បីតែចៅហ្វាយស្រុកក៏ខ្លាចស្ត្រីចំណាស់ម្នាក់នេះដែរ។" តើលោកពិតជាបាននិយាយថា ដូច្នេះមែនទេ? បាននិយាយអំពីបងស្រីរបស់ សោ ភឹម នេះ?

**ឆ៖** បាទ មែន។ ពិតជាត្រឹមត្រូវមែន។

**ស៖** ហើយថា តើ ប្រាក់ ឈុន នេះគាត់ទទួលខុសត្រូវសហករណ៍មួយគឺគគីរសោមនេះ គគីរសោម តើគាត់ជាប្រធានសហករណ៍នៅគគីរសោមនោះមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ គាត់ជាប្រធានសហករណ៍នៅគគីរសោមនោះមែន បាទ។

**ស៖** មុនពេលខ្ញុំចូលសួរអំពីប្អូនប្រុសម្នាក់ទៀតរបស់ សោ ភឹម ឈ្មោះ ប្រាក់ ទិត អ៊ីចឹងខ្ញុំសួរសំណួរមួយចុងក្រោយអំពីប្អូនប្រុសរបស់ សោ ភឹម មួយផ្សេងទៀតដែលជាលេខាស្រុកឆ្លូង គឺគាត់ឈ្មោះ ឌុល។ តើលោកស្គាល់ឈ្មោះ ឌុល នេះទេ?

[១៥:១១:២៨]

**ឆ៖** បាទ ខ្ញុំស្គាល់។ ឈ្មោះ ឌុល ហ្នឹងគឺ ប្រាក់ ទិត ហ្នឹង។ បាទ គេហៅ ប្រាក់ ទិត ហ្នឹងគឺឈ្មោះគាត់ពីមុន គេហៅថា ឌុល។ បាទ ខ្ញុំស្គាល់។

**ស៖** សូមអរគុណច្រើនលោក។ អ៊ីចឹងលោកបានឆ្លើយទៅនឹងសំណួរខ្ញុំហើយ។ ឥឡូវខ្ញុំសួរអំពី ប្រាក់ ទិត ឬហៅ ឌុល នេះ។ តើត្រឹមត្រូវដែរឬទេ ដែលថា -- បាទ ខ្ញុំសូមរៀបសំណួរឡើងវិញ។ តើលោកបាននិយាយថា ប្រាក់ ទិត គឺជាប្រធានមន្ទីរនគរបាលស្រុកក្រូចឆ្មារ តើលោកពិតជាបាននិយាយអ៊ីចឹងមែនទេ?

**ឆ៖** ជំនាន់ហ្នឹង ខ្ញុំមិនថាប្រធាននគរបាលទេ គ្រាន់តែថាគាត់ទៅកាន់ស្រុកក្រូចឆ្មារ។ ប្រាក់ ទិត ហ្នឹងបាទ ខ្ញុំបាននិយាយថាគាត់ប្រធានស្រុកក្រូចឆ្មារ។ កាលនុ៎ងគាត់នៅកាន់ក្រូចឆ្មារពិតមែនបាទ។

**ស៖** ខ្ញុំអាចមានការច្របូកច្របល់កន្លែងនេះ។ ចម្លើយរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជា បាទ ខ្ញុំសុំយោងទំព័រឲ្យបានច្បាស់លាស់ គឺឯកសារ E3/10716, អង់គ្លេស 01353315, ខ្មែរ 01340539 លោកបាននិយាយអំពីប្អូនប្រុសរបស់ សោ ភឹម ហៅ ប្រាក់ ទិត – ប្រាក់ ទិត ហៅ ឌុល។ លោកនិយាយថា គាត់គឺជាអ្នកទទួលខុសត្រូវនៅស្រុកក្រូចឆ្មារ។ តើក្រោយពីឆ្នាំ១៩៧៩ គាត់ជាប្រធាននគរបាលស្រុកស្វាយទាបមែនទេ ក្រោយឆ្នាំ១៩៧៩?

**ឆ៖** បាទ គាត់ជាប្រធាននគរបាលស្រុកស្វាយទាបមែន បាទ។

**ស៖** អ៊ីចឹងតើត្រឹមត្រូវដែរឬទេថា គាត់ក៏ព្យាយាមរត់គេចទៅវៀតណាមដែរ នៅពេលមួយនៅខែឧសភា ឆ្នាំ១៩៧៨ អ៊ីចឹងឬក៏យ៉ាងណា?

[១៥:១៤:២៨]

**ឆ៖** បាទ ក្នុងរឿងហ្នឹងកាលដែល៧៨ហ្នឹង ខ្ញុំមិនបានដឹងទេ ព្រោះនៅបែកបាក់គ្នាហើយ មិនដឹងថា គាត់គម្រោងការណា បើខ្ញុំរត់ រួចហើយគេបញ្ជូនខ្ញុំឡើងមកស្អាងកោះធំនេះហើយ។ នៅពេលនុ៎ងមក ខ្ញុំអត់បានដឹងទេ បាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកដឹងទេថា ចាប់ពីពេលណា ដល់ពេលណាដែរ ដែល ប្រាក់ ទិត ហៅ ឌុល នេះគឺជាចៅហ្វាយស្រុកក្រូចឆ្មារ? ហើយថាតើគាត់ឈប់ធ្វើជាចៅហ្វាយស្រុកក្រូចឆ្មារនេះនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំដឹងអាត្រង់ពេលដែលថា ខាងគេចាប់ប្ញូកហ្នឹង ពេលហ្នឹងគាត់ឈប់ក្នុងពេលហ្នឹងដឹងតែពេលហ្នឹងបាទ។

**ស៖** ដូច្នេះដើម្បីឲ្យបានច្បាស់លាស់នោះគឺថា គាត់គឺជាលេខាស្រុករហូតមកដល់ខែឧសភា ឆ្នាំ១៩៧៨ អ៊ីចឹងឬ?

**ឆ៖** បាទ ខ្ញុំចំណាំមិនបានទេ ដឹងស្រពេចស្រពិល មិនដឹងថារយៈពេល ដឹងតែពេលថារត់ គេចាប់រត់នេះនោះពេលនុ៎ងមកហ្នឹងវារគាត់រតាយតាមហ្នឹងរៀង១ខ្លួន ខ្ញុំក៏មិនគាត់ទៅណា គាត់ក៏មិនដឹងខ្ញុំទៅណាដែរក្នុងពេលនោះ។ បាទ ខ្ញុំចាំតែប៉ុណ្ណឹង។

**ស៖** បាទ ខ្ញុំយល់ហើយ។ លោកប្រហែលជាដឹងហើយថា ស្រុកក្រូចឆ្មារនេះត្រូវបានរំដោះរួចហើយនៅក្នុងឆ្នាំ១៩៧០ នោះ។ តើ ប្រាក់ ទិត ហៅ ឌុល ដែល -- តើ ប្រាក់ ទិត ហៅ ឌុល នេះចាប់ផ្ដើមធ្វើជាចៅហ្វាយស្រុកក្រូចឆ្មារនេះតាំងពីឆ្នាំ១៩៧០ មកឬក៏នៅពេលក្រោយៗទេ?

[១៥:១៦:៥៣]

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ពេលដែលគាត់ធ្វើការហ្នឹង ខ្ញុំមិនដឹងធ្វើពីថ្មើរម៉ានទេ ពីព្រោះខ្ញុំទើបនឹងទៅដឹងឆ្នាំ៧៦ហើយ។ កាលពីមុនមកខ្ញុំអត់ដឹងផង មិនដឹងធ្វើពីពេលណា អីថ្មើរណា។ បាទ ខ្ញុំឆ្លើយសូមចប់ហើយ។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែពេលលោកទៅដល់នៅឆ្នាំ៧៦នោះ តើគាត់បានធ្វើជាចៅហ្វាយស្រុកក្រូចឆ្មាររួចហើយឬនៅ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គាត់បានធ្វើរួចហើយបាទ។

**ស៖** តើលោកមានបានដឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងឆ្នាំ១៩៧៤ អាចជាខែកញ្ញា តុលា ឆ្នាំ១៩៧៤ និងនៅក្នុងឆ្នាំ១៩៧៥។ គឺព្រឹត្តិការណ៍អំពីការបះបោររបស់កងកម្លាំងចាម ហើយនិងការបង្ក្រាបការបះបោរជនជាតិចាមនៅភូមិទ្រា។ តើលោកមានដឹងអំពីការបង្ក្រាបការបះបោររបស់ជនជាតិចាមនៅក្នុងស្រុកក្រូចឆ្មារនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេបាទ អង្កាល់នុ៎ងវាខ្ញុំមិនដឹងនៅ ពី៧៤ ខ្ញុំមិននៅហ្នឹងផង។

**ស៖** ខ្ញុំសូមអានឲ្យលោកស្ដាប់ចេញពីសៀវភៅមួយ របស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ជន

ជាតិអូស្ត្រាលី ហើយ<ខ្ញុំនឹងសួរ>លោក<ថា>បាន<ឮដែរ<ឬទេ>។ លោកប្រធាននេះគឺ សៀវភៅរបស់ ប៉ែន យៀរនិន E3/1593, ERN អង់គ្លេស 01150139, បារាំង 00639033, ខ្មែរ 00637771។ កម្មាភិបាល ឬក៏ជនកុម្មុយនីស្ត<ជាន់ខ្ពស់ នៅក្រោយឆ្នាំ១៩៧៩> ឈ្មោះ ហែម សាមិន <> គឺថាត្រូវបានលោក ប៉ែន យៀរនិន នេះគាត់សម្ភាស ហើយនេះគឺអ្វីដែល ប៉ែន យៀរនិន គាត់បានសរសេរ សូមដកស្រង់៖ "ហែម សាមិន ដែលជាជនកុម្មុយនីស្តបង្ហាត់បង្រៀនដោយរដ្ឋាភិបាលទីក្រុងហាណូយ បានស្តីបន្ទោសទៅដល់លេខាភូមិភាគ សោ ភឹម ចំពោះការបង្ក្រាបការបះបោរជនជាតិចាម ជាលើកដំបូង សូមដកស្រង់៖ "គឺគាត់ដែលជាអ្នកស៊ីញ៉េទៅលើការបញ្ជាឱ្យសម្លាប់ជនជាតិចាមនៅភូមិទ្រា នៅក្នុងឆ្នាំ<១៩៧៤> គាត់នេះកាចណាស់" បញ្ចប់ការដកស្រង់។ ភួង ដែលយើងទើបតែនិយាយគ្នាអម្បាញ់មិញនេះ ហើយគឺជាមនុស្សម្នាក់ដែលមានមាឌតូចនៅក្នុងរូបថតដែលខ្ញុំបានសួរលោកនោះ។ តើលោកមានបានដឹងអំពីព្រឹត្តិការណ៍នេះ ឬក៏បានឮក្រោយឆ្នាំ១៩៧៩ ថា សោ ភឹម នេះបានស៊ីញ៉េទៅលើការបញ្ជាមួយ សេចក្តីបញ្ជាមួយនេះបញ្ជាឱ្យ ភួង ទៅបង្ក្រាប<ការបះបោររបស់>ជនជាតិចាម<នៅភូមិភាគបូព៌ា>នោះ លោកមានបានឮទេ?

**ឆ៖** បាទ ខ្ញុំមិនបានឮហើយមិនបានដឹងទេ ការងារហ្នឹងបាទ។ ព្រោះគេមិនមានអ្នកណានិយាយប្រាប់ខ្ញុំផងបាទ។

[១៥:២១:១៦]

**ស៖** មិនថ្វីទេ សូមអរគុណលោកសាក្សី។ មួយសំណួរ ពីរសំណួរទៀតពាក់ព័ន្ធទៅនឹងប្អូនប្រុសរបស់ សោ ភឹម គឺ ឌុល ឬក៏ហៅ ប្រាក់ ទិត នេះ នៅពេលដែលលោកលើកឈ្មោះគាត់មកនិយាយជាមួយអ្នកសម្ភាសន៍នៅមជ្ឈមណ្ឌលឯកសារកម្ពុជាលោកបាននិយាយថា គាត់ជាប់ទាក់ទងទៅនឹងបុគ្គលម្នាក់ឈ្មោះ ម៉ៅ ប៉ុក។ អង់គ្លេសគឺ <01353315> និងខ្មែរ 01340539។ ម៉ៅ ប៉ុក តើ ម៉ៅ ប៉ុក នេះជាអ្នកណា?

**ឆ៖** បាទ ម៉ៅ ប៉ុក ហ្នឹងមិនមែន ក្រែងគាត់មិនច្បាស់មិនដឹងមានតែឈ្មោះ ម៉ៅ ភោគ បាទ។ ម៉ៅ ភោគ ហ្នឹងនៅអគ្គសេនាធិការហ្នឹងដែរបាទ។ បើ ម៉ៅ ប៉ុក ហ្នឹងមិនដឹងដែរ ខ្ញុំអត់ច្បាស់ទេ។

**ស៖** លោកសាក្សី ប្រហែលជានៅជាអំណានបរទេសរបស់ខ្ញុំអានមិនច្បាស់ សុំទោស។ ប្រហែលជាខ្ញុំស្នើសុំឱ្យសហការីជាតិ ឬក៏សហការីជាតិក្រុម ខៀវ សំផន ជួយអានឈ្មោះនេះឱ្យលោកស្តាប់ ដើម្បីថាគាត់អានឈ្មោះខ្មែរទៅ គឺថាចំត្រឹមត្រូវតែម្តង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ សូមបញ្ជាក់គឺឈ្មោះ ម៉ៅ ភោគ ហ្នឹង បាទ សូមអរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកបានលើក<អំពី ឌុល>មកនិយាយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកបាននិយាយថាគាត់ក៏ត្រូវបានចាប់ខ្លួនដែរ ប៉ុន្តែគាត់រត់ទៅចូលព្រៃ។ គាត់បានរត់ទៅចូលព្រៃជាមួយនឹង ម៉ៅ ភោគ។ តើលោកអាចពន្យល់លម្អិតជូនអង្គជំនុំជម្រះបន្តិចបានទេអំពីរឿងរ៉ាវនេះ?

[១៥:២៣:២៦]

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** កាលដែលគាត់រត់ខ្លួនគេចទៅហ្នឹង ខ្ញុំមិនបានដឹងទេ។ ពីព្រោះរត់បែកពីគ្នាអស់លីងពីណាមិនដឹងអ្នកណាទៅខាងណា អ្នកណាទៅខាងណាទេ គេចយកតែរួចខ្លួនណ៎ា ដល់ពេលហ្នឹងខ្ញុំមិនបានដឹងលម្អិតពីរឿងហ្នឹងទេ ព្រោះមិនបានឃើញ ហើយមិនបានដឹងទៅជាមួយគ្នាបាទ។

**ស៖** តើលោកដឹងថា ម៉ៅ ភោគ ធ្លាប់ទទួលខុសត្រូវបញ្ជាកងវរៈបញ្ជាកងវរសេនាតូច<០៩>ដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ដឹងគាត់នៅ០៩ ហ្នឹងបាទ។ នៅកន្លែងហ្នឹងពិតជានៅកន្លែង០៩ ហ្នឹងមែនបាទ។

**ស៖** តើលោកដឹងថាៗមានជម្លោះប្រដាប់អាវុធរវាងកងទ័ពមជ្ឈិម ហើយនិងវរសេនាតូច០៩នេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំគ្រាន់តែធ្លាប់ឮពេលដែលខ្ញុំរត់ចេញមកហ្នឹង ឮថាគេនិយាយថា គឺខាង០៩ ហ្នឹងគឺវាយហ្នឹងកងមជ្ឈិមហ្នឹងសន្ធឹកសន្ធាប់ណាស់ បាទ ជាប់យូរ។ ខ្ញុំឮតែអ៊ីចឹង ប៉ុន្តែបើថានៅហ្នឹង ខ្ញុំក៏រត់ដែរ ខ្ញុំគេចភៀសខ្លួនដែរ អត់បានដឹងនៅហ្នឹងផង។

**ស៖** តើលោកខ្លួនឯងផ្ទាល់មានបានចូលរួមក្នុងជម្លោះប្រដាប់អាវុធរវាងកងទ័ពភូមិភាគបូព៌ាដែលប្រយុទ្ធជាមួយនឹងកងទ័ពមជ្ឈិមនោះដែរទេ?

**ឆ៖** ពេលនោះ ខ្ញុំមិនបានចូលរួមទេ គ្រាន់តែថា មួយពេលនោះ គេចាប់ខ្ញុំ ខ្ញុំបានដោះដៃបានរំដោះខ្លួនមានផ្ទុកអាវុធដែរ បានរំដោះខ្លួន បានមានតែប៉ុណ្ណឹងបាទ។

[១៥:២៥:០៣]

**ស៖** ខ្ញុំនឹងត្រឡប់មកសួរចំណុចនេះឡើងវិញនៅពេលក្រោយនេះបន្តិច។ ខ្ញុំសូមបញ្ចប់ការតាំង

សំណួរពាក់ព័ន្ធទៅនឹងមនុស្សមកពីភូមិភាគបូព៌ា គឺអ្នកដែលទទួលខុសត្រូវភូមិភាគបូព៌ា។ យើងបាននិយាយខ្លះៗហើយអំពី ហេង សំរិន ដែលគាត់ជាសមាជិកជាន់ខ្ពស់ក្នុងជួរកងទ័ពភូមិភាគបូព៌ា។ តើលោកដែលបានឃើញ សោ ភឹម និង ហេង សំរិន ជួបប្រជុំគ្នានៅពេលណាមួយដែរឬទេ?

**ឆ៖** បាទ ខ្ញុំចំណាំពេលមិនបានទេ ប៉ុន្តែគ្រាន់ថា គាត់បានធ្លាប់ជួបគ្នាដែរ កាលដែលនៅក្រុងព្រៃវែង។ បានឃើញតែប៉ុណ្ណឹង។ មិនដឹងនិយាយកិច្ចការអីមិនដឹងដែរ។

**ស៖** ខ្ញុំសូមសួរសំណួរជាទូទៅសិន។ លោកគឺជាកងការពាររបស់ សោ ភឹម ហើយឃើញ សោ ភឹម ហ្នឹងជួបប្រជុំជាមួយនឹងអ្នកដទៃជាច្រើនលើក ច្រើនសា តើមានពេលណាមួយ លោកមានវត្តមាននៅក្នុងកិច្ចប្រជុំរបស់ សោ ភឹម ជាមួយនឹងអ្នកដែលមានឋានន្តរសក្តិខ្ពង់ខ្ពស់នៅភូមិភាគបូព៌ា ឬក៏ធ្លាប់ឃើញ តើលោកធ្លាប់ដែលមានវត្តមាននៅក្នុងបន្ទប់ប្រជុំរបស់ សោ ភឹម ជាមួយកម្មាភិបាលជាន់ខ្ពស់ភូមិភាគបូព៌ា និងការប្រជុំជាមួយនឹងថ្នាក់មជ្ឈិមដែរឬទេ? <តើលោកធ្លាប់បានស្តាប់ការប្រជុំរបស់ សោ ភឹម ដែរឬទេ?>

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ ពេលដែលគាត់មកប្រជុំអីហ្នឹង ខ្ញុំមិនដែលមានវត្តមាននៅក្នុងហ្នឹងដែរ មិនដឹងប្រជុំពីរឿងអីៗ ខ្ញុំការពារតែខាងក្រៅហ្នឹងបាទ។

[១៥:២៨:១៣]

**ស៖** តើមានពេលណាមួយដែលលោកស្តាប់ឮដោយចៃដន្យ តើលោកតែងតែស្ថិតនៅខាងក្រៅបន្ទប់ប្រជុំ ហើយមិនដែលស្តាប់ឮគេនិយាយពីខាងក្នុងមកដោយចៃដន្យម្តងណាទេ ឬក៏យ៉ាងណា?

**ឆ៖** បាទ មិនដែលទេ ព្រោះតែនៅខាងក្រៅនៅតែខាងក្រៅ នៅខាងក្នុងម៉េចមិនឮបាទ។ នៅខាងក្រៅ ប្រជុំនៅខាងក្នុង។

**ស៖** ហេង សំរិន គឺថា មានបងប្រុស<>នៅពេលនោះ។ ហើយលោកសាក្សី គឺថា លោកធ្លាប់បានទៅលេងជាមួយនឹងបងប្រុសរបស់គាត់ម្នាក់។ តើលោកពិតជាធ្លាប់បានទៅលេង<ផ្ទះរបស់> ប្រធាននីរសារ ភូមិភាគ<> ឈ្មោះ ហេង សំកៃ ជាញឹកញាប់។ តើធ្លាប់អ៊ីចឹងមែនទេ?

**ឆ៖** បាទ ទៅលេង -- ខ្ញុំសូមឆ្លើយបាទ ទៅលេងព្រោះផ្ទះគាត់ មន្ទីរគាត់ហ្នឹង ហើយខ្ញុំនៅក្បែរគ្នា ជាប់គ្នា។ ខ្ញុំឧស្សាហ៍ទៅលេងដែរ ប៉ុនខ្ញុំលេងជាមួយគាត់ ខ្ញុំលេងជាមួយបុគ្គលិកនៅកន្លែងនោះ ជិតគ្នា ហើយទៅស្តាប់ភ្លេងដែលគេដេញ តាៗគាត់លេងភ្លេងនៅជាប់នឹងផ្ទះគាត់ហ្នឹង ឧស្សាហ៍ទៅញឹកញាប់ដែរ ព្រោះផ្ទះនៅជាប់គ្នា ជិត របងជាប់គ្នា។

**ស៖** តើលោកនៅនឹកឃើញថា លោកធ្លាប់បាននិយាយជាមួយនឹង ហេង សំរិន ដែរឬទេ?

**ឆ៖** បាទ ខ្ញុំដូចជាមិនធ្លាប់ទេ ធ្លាប់តែនិយាយលេងជាមួយអង្គរក្សគាត់មាន ជាមួយគាត់ផ្ទាល់មាត់អត់មានទេ។ មានតែអង្គរក្សមាន អង្គរក្ស ហេង សំរិន។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថាលោកក៏យកសំបុត្រពី សោ ភឹម ទៅជូន ហេង សំរិន ដែរអីចឹងឬ?

**ឆ៖** បាទ មែន គ្រាន់តែអាហ្នឹងមិនមែនទៅជូននេះ ជូននៅក្នុងបុគ្គលិកមន្ទីរនុំង មិនជូនប្រធានទេ ជូនបុគ្គលិកនៅក្នុងមន្ទីរនុំងបាទ។

[១៥:៣១:២២]

**ស៖** តើលោកដឹងថា ហេង សំរិន មានតួនាទីអ្វីដែរ ក្រោយឆ្នាំ១៩៧៩?

**ឆ៖** បាទ ក្រោយ៧៩ គាត់ជាចៅហ្វាយខេត្តស្វាយរៀង។

**ស៖** តើលោកដឹងថា គាត់គឺជាសមាជិកមជ្ឈិមបក្សនៃ<គណបក្សប្រជាជនបដិវត្តន៍>កម្ពុជានោះដែរឬទេ?

**ឆ៖** បាទ ត្រង់សមាជិកតួនាទីអីទេ ខ្ញុំមិនសូវដឹងទេ ដឹងគ្រាន់តែគាត់ប្រធាន នីរសារនៅនុំង ប្រធាននីរសារភូមិភាគ ដឹងតែប៉ុណ្ណឹង បើថាតួនាទីស្អីៗ ខ្ញុំមិនសូវដឹងដែរ។

**ស៖** ហេង សំរិន បានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកកាសែតអាមេរិកាំងម្នាក់ដែលបានមកផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿងមួយផ្សេង ក្នុងឋានៈជាអ្នកជំនាញ គឺសម្ភាសនៅក្នុងឆ្នាំ<១៩៨១> សៀវភៅរបស់គាត់ឈ្មោះថា *"ប្រាថ័រ អេនណឹមី"* E3/2376, អង់គ្លេស ERN 00192440។ បាទ ខ្ញុំនឹងផ្ដល់លេខ ERN ផ្សេងទៀតនៅពេលក្រោយ។ ក្នុងកិច្ចសម្ភាសន៍នេះ ហេង សំរិន បាននិយាយថា សូមដកស្រង់ "គឺថាវាមិនអាចផ្ដួលរំលំ ប៉ុល ពត ដោយខ្លួនយើងបានទេ យើងត្រូវស្នើសុំជំនួយពីវៀត-ណាម" បញ្ចប់ការដកស្រង់។

តើសម្ដីនេះ លោកធ្លាប់ដែលឮ ហេង សំរិន និយាយស្រដៀងគ្នានេះដែរឬទេ ដែលថាមានផែនការទម្លាក់ប៉ុល ពត គឺជាផែនការរបស់ភូមិភាគបូព៌ា ប៉ុន្តែផែនការនេះ មិនដំណើរការទៅបាន គឺត្រូវការជំនួយពីវៀតណាម ដើម្បីធ្វើម៉េចឲ្យសម្រេចផែនការនេះទៅបាន។ លោកធ្លាប់ដែលឮគេនិយាយពីផែនការនេះទេ?

[១៥:៣៣:៥១]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01391902



**ឆ៖** បាទ ខ្ញុំសូមឆ្លើយ មិនដែលឮផង បាទរឿងផែនការនេះ។ ខ្ញុំមិនឮ បាទ សូមចប់។

**ស៖** មិនថ្វីទេលោកសាក្សី។ បាទ ខ្ញុំសូមសួរបញ្ចប់អំពីរចនាសម្ព័ន្ធកង<ពលផ្សេងៗ ឬយោធា ដែលលោកបានឃើញ>។ ហេង សំរិន ជាមេបញ្ជាការកងពលលេខ៤ ប្អូនប្រុសរបស់គាត់ម្នាក់ឈ្មោះ ថាល់ គឺជាមេបញ្ជាការ កងពលលេខ២ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំបាទ មិនដឹងច្បាស់ទេ ដឹងតែថា លោក សម្តេច ហេង សំរិន ហ្នឹងគាត់ជាកងពលលេខ៤ មែន តែដល់ឈ្មោះប្អូនគាត់ហ្នឹង ខ្ញុំមិនស្គាល់អស់ទេបាទ ព្រោះគេនៅខាងមុខ ខ្ញុំនៅអីក្រោយ។

**ស៖** សាក្សីដែលនឹងចូលខ្លួនមកថា <គាត់ហ្នឹងគឺ> ថាល់ ហើយ<លោកនិយាយថាមេបញ្ជាការ កងពលលេខ២ គឺ តាតាត>។ ERN គឺ 01353341, ខ្មែរ 01340556។ តើចំណុចនេះ វាជួយរំឭក ដល់ការចងចាំរបស់លោកបានដែរទេ គឺឈ្មោះ <តាតាត ឬក៏ប្រហែលជាលោកចង់សំដៅទៅលើ> តា ថាល់?

**ប្រធានអង្គជំនុំ៖**

តាល់ ឈ្មោះ តាល់ ខ្មែរ – តាល់ ទេណា។

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំមិនបានឮឈ្មោះហ្នឹង ខ្ញុំមិនបានឮដែរ។ មិនដឹង កន្លែងណាដែលមិនដឹង ខ្ញុំមិនឆ្លើយ ទេ ព្រោះអត់ដឹង។

[១៥:៣៦:១១]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជាការពិតហើយលោកសាក្សី។ សំណួរមួយទៀតពាក់ព័ន្ធទៅនឹងកងពលភូមិភាគបូព៌ាគឺ កងពលលេខ៥។ លោកបានឆ្លើយទៅប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថាមេបញ្ជាការកងពលលេខ៥ ម្នាក់ទៀតនោះគឺឈ្មោះ ហេង គីម។ សាក្សីដែលចូលខ្លួនបន្ទាប់នោះនិយាយថា ហេង គីម នេះគឺមិនមែន ជាសមាជិកគ្រួសាររបស់ ហេង សំរិន ទេ។ ចុះលោកវិញនេះ តើលោកមានបានដឹងថា ហេង គីម នេះ ជាសមាជិកគ្រួសារ ជាសាច់ឈាមរបស់ ហេង សំរិន ដែរឬ?

**ឆ៖** បាទ ខ្ញុំសុំឆ្លើយ ខ្ញុំមិនបានដឹងរឿងសាច់ញាតិ សាច់អីនេះ ខ្ញុំអត់បានដឹង អត់ដឹងឮទេ បាទ មិនដឹងទាល់តែសោះហ្នឹង។

**ស៖** មិនថ្វីទេ។ លោកសាក្សី តើត្រឹមត្រូវដែរឬទេ ដែលថា នៅភូមិភាគបូព៌ា នៅក្នុងឆ្នាំ១៩៧៨

មានកងពលចំនួនបួន មានកងពលលេខ២, ៣, ៤ និង ៥?

**ឆ៖** បាទ នៅបូព៌ានោះមានប្រាំកងពលមែន តែខ្ញុំចំណាំមេកងពលអត់ស្គាល់ឈ្មោះទាំងអស់នោះទេ បាទ គ្រាន់ថាមានប៉ុណ្ណឹងមែន។

[១៥:៣៧:៥៨]

**ស៖** ខ្ញុំយល់ហើយ។ ហេង សំរិន បានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹង ប៉ែន យៀវនិន គឺឯកសារ E3/1568, ERN ជាភាសាអង់គ្លេស 00651894, ខ្មែរ 00713971, បារាំង 00743368។ គាត់បាននិយាយអំពីកងពលផ្សេងៗនៅភូមិភាគបូព៌ា។ គាត់បានឆ្លើយថា កងកម្លាំងភូមិភាគហ្នឹង គឺវាមានបីកងពល<ដែលមានចំនួន៨.០០០នាក់ ៦.០០០នាក់ និង៥.០០០នាក់ ហើយ> សរុបទាំងអស់ ២០.០០០នាក់។ ហើយកងទ័ពតំបន់ហ្នឹងគឺវាមានពីរវរសេនា<ធំ> មាន១៥.០០០នាក់។ នៅថ្នាក់ស្រុកហ្នឹង គឺមានកងអនុសេនាតូចពីរ មានកម្លាំងចំនួន៦.០០០នាក់។ តើលោកអាចដឹងអំពីសមាសភាព គឺនិយាយកងកម្លាំងរបស់ភូមិភាគបូព៌ាទាំងអស់នេះដែរទេ ដែលថា យ៉ាងហោចណាស់មានសរុបទាំងអស់ហ្នឹងដល់ទៅ៤០.០០០នាក់ឯណោះ កងកម្លាំងចំណុះឲ្យភូមិភាគបូព៌ាទាំងអស់ហ្នឹង។លោកដឹងទេ?

**ឆ៖** បាទ ក្នុងកងកម្លាំង កងទ័ពនេះ ខ្ញុំមិនបានដឹង មិនបានស្តាប់ មិនបានយកចិត្តទុកដាក់ទេបាទ។ រឿងនេះខ្ញុំមិនដឹងទេ មិនហ៊ានឆ្លើយថា ប៉ុន្មានៗ កំណត់ ខ្ញុំអត់ដឹងដែរ។

**ស៖** បាទ ខ្ញុំយល់ហើយ ប៉ុន្តែតើលោកបានដឹងដែរឬទេថា កងទ័ពភូមិភាគបូព៌ាប៉ុន្មាននាក់បានចូលរួមប្រយុទ្ធជាមួយនឹងកងទ័ពមជ្ឈិមគឺថា ក្រោយថ្ងៃ២៥ ឧសភា ឆ្នាំ១៩៧៨នោះ លោកដឹងទេ កម្លាំងបូព៌ាសរុបទាំងអស់ប៉ុន្មាននាក់ប្រយុទ្ធជាមួយខាងមជ្ឈិម?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយមិនបានដឹងច្បាស់ទេកន្លែងហ្នឹងបាទ មិនដឹងប៉ុន្មានៗទេ ខ្ញុំបោះបង់ចោលហើយពេលហ្នឹង។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា គឺមានឈ្មោះពីរ។ លោកធ្លាប់ឮឈ្មោះខៀវ សំណាង -- កែវ សំណាង។ លោកធ្លាប់ឮឈ្មោះនេះទេ?

**ឆ៖** បាទ ពេលដែលខ្ញុំទៅហ្នឹងដូចជាមិនដែលឮឈ្មោះហ្នឹងទេបាទ។ ខ្ញុំមិនដែលឮកន្លែងណាដែលខ្ញុំមិនឮ មិនពិត ខ្ញុំក៏មិនហ៊ានឆ្លើយ មិនហ៊ានអះអាងដែរ។

[១៥:៤១:១៥]

**ស៖** បាទ មិនអីទេ។ អ៊ីចឹងឈ្មោះមួយទៀត ប៉ុល សារឿន ដែលបច្ចុប្បន្នជាឧត្តមសេនីយ៍

ប្រហែលជាផ្កាយ៣ នៅក្នុងកងយុទ្ធពលខេមរភូមិន្ទ។ លោកធ្លាប់ឮឈ្មោះហ្នឹងទេ ប៉ុល សារឿន?

**ឆ៖** បាទ ដូចខ្ញុំនិយាយថាកន្លែងណាដែលពិត ហើយកន្លែងណាដែលខ្ញុំធ្លាប់ដឹងបានខ្ញុំហ៊ាននិយាយ កន្លែងណាដែលមិនច្បាស់លាស់ ខ្ញុំក៏មិនហ៊ាននិយាយ ហើយខ្ញុំអត់បានឮឈ្មោះហ្នឹងក៏មិនបានស្គាល់ដែរ គឺមិនដឹងដែរ។ ជំនាន់គេប្រែឈ្មោះដូចម៉េចៗដែរបាទ។

**ស៖** បាទ ខ្ញុំចូលទៅប្រធានបទបន្ទាប់ទៀតលោកសាក្សី។ <ម្តងជាពីរដង>នៅក្នុងកំណត់ហេតុសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានប្រើពាក្យ "រដ្ឋប្រហារ"។ ខ្ញុំសូមបញ្ជាក់ឱ្យច្បាស់ ត្រង់ចំណុចនេះហ្នឹង គឺខ្ញុំ អង់គ្លេស 01353339, ខ្មែរ 01340554។ លោកនិយាយអំពី ប្រាក់ ជឿក ដែលជាប្រធានកងការពារ។ លោកថា៖ "ជឿក ប្រហែលជាស្លាប់ជាមួយ សោ ភឹម <ដោយសារតែពេលភ្លឺហើយ គាត់មិនទាន់ត្រឡប់មកវិញទៀត។> ថ្ងៃនុំងគឺគេធ្វើរដ្ឋប្រហារ ពួកគេត្រូវបានចាប់<ខ្លួនយកទៅជាច្រើនថ្ងៃ> ហើយអ្នកដែលចាប់បានហ្នឹងគេយកទៅ គឺមិនឱ្យដឹងខ្លួនទេ គេចាប់មិនឱ្យដឹងខ្លួន"។

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

សំណួររបស់លោកពាក់ព័ន្ធនឹងរដ្ឋប្រហារ អ៊ីចឹង<ប្រហែលអ្នកណាម្នាក់គួរតែប្រាប់គាត់ថា> តើជាភាសាខ្មែរហ្នឹងយ៉ាងម៉េចដែរ ពាក្យហ្នឹងវាត្រឹមត្រូវតាមអង់គ្លេសដែល *គូដេតា* ហ្នឹងទេ? បញ្ជាក់ខ្មែរឱ្យច្បាស់ <ពីព្រោះអាចមានការបកប្រែផ្សេងៗគ្នា>។

**<លោក វ៉ិចទ័រ កូប៉េ៖>**

មេធាវីជាតិរបស់ខ្ញុំគាត់ឈឺ <ដូច្នេះគាត់សុំចេញទៅមុន>បាត់ហើយ។

**លោក នីកូឡាស គូមជែន៖**

បាទ <ខ្ញុំជឿជាក់ថា>ត្រឹមត្រូវហើយពាក្យជាភាសាខ្មែរហ្នឹង គេប្រើពាក្យរដ្ឋប្រហារដូចគ្នាហើយ ពាក្យជាមួយនឹង*គូដេតា* ហ្នឹង <យោងតាមសហការីជនជាតិបារាំងរបស់ខ្ញុំ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

បាទ អ៊ីចឹងគឺពាក្យហ្នឹងត្រូវហើយអ៊ីចឹង ដូច--

**ស៖** ដូច្នេះ ដើម្បីឱ្យបានពេញលេញត្រង់ចំណុចនេះ ខ្ញុំសូមយោងទៅចម្លើយដែលលោកបានឆ្លើយពាក់ព័ន្ធនឹងរដ្ឋប្រហារ។ នៅទំព័រជាភាសាអង់គ្លេសគឺ 01353376, ខ្មែរ 01340577។ លោកបាននិយាយពាក់ព័ន្ធនឹង<ទម្លាប់ផឹកស្រារបស់> សោ ភឹម គេសួរថា "តើគាត់ចូលចិត្តហូបស្រាអី?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01391905





<ហើយលោកបានឆ្លើយ>ថា <នៅពេលណាដែលមានរឿង>លំបាក<កើតឡើង ដូចជាមានការ>ធ្វើរដ្ឋប្រហារ <និងមានការចាប់ខ្លួនច្រើន ខ្ញុំឃើញគាត់>ហូបស្រា<ជាច្រើន>ថ្ងៃ <រហូតដល់>ជិតមួយខែ<ក៏មាន> ចុះផឹកស្រាតែម្នាក់ឯង <ផឹកតែស្រា> ស្រាតែមួយដបចាក់ផឹកទៅ ខ្លួនគាត់ដូចពិបាកគិតមិនចេញ”។ នេះជាចំណុចលម្អិតដែលលោកបានឆ្លើយពាក់ព័ន្ធនឹង សោ ភឹម <នៅ>ថ្ងៃធ្វើរដ្ឋប្រហារ។ ពេលដែលលោកនិយាយពាក្យថា “រដ្ឋប្រហារ”នេះ លោកចង់សំដៅទៅលើហេតុការណ៍អ្វីដែរ?

[១៥:៤៥:២២]

**ឆ៖** បាទ ខ្ញុំចង់និយាយថារដ្ឋប្រហារមុនវាជាបក្សតែមួយ ដូចជាកម្ពុជាប្រជាធិបតេយ្យ ស្រាប់តែដល់គេមានភ័ន្តប្រែ មានខាងមជ្ឈិមឡើងទៅចាប់ខាងនេះខាងនោះ អ៊ីចឹងបានខ្ញុំនិយាយថាវារដ្ឋប្រហារ ប្រហែលជាគេផ្តួលរំលំណាមួយហើយ បានគេធ្វើរដ្ឋប្រហារចាប់គ្នានេះផង ចាប់សម្លាប់ ឬបណ្តេញគ្មានទិសដៅអ៊ីចឹង។ ខ្ញុំអាពាក្យរដ្ឋប្រហារហ្នឹង ខ្ញុំចេះតែនិយាយថា ព្រោះមិនដឹងច្បាស់ៈ អាពាក្យរប្បធម៌រដ្ឋប្រហារជាអ្វី គ្រាន់តែដឹងថាហេតុតែមានរដ្ឋាភិបាលតែមួយ តែមានទំនាស់ហើយ បានជាមានរដ្ឋប្រហារអ៊ីចឹងណ៎ា ខ្ញុំវាមិនចេះភាសាហ្នឹងដែរបាទ។

**ស៖** ខ្ញុំយល់ត្រង់ចំណុចនេះ ក៏ប៉ុន្តែតើអ្នកណាជាអ្នកប៉ុនប៉ងធ្វើរដ្ឋប្រហារនោះ ជាកងកម្លាំងនៅភូមិភាគបូព៌ា? មនុស្សជាច្រើនមកពីបូព៌ាបាននិយាយថា ប៉ុល ពត ឬ សុន សេន ទេជាអ្នកប៉ុនប៉ងធ្វើរដ្ឋប្រហារនោះ?

**ឆ៖** បាទ វាខ្ញុំសូមឆ្លើយរឿងរដ្ឋប្រហារហ្នឹង ខាងមជ្ឈិមហ្នឹងគេឡើងទៅចាប់បូព៌ាហ្នឹង បានថាខ្ញុំនិយាយថារដ្ឋប្រហារ ប៉ុនថាមិនដឹងអ្នកណាមួយអ្នកផ្តើមគំនិត ប៉ុនដឹងតែថាមជ្ឈិមឡើងទៅចាប់ខាងនិរតីហ្នឹង ឡើងទៅចាប់ខាងបូព៌ាទាំងអស់ហ្នឹងបាទ។ ខ្ញុំដឹងតែប៉ុណ្ណឹងបាទ។

[១៥:៤៧:១៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរមួយសំណួរលោកសាក្សី តាមយោបល់របស់លោកនោះ អ្នកណាជាអ្នកធ្វើរដ្ឋប្រហារ? មជ្ឈិមជាអ្នកធ្វើរដ្ឋប្រហារ ឬក៏អ្នកណាម្នាក់ធ្វើរដ្ឋប្រហារប្រឆាំងនឹងមជ្ឈិម?

**លោក ស៊ិន អ៊ឹង៖**

តាមខ្ញុំនៅហ្នឹងគឺខាងមជ្ឈិមគេចុះចាប់មុន ខាងបូព៌ាគ្មានដឹងខ្លួនផង អត់ដឹងផង ស្រាប់តែទៅគេចាប់ ទៅត្រង់នេះគេចាប់បាត់ខ្លួន ទៅត្រង់នោះគេចាប់បាត់ខ្លួនអ៊ីចឹងតែម្តងបាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំងាកចេញពី ហេង សំរិន ឬក៏ ជា ស៊ីម ដែលនិយាយ<ថា ប៉ុល ពត ជាអ្នករៀបចំធ្វើ>រដ្ឋប្រហារ។ ឥឡូវខ្ញុំចូលទៅនិយាយឋានៈរបស់លោកនៅក្នុងឋានានុក្រម ខ្ញុំយោងទៅលើសាក្សីដែលនឹងមកផ្ដល់សក្ខីកម្មនាពេលខាងមុខ គឺសាក្សី2-TCW-1070 ដែលបានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ERN ជាភាសាអង់គ្លេស -- គឺឯកសារ E3/10717, អង់គ្លេស 01354198 គាត់បាននិយាយថា "អាពត គឺ ប៉ុល ពត ជាអ្នកធ្វើរដ្ឋប្រហារ ហើយសម្លាប់មនុស្ស។" គាត់និយាយថា ប៉ុល ពត ជាអ្នកធ្វើរដ្ឋប្រហារ ដូច្នេះតើចំពោះលោកនោះ លោកគិតថាអ៊ីចឹងទេ?

[១៥:៤៩:០៦]

**លោក ស៊ិន អ៊ីង៖**

**ឆ៖** កាលដែល តាមគិតដែលខ្ញុំគិតហ្នឹង មិនដឹងច្បាស់ថាអ្នកណាមួយជាធ្វើរដ្ឋប្រហារទេ ប៉ុនគ្រាន់ដឹងថាខាងមជ្ឈិម ខាងនិរតីហ្នឹងឡើងទៅចាប់ហ្នឹង ប៉ុន្តែមិនដឹងគេមានបំណងចាប់ប្រុងធ្វើស្អីភាសាខ្ញុំយល់មិនច្បាស់ដែរ រឿងត្រង់គេធ្វើស្អីមួយ ហើយក៏មិនដឹងដែរ គ្រាន់តែដឹងថាចាប់បានដឹងថាបាត់ខ្លួនតែម្ដង។

**ស៖** ខ្ញុំសូមបញ្ជាក់ឱ្យបានច្បាស់ត្រង់ចំណុចនេះ។ លោកសាក្សីលោកបានផ្ដល់ចម្លើយយ៉ាងវែងពាក់ព័ន្ធនឹងហេតុការណ៍ដែលបានកើតឡើងរវាងថ្ងៃទី<ព្រហស្បតិ៍ ទី>២៥ ឧសភា ៧៨ រហូតដល់ថ្ងៃ<សៅរ៍ ទី៣ ខែមិថុនា ឆ្នាំ៧៨>ដែល<ជាថ្ងៃ> សោ ភឹម ធ្វើអត្តឃាតសម្លាប់ខ្លួនឯង។ ខ្ញុំអត់មានពេលចូលទៅនិយាយលម្អិតទេ ក៏ប៉ុន្តែលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺចំណុចដែលគួរឱ្យចាប់អារម្មណ៍មែនទែនពាក់ព័ន្ធនឹងការប៉ះទង្គិចគ្នារវាងកងទ័ពបូព៌ានិងមជ្ឈិម។ អង់គ្លេស 01353387, ខ្មែរ 01340584 គឺលោកបានឃើញហេតុការណ៍ ដែលសោ ភឹម បានប្រាប់ ហេង សំរិន។ នេះគឺជាអ្វីដែលលោកបានឆ្លើយ ខ្ញុំសូមអានឱ្យលោកស្ដាប់ "គាត់គឺ សោ ភឹម ជួបតា ហេង សំរិន។ ពេលដែលជួបហេង សំរិន នោះ គាត់សម្រាកនៅទីនោះជាច្រើនថ្ងៃ។ ពេលនោះ គាត់ប្រាប់ថា តារិន ឯងសល់ប៉ុន្មានឱ្យប្រមូលគ្នាចូលព្រៃតស៊ូ វ៉ៃម្ដងទៀត។ យើងវ៉ៃខ្មែរ វ៉ៃអាពួកខ្មែរប៉ុលពតហ្នឹងម្ដងទៀត។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី លោកបានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាបែបហ្នឹងមែនទេ? លោកអាចពន្យល់ហេតុការណ៍ដែល សោ ភឹម និយាយបែបនេះ ទៅប្រាប់ ហេង សំរិន បានទេ?

[១៥:៥២:០២]

**ឆ៖** បាទ ពេលនោះ ខ្ញុំឮពេលជិតបែកគ្នាហើយហ្នឹង ថាតែប៉ុណ្ណឹងបែក ខ្ញុំឮមែន ពេលហ្នឹង។ ហ្នឹងពេលហ្នឹង ហើយក៏លាគ្នាចុះចេញរៀងខ្លួនទៅ។

**ស៖** ក៏ប៉ុន្តែនេះ ជាអ្វីដែលលោកបានស្ដាប់ឮដោយផ្ទាល់ត្រចៀក ក្នុងឋានៈលោកជាអ្នកយាម សោ ភឹម ឬក៏លោកឮពីអ្នកណាផ្សេងៗប្រាប់លោកនូវរឿងរ៉ាវបែបហ្នឹងនេះ?

**ឆ៖** ខ្ញុំបាទ ខ្ញុំឮ អាភាសាហ្នឹង ខ្ញុំឮដោយផ្ទាល់ត្រចៀក និយាយដែលថាខ្ញុំឮ ពេលណាដែលខ្ញុំឮ ខ្ញុំដឹង ខ្ញុំសូមឆ្លើយថាខ្ញុំឮ អាពេលហ្នឹងខ្ញុំឮមែន។ បាទ ពិតប្រាកដមែន។

**ស៖** លោកដឹងថា សោ ភឹម ចង់មានន័យថាម៉េចទេ ពេលដែលគាត់ប្រាប់ តារិន ថា "ឯងសល់ប៉ុន្មានឲ្យប្រមូលគ្នាចូលព្រៃតស៊ូ វ៉ៃម្ដងទៀត យើងវ៉ៃខ្មែរ អាពួកខ្មែរប៉ុលពត ហ្នឹងម្ដងទៀត?" លោកយល់ទេ ពេលដែល សោ ភឹម និយាយបែបហ្នឹង? គាត់ចង់មានន័យយ៉ាងម៉េចថា ប្រមូលគ្នាចូលព្រៃហ្នឹង? ប្រមូលគ្នា "គ្នា"ហ្នឹងជាអ្នកណា?

**ឆ៖** តាមខ្ញុំយល់ ម៉ាពេលនោះ ពីព្រោះមាននៅសល់មេកងពល អនុកងពល ហើយស្អី នៅខ្លះដែរ នៅច្រើនដែរ ពេលនោះបានគាត់ ពេលគាត់ចុះមកភ្នំពេញហ្នឹង គាត់ប្រាប់អ៊ីចឹង។ គាត់ប្រាប់ថា ឲ្យនាំគ្នាប្រមូលគ្នាហ្នឹង ប្រមូលផ្ដុំកងទ័ពរត់ចូលព្រៃតស៊ូម្ដងទៀត។ ថាតែប៉ុណ្ណឹង ខ្ញុំស្ដាប់ឮ។ ប៉ុនគាត់ថាច្រើនជាងហ្នឹងក៏ខ្ញុំមិនឮ អាហ្នឹងប្រហែលជាច្រើនជាងហ្នឹង ប៉ុនខ្ញុំឮសូរច្បាស់តែប៉ុណ្ណឹង។ ដែលខ្ញុំចូលទៅប្រមូលយកកែវ យកកែវទឹក កែវអីហ្នឹង។ គាត់រៀបបែកគ្នាហ្នឹង កាលហ្នឹង។

[១៥:៥៤:៤០]

**ស៖** លោកចង់មានន័យថាម៉េច ពេលដែលលោកថាលោកទៅប្រមូលកែវហ្នឹង?

**ឆ៖** បាទ ពេលដែលគាត់នៅអង្គុយនៅតុហ្នឹង មានកែវទឹក កែវអ៊ីចឹង ដាក់ទឹកហូប សម្រាប់ឲ្យគាត់ហូប ដល់ពេលគាត់ឡើងចេញ ខ្ញុំមិនប្រមូលអាកែវហ្នឹងយកមកវិញ ដាក់ទៅតាមគាត់ ទៅតាមឡានដែលគាត់ទៅវិញនោះ ឡើងទៅហ្នឹង បាទ អ៊ីចឹង។

**ស៖** ពេលហ្នឹងនៅក្នុងបន្ទប់ហ្នឹងមានតែ ហេង សំរិន និង សោ ភឹម ទេ ឬក៏មានអ្នកផ្សេងទៀតដែរ?

**ឆ៖** មានតែគាត់ពីរនាក់ ហេង សំរិន ហ្នឹងបាទ។

**ស៖** សោ ភឹម ដូចដែលខ្ញុំបានប្រាប់លោកអ៊ីចឹង គឺគាត់បានធ្វើអត្តឃាត នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៨ អ៊ីចឹង ពេលដែលគាត់ប្រាប់ឲ្យ ហេង សំរិន ប្រមូលគ្នាទៅវ៉ៃប្រឆាំង ប៉ុល ពត ហ្នឹង <មុន

គាត់ស្លាប់ប៉ុន្មានថ្ងៃ>ដែរ?

**ឆ៖** បាទ ពេលនុ៎ង មុននុ៎ងប្រហែលជាបីបួន -- ខ្ញុំថាមួយពេលដែលគាត់ មុនគាត់ស្លាប់ ប្រហែលជា១០ថ្ងៃចុះយ៉ាង ប្រហែលជា១០ថ្ងៃ ឬក៏លើនុ៎ងបន្តិច ព្រោះគាត់ថា ពីកន្លែងនុ៎ងហើយ គាត់ក៏ចុះមកដល់អរិយក្សត្រនុ៎ង។ ដល់អរិយក្សត្រហ្នឹង គេចាប់រត់ទាំងខ្ញុំទាំងអីហ្នឹងទៅ ខ្ញុំនៅរយៈនុ៎ងវាពីរបីថ្ងៃទៀត ហើយទម្រាំនឹងរត់ ឮដំណឹងដល់គ្នាហ្នឹង វាមួយអាទិត្យជាងទៀត មើលទៅវាជា១០ថ្ងៃហើយ។ ១០ថ្ងៃជាងហើយ បានពេលគាត់ធ្វើអត្តឃាតហ្នឹង។ ប៉ុន្តែវាមិនដឹងថ្ងៃប៉ុន្មាន ខែស្អីប៉ុន្មាន ខ្ញុំមិនបានចាំដែរបាទ។ សូមចប់បាទ។

[១៥:៥៧:១៣]

**ស៖** ពេលហ្នឹង គឺក្នុងពេលដែលលោករៀបរាប់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចដែលខ្ញុំបានអានជូនលោកស្តាប់ហ្នឹង គឺពេលហ្នឹង គឺគាត់នៅបន្តផឹកស្រាស្រវឹងទៀតមែនទេ? គឺពេលដែលគាត់ឲ្យហេង សំរិន ប្រមូលកម្លាំងទ័ពហ្នឹង គឺពេលដែលគាត់ផឹកស្រាហ្នឹងមែនទេ?

**ឆ៖** បាទ ពេលនុ៎ង គាត់ហូបស្រាបាទ។ ពេលគាត់ជួបនុ៎ង គាត់ហូបស្រា អាពេលហ្នឹងគាត់និយាយ។

**ស៖** លោកដឹងថា តើ ហេង សំរិន ធ្វើតាមបញ្ជា សោ ភឹម ទេ? ហើយបើធ្វើតាមនោះ តើហេង សំរិន គាត់ធ្វើយ៉ាងម៉េចខ្លះ?

**លោក នីកូឡាស គូមជែន៖**

<លោកប្រធាន ខ្ញុំគិតថា> ដើម្បីឲ្យយុត្តិធម៌ មុនពេលសាក្សីឆ្លើយតប <ការដកស្រង់នូវ> ចម្លើយពេញលេញរបស់សាក្សី<គួរតែផ្តល់ឲ្យគាត់។ នៅលើទំព័រនោះ> គាត់បាននិយាយ<ទៅ>មជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលនោះ<ថា> គាត់ទៅភ្នំពេញ ដើម្បីដោះស្រាយបញ្ហាមួយចំនួន។ ខ្ញុំសូមស្រង់ "គាត់បាននិយាយថា ខ្ញុំទៅភ្នំពេញ បើខ្ញុំបាត់ខ្លួនក្នុងរយៈពេលមួយសប្តាហ៍ <រិន ឯង>ត្រូវចូលព្រៃប្រមូលកម្លាំងដែលនៅសេសសល់ ហើយតស៊ូប្រយុទ្ធទៅ"។ ដូច្នេះ គាត់បាននិយាយថា បើគាត់មិនត្រឡប់មកវិញទេ ក្នុងរយៈពេលមួយសប្តាហ៍ គឺត្រូវតែអនុវត្ត។

**លោក វ៉ិចទ័រ កូប៉េ៖**

បើមិនជាបញ្ហាអ្វីទេ ខ្ញុំគ្រាន់តែចង់ចំណេញពេលវេលា បានជាខ្ញុំសង្ខេបបែបនេះនោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ៊ីចឹង ខ្ញុំចង់សួរលោកថា ពេលដែល សោ ភឹម បញ្ជាឲ្យ ហេង សំរិន ប្រមូលកម្លាំងទ័ព ដើម្បីវាយប្រយុទ្ធជាមួយនឹង ប៉ុល ពត ហ្នឹង តើ ហេង សំរិន គាត់អនុវត្តតាមនុ៎ងទេ?

[១៥:៥៩:២០]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គឺមួយពេលគាត់និយាយនុ៎ង គាត់ទៅនុ៎ង ដែល ហេង សំរិន គាត់ធ្វើ។ អាហ្នឹងគាត់ធ្វើ ឬក៏មិនធ្វើ ខ្ញុំក៏មិនដឹងដែរ ព្រោះវាដាច់ទាំងខ្ញុំ ទាំងគាត់ ទាំងអីទាំងអស់គ្នាទៅ បែកបាក់គ្នាបាត់អស់ទៅ តែត្រង់គាត់ធ្វើ មិនធ្វើអាហ្នឹងខ្ញុំក៏មិនដឹងដែរ អារឿងផែនការនឹងធ្វើហ្នឹង។ ខ្ញុំដឹងតែប៉ុណ្ណឹងបាទ។

**ស៖** សំណួរចុងក្រោយលោកប្រធាន មុនពេលឈប់សម្រាក សូមអនុញ្ញាត។ លោកសាក្សី នៅពេលពិភាក្សាគ្នាអំពីរដ្ឋប្រហារនៅក្នុង<ចម្លើយរបស់លោក ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ ERN អង់គ្លេស 01353348>, ជាភាសាខ្មែរ គឺ <01340560> លោកថា៖ “ខ្ញុំមិនដឹងពីរដ្ឋប្រហារទេ។ ខ្ញុំគ្រាន់តែឮថាពួកគេ -- ខ្ញុំគ្រាន់តែដឹងថាគេចាប់គាត់។ ហើយគេថា សោ ភឹម ហ្នឹងគឺចូលដៃជាមួយយួន គឺរួមកម្លាំងជាមួយយួន។” <នរណានិយាយ ឬ>លោកឮយ៉ាងម៉េចថា សោ ភឹម ហ្នឹងគាត់រួមកម្លាំង រួមដៃជាមួយជាយួនហ្នឹង?

**ឆ៖** បាទ ខ្ញុំសុំឆ្លើយអាពេលដែលថារួមដៃជាមួយយួនហ្នឹងគឺ អាពេលដែលកំពុងតែគេចាប់ជិះដាច់ហើយហ្នឹងគឺ គេទម្លាក់ត្រាក់ចេញពីកាប៉ាល់ហោះមួយគ្រឿងហោះពីភ្នំពេញឡើងទៅតាមភូមិភាគបូព៌ាហ្នឹង បាចក្រដាស់ខិត្តប័ណ្ណពេញចេញពីយន្តហោះមក។ ខ្ញុំក៏រើសបាន ប្រជាជនក៏គេរើសបាន។ គេមើលទៅថា សោ ភឹម ក្បត់ជាតិចូលរួមដៃជាមួយយួនជាមួយអីហ្នឹងណ៎ា។ មើលតាមឯកសារនុ៎ងបាទ។ សុំចប់។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថា ឥឡូវនេះម៉ោងបួនដល់ពេលឈប់សម្រាកហើយ។

[១៦:០១:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ហើយសវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០៥ ខែធ្នូ ឆ្នាំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស៊ិន អ៊ីង ហើយនិងមានសាក្សីបម្រុង 2-TCW-1060។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយអង្គជំនុំជម្រះអរគុណ លោក ស៊ិន អ៊ីង។ សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចាប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរ -- អង្គជំនុំជម្រះក៏សូមអញ្ជើញមេធាវីប្រឹក្សាសាក្សីមកប្រឹក្សាសាក្សីរូបនេះនៅថ្ងៃចន្ទ សប្តាហ៍ក្រោយទៀតដែរ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះវិលត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់មកចូលរួមសវនាការ នៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី០៥ ខែធ្នូ ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*